ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ

# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី “ឌុច”

## សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៩**

**សវនាការលើកទី៦៨**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោក ម៉ាតូ គ្រីប្ពារ *(Mr. Matteo Crippa)*

កញ្ញា អៃដា កេសាវ៉ាហ្ស៊ី *(Aida KESHAVARZI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក អានីស អះមេដ *(Mr. Anees AHMED)*

លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល

*(Mr. Vincent DE WILDE D'ESTMAEL)*

លោក ពេជ្រ សម្បត្តិ

លោក ប៉ាក ច័ន្ទលីណូ

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គឹម ម៉េងឃី

លោក អាឡាំង វ៉ែនណឺ*(Mr. Alain Werner)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## លោកស្រី ស៊ីរ៉ូនី ហ្គ្លៀលបូ និង លោក ភា ស៊ុនបូណាត

សួរដោយលោក ហ្វ្រង់ស្វ័រ រូ ផ្ដើមពី........................................................ទំព័រ ៣

## លោកស្រី ស៊ូ សាត

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................ទំព័រ ២៥
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ ផ្ដើមពី ........................................................ទំព័រ ២៩
សួរដោយលោក តាន់ សេណារ៉ុង ផ្ដើមពី ........................................................ទំព័រ ២៩
សួរដោយលោក ដឺវ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ........................................................ទំព័រ ៣១
សួរដោយលោក ការ សាវុត្ថ ផ្ដើមពី........................................................ទំព័រ ៣៤
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្ដើមពី........................................................ទំព័រ ៣៥

## លោក ទេព សែម

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................ទំព័រ ៣៧
សួរដោយលោក តាន់ សេណារ៉ុង ផ្ដើមពី ........................................................ទំព័រ ៤២
សួរដោយលោក ដឺវ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ........................................................ទំព័រ ៤៣
សួរដោយលោក ការ សាវុត្ថ ផ្ដើមពី........................................................ទំព័រ ៤៨

## លោក ទេព សុខ

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................ទំព័រ ៥០
សួរដោយលោក តាន់ សេណារ៉ុង ផ្ដើមពី ........................................................ទំព័រ ៥៦
សួរដោយលោក ដឺវ៉ាយដ៍ ដេស្មាឯល ផ្ដើមពី ........................................................ទំព័រ ៥៧
សួរដោយលោក ការ សាវុត្ថ ផ្ដើមពី........................................................ទំព័រ ៦០
សួរដោយលោក ហ្វ្រង់ស្វ័រ រូ ផ្ដើមពី........................................................ទំព័រ ៦៣

## លោក ជុំ ទិន

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ....................ទំព័រ ៦៦
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍ ផ្ដើមពី ....................ទំព័រ ៧៥
សួរដោយលោក តាន់ សេណារ៉ុង ផ្ដើមពី ....................ទំព័រ ៧៧
សួរដោយលោក ដឺវ៉ាយដ៍ ដេស្នាឯល ផ្ដើមពី ....................ទំព័រ ៧៩
សួរដោយលោក ការ សាវុត្ថ ផ្ដើមពី....................ទំព័រ ៨៣
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្ដើមពី....................ទំព័រ ៨៦

## បញ្ជីឈ្មោះ អ្នកនិយាយ៖

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| លោក អានីស អះមេដ | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ជូ វិន | ខ្មែរ |
| លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក កា ស៊ុនបូណាត | ខ្មែរ |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោកស្រី ស៊ូ សាត | ខ្មែរ |
| លោកស្រី ស៊ីរ៉ូនី ហ្គៀលបូ | បារាំង |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក ទេព សែម | ខ្មែរ |
| លោក ទេព សុខ | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក អាឡាំង វែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៣:១០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

នៅព្រឹកនេះ តាមរបៀបវារៈគ្រោងទុកយើងបន្តស្តាប់នូវរបាយការណ៍របស់អ្នកជំនាញចំនួនពីររូប ដែលធ្វើសវនាការកាលពីម្សិលមិញ ហើយមិនទាន់ចប់ដោយនៅការតាំងសំណួរពីមេធាវីការពារក្តីអន្តរជាតិមួយរូបទៀត ។ ហើយមុននឹងប្រគល់វេទិការនេះទៅមេធាវីការពារក្តី អង្គជំនុំជម្រះអញ្ជើញក្រឡាបញ្ជីសវនាការឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួមនៅក្នុងដំណើរការនីតិវិធីនៅក្នុងដំណើរការសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរនីតិវិធីសវនាការក្នុងថ្ងៃមានវត្តមានគ្រប់ចំនួន លើកលែងតែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីពីរ និងក្រុមទីបួន អវត្តមាន ។

អ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ លោក កាស៊ុន បូណាត និងលោកស្រី ហ្វ្រង់ស័រ ស៊ីរ៉ូនី ហ្កៀលបូ មានវត្តមាន ។ ចំណែកឯសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ពីអ្នកជំនាញទាំងពីររូបមាន សាក្សី D1, D2, D3, D4, D5 និងD6 មានវត្តមាន រង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។ សាក្សីទាំងប្រាំមួយរូបនេះ មិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ សាក្សីទាំងប្រាំមួយរូបបានស្បថរួចហើយ ។

[០៩:០៥:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី អាឡាំង វ៉ែនណឺ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ជាទីគោរព! ខ្ញុំសូមលើកចំណុចចំនួនពីរ ទីមួយទាក់ទងទៅនឹងបញ្ហាការបកប្រែ មិនមែនមេធាវីក្រុមពីរ និងបីនោះទេ ។ គឺមេធាវីក្រុមពីរ និងក្រុមបួនដែលអវត្តមាន ។ ហើយចំណុចមួយទៀត គឺខ្ញុំមានសំណើមួយខ្លី ដូចដែលលោកប្រធានបានជ្រាបហើយ ហើយខ្ញុំបានប្រកាសកាលពីដើមសវនាការកាលពីម្សិលមិញ ដើមបណ្តឹងរដ្ឋប្បវេណីគួរតែ

មានវត្តមាន ហើយគាត់បានសរសេរលិខិតចំហមួយជូនអង្គសវនាការ ហើយលិខិតចំហនោះ បានដាក់ជូនទៅក្រឡាបញ្ជីរួចហើយ ។ យើងខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះនឹងអាននូវលិខិតនោះ ហើយលិខិតនោះ គឺមិនទាន់បានដាក់ទៅតាមវិធាននៅឡើយទេ ។

លិខិតដែលខ្ញុំផ្ញើជូន ដែលមេដើមបណ្តឹងរដ្ឋប្បវេណីផ្ញើជូននោះគឺវាខ្លីតែប៉ុណ្ណោះ ដូច្នេះវាចំណាយប្រហែលតែមួយនាទីប៉ុណ្ណោះក្នុងការអានលិខិតនោះ ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតពីលោកប្រធាន ហើយខ្ញុំគិតថា បើសិនជាខ្ញុំអាននោះវាមានលក្ខណៈងាយស្រួលជាង ហើយខ្ញុំសង្ឃឹមថា លិខិតនោះនឹងដាក់ចូលទៅក្នុងសំណុំរឿង ។

លិខិតនេះ គ្រាន់តែជាការស្នើសុំឲ្យលើកឡើងអំពីបញ្ហាដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ដូច្នេះហើយ គឺខ្ញុំសូមអនុញ្ញាត ប្រហែលជាមួយនាទីប៉ុណ្ណោះក្នុងការអានទៅលើលិខិតនេះ ។ សូមអរគុណ ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១០:៥៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី អាឡាំង វ៉ែនណឺ អញ្ជើញក្រោកឈរ! លោកបានលើកឡើងអំពីលិខិតរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលលោកបានលើកឡើងកាលពីម្សិលមិញ ហើយលោកអះអាងថាបានដាក់ជូនដល់ក្រឡាបញ្ជីរួចហើយ ។

សំណួរសួរថា តើលិខិតនោះជាលិខិតរបស់អ្នកណាគេ? ជារបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយការស្នើដាក់នោះ ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើដាក់? យើងមើលលក្ខណៈទម្រង់នៃលិខិតនុ៎ង គឺមិនបានមានទម្រង់តាមបែបផែននៃការណែនាំអំពីការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះទេ ។ អ៊ីចឹងបញ្ហានេះ លោកបញ្ជាក់ឲ្យបានច្បាស់លាស់លើបំណងនៃការស្នើសុំដាក់ឯកសារនោះនៅចំពោះមុខអង្គជំនុំជម្រះ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ចំពោះសំណួររបស់លោកប្រធាន។ ទាក់ទងទៅនឹងរបៀបដែលយើងដាក់លិខិតនោះ គឺថាក្រឡាបញ្ជីអាចជម្រាបលោកប្រធានអំពីបញ្ហានេះ ។ តាមអ្វីដែលខ្ញុំយល់ ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់បានដាក់លិខិតនេះជូនអង្គជំនុំជម្រះសាលាដំបូង ហើយលិខិតនោះ គឺមិនមែនជាលិខិតចេញពីមេធាវីនោះទេ គឺដើមបណ្តឹងរដ្ឋប្បវេណីម្ភៃប្រាំបីជាអ្នកចុះហត្ថលេខា ។ ខ្ញុំបាន

ជម្រាបកាលពីម្សិលមិញហើយពេលព្រឹក យើងមិនបានចុះហត្ថលេខានោះទេ ហើយវាមិនមែនជាកិច្ចគតិយុត្តពីខាងមេធាវីនោះទេ ។

[០៩:១២:៤៧]

ហើយយើងមិនបានចូលរួមនៅក្នុងការសរសេរ និងចុះហត្ថលេខាទៅលើលិខិតនោះទេ យើងដឹងហើយថា យើងត្រូវដាក់តាមវិធាន ក្រឡាបញ្ជីក៏ជម្រាបយើងពីបញ្ហានេះ ។ គោលបំណងនៃលិខិតនោះគឺយើងគួរតែក្នុងលក្ខណៈសន្សំសំចៃដោយយើងមិនចាំបាច់បកប្រែ ធ្វើការបកប្រែអីផ្សេងៗ ។ ដូច្នេះហើយ គឺខ្ញុំសូមអនុញ្ញាតឲ្យអានវាក្នុងរយៈពេលមួយនាទីតែប៉ុណ្ណោះ ហើយអាចកត់ប្រតិចារឹកបាននៅក្នុងឯកសារតុលាការរបស់យើង ។ មេធាវី បើសិនមេធាវីវិញ យើងនឹងដាក់សេចក្តីសន្និដ្ឋាន ហើយមានការបកប្រែត្រឹមត្រូវចូលទៅក្នុងសំណុំរឿង ប៉ុន្តែនៅពេលនេះ ខ្ញុំគ្រាន់តែចង់ស្នើដំណោះស្រាយមួយនៅពេលនេះដែលវាជាដំណោះស្រាយល្អ ហើយប្រហែលជាចំណាយពេលតែប្រាំនាទី ប៉ុណ្ណោះយើងស្តាប់នូវអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីគាត់មានបំណងលើកឡើងនៅក្នុងលិខិតរបស់គាត់ ដោយយើងមិនចាំបាច់ធ្វើការបកប្រែអីផ្សេងៗនោះទេ ជាឯកសារនោះ ។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១៤:៣៥]

**ប្រធានអង្គជំនុំ៖**

កាលដែលលោកមេធាវី អាឡាំង វ៉ែនណឺ បានលើកឡើងនេះ អង្គជំនុំជម្រះបានឯកភាពគ្នាជាឯកច្ឆន្ទថាយល់ព្រមឲ្យដាក់ឯកសារនេះចូលទៅក្នុងសំណុំរឿង ប៉ុន្តែមិនអនុញ្ញាតឲ្យលោក អាឡាំង វ៉ែនណឺ អាននូវលិខិតនោះទេ ។

ជាកិច្ចបន្តអង្គជំនុំជម្រះ សូមប្រគល់វេទិកាទៅមេធាវីការពារក្តីអន្តរជាតិ ដើម្បីអាចសួរសំណួរទៅដល់អ្នកជំនាញទាំងពីររូបនេះ ហើយលោកមេធាវីការពារក្តីអន្តរជាតិមានពេលវេលាសែសិបមីនុតក្នុងការតាំងសំណួរនេះ ។ សូមអញ្ជើញ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន អរគុណលោក លោកស្រីចៅក្រមជាទីគោរព ។

សូមគោរព អរុណសួស្តីលោក លោកស្រីអ្នកជំនាញ លោកប្រធានជាទីគោរព! ខ្ញុំនឹងព្យាយាមតាំងសំណួររបស់ខ្ញុំទៅកាន់អ្នកជំនាញក្នុងរយៈពេលសែសិបនាទី ។ ប្រសិនបើខ្ញុំមិនអាចបញ្ចប់ក្នុងរយៈ

ពេលសែសិបនាទី ខ្ញុំសូមពេលវេលាបន្ថែម ។

**ស៖** លោក លោកស្រីអ្នកជំនាញ! ជាបឋម ខ្ញុំសូមសួរសំណួរលោក លោកស្រី ។ យើងសូមលើកឡើងចំពោះការប្រែចំណុចចំនួនពីរទាក់ទងទៅនឹងការស្នើសុំ-- ទម្រង់នៃការស្នើសុំរបស់ជនជាប់ចោទ ។ យើងដឹងហើយថា គាត់មានភាពហ្មត់ចត់ ហើយយើងចង់ឲ្យមានការកែប្រែនៅក្នុងឯកសាររបាយការណ៍បារាំងទំព័រទី២៣ ដែលលោក លោកស្រីបានលើកឡើងថា គាត់មានកូនបួនរូប ។ កូនស្រីកើតឆ្នាំ១៩៧៧ ខែបួន ថ្ងៃទី២៧ ហើយនិងកូនកើតនៅក្នុងថ្ងៃ-- កូនប្រុសកើតនៅក្នុងថ្ងៃ១៤, ១៧ ឆ្នាំ១៩៧៨ និងកូនស្រីកើតឆ្នាំ៣០ ខែ៦ ឆ្នាំ១៩៨១ ។ តាមពិតឆ្នាំ៨១ នោះ គឺជាកូនប្រុសតែប៉ុណ្ណោះ មិនមែនកូនស្រីទេ ។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតធ្វើការកែប្រែទៅលើចំណុចនេះ ហើយចំណុចកែប្រែមួយទៀត គឺនៅក្នុងទំព័រទី២៧ នៃរបាយការណ៍របស់លោក លោកស្រី ។ នៅក្នុងនោះ គឺមានការឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម ឡាវែន៍ផងដែរ កាលពីម្សិលមិញ ។

នៅក្នុងទំព័រទី២៧ ឯកសាររបាយការណ៍បារាំង លោក លោកស្រីបានលើកឡើងថា "ប៉ុន្តែ ឌុច មិនបានចាំអំពីចំនួនជនរងគ្រោះនៅស-២១ នៅដើមដំណាក់កាលស៊ើបអង្កេតដំបូង ។ ហើយគាត់បានពិនិត្យបណ្ណសារនិងរូបថតផ្សេងៗ ហើយនៅពេលនោះ គាត់បានផ្តល់តួលេខចំនួនពីររយ ។ ខ្ញុំគិតថាប្រហែលជាមានការភ័ន្តច្រឡំនៅក្នុងចំណុចហ្នឹង ។ នៅពេលដែលយើងធ្វើការពិនិត្យកំណត់ហេតុសួរចម្លើយចំនួន គឺមិនបានលើកឡើងនោះទេ ហើយប៉ុន្តែបែរជាលោក លោកស្រីបានលើកឡើងចំនួនពីររយនៅក្នុងរបាយការណ៍របស់លោកស្រី ។

[០៩:១៨:៥៧]

ដូច្នេះហើយ វាជាភាពចាំបាច់ ដែលយើងកត់ត្រាឲ្យបានត្រឹមត្រូវ ហើយគាត់មានលក្ខណៈហ្មត់ចត់និងប្រយ័ត្នប្រយែង ហើយខ្ញុំសូមធ្វើការសង្កេតទៅលើចំណុចនេះ ។ ដរាបណាយើងមិនមានការយោងខុសទៅក្នុងកំណត់ហេតុសួរចម្លើយ នៅពេលនោះយើងនឹងពុំមានបញ្ហាហើយ ។ ហើយនៅពេលនេះ គឺខ្ញុំសូមតាំងសំណួរជូនលោក លោកស្រីអ្នកជំនាញ ។

ខ្ញុំអាចនិយាយជាបឋមថា លោកស៊ុន ប៊ូណាត និងលោកស្រី ស៊ីរ៉ូនី ហ្គៀលប្លូ ខ្ញុំសូមថ្លែងអំណរគុណចំពោះសក្ខីកម្ម ដែលលោក លោកស្រីបានផ្តល់ជូនអង្គជំនុំជម្រះនេះ កាលពីម្សិលមិញ ហើយនិងការពន្យល់កាលពីម្សិលមិញ ដែលលោក លោកស្រីបានលើកឡើងថា វាមិនមែនជាវិធីក្នុងការបញ្ជាក់ថាឧក្រិដ្ឋកម្មនោះត្រឹមត្រូវនោះទេ ។ ហើយវាជាគោលបំណងក្នុងការស្វែងយល់ថា ឌុច ក្លាយទៅជាមនុស្ស

ដែលហៅថា ឌុច នេះយ៉ាងដូចម្តេច?

ដូច្នេះ ខ្ញុំអាចជម្រាបជាសេចក្តីដំបូងចំពោះសំណួររបស់ខ្ញុំ ខ្ញុំមានលក្ខណៈងាយស្រួលចំពោះការវិភាគរបស់សហព្រះរាជអាជ្ញាដែលគាត់បានវិភាគទៅលើស្ថានភាពនោះ ។ ឌុច នៅថ្ងៃនេះមិនមែនជាបុគ្គលតែម្នាក់ដែលគាត់បដិសេធ និងស្ថិតនៅក្នុងស្ថានភាពបដិសេធទេ ។ សហព្រះរាជអាជ្ញា គាត់បានលើកឡើងនូវចំណុចមួយដែលមិនមែនជាបញ្ហានៅក្នុងសំណុំរឿងរបស់យើងនោះទេ ។ គឺចំណុចដូចនេះ ឌុច បាននិយាយថា គាត់គឺមនុស្សកំសាក ។ ឌុច បាននិយាយថា គាត់មិនបានពិនិត្យទៅមើលស្ថានភាពជាក់ស្តែង ហើយគាត់មិនបានជួបមិត្តភក្តិរបស់គាត់ ដែលត្រូវបានជាប់ឃុំ ។ ឌុច បានលើកឡើងថា គាត់គ្រាន់តែគោរពបញ្ជាតែប៉ុណ្ណោះ ប៉ុន្តែយ៉ាងណាក៏ដោយ គាត់ទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅស-២១ ។ ឌុច គាត់បានទទួលស្គាល់ចូលរួមនៅក្នុងការសម្តែងឡើងវិញនៅជើងឯក និងនៅស-២១ ផងដែរ ។ ឌុច បានសហការជាមួយនឹងសហចៅក្រមស៊ើបអង្កេត ដូចដែលបានសរសេរនៅក្នុងកថាខណ្ឌ១៦៧ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ ឌុច បានទទួលស្គាល់៨៥ភាគរយនេះតាមការគណនារបស់យើងខ្ញុំ ចំពោះអង្គហេតុដែលសហព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ ។ ខ្ញុំសូមពន្យល់ទៅលើចំណុចនេះ ។

យើងនៅក្នុងខែមករា ឆ្នាំនេះ បានទទួលនូវឯកសារ ដែលមាន ១៦០កថាខណ្ឌ ស្នើសុំឲ្យជនជាប់ចោទទទួលស្គាល់ទៅលើកថាខណ្ឌអង្គហេតុ១៦០នោះ ហើយយើងទទួលស្គាល់៨៥ភាគរយ ។ ឌុច បានស្នើសុំការអនុគ្រោះពីជនរងគ្រោះដោយនិយាយថា “ខ្ញុំមិនសូមឲ្យជនរងគ្រោះអនុគ្រោះខ្ញុំនោះទេ ខ្ញុំគ្រាន់តែបញ្ជាក់សូមទោសរបស់ខ្ញុំ” ។

[០៩:២៣:០៥]

ដូច្នេះ តាមរយៈភស្តុតាងទាំងអស់នេះ ដែលវាមានផុសចេញពីសំណុំរឿងនិងនីតិវិធីរបស់យើង ហើយនិងផុសចេញពីអ្វីដែលសហព្រះរាជអាជ្ញាបានពិនិត្យឃើញនោះ គឺជនជាប់ចោទមានការសហការជាមួយនឹងខាងការិយាល័យរបស់លោក ។ ថាតើនេះជាដំណើរការងាយស្រួលដែរឬទេ អ្វីដែលគាត់បានធ្វើចំពោះមនុស្សទូទៅ ជាពិសេសចំពោះប្រជាជនកម្ពុជាមួយរូប? ថាតើនេះជាដំណើរការមួយដែលគាត់បានហាក់ដូចជាក្រោកឈរប្រឈមទៅនឹងសាធារណជន ហើយទទួលស្គាល់ជាទូទៅអំពីការទទួលខុសត្រូវរបស់គាត់ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរបែបនោះ? នេះជាសំណួរទីមួយរបស់ខ្ញុំ ។

ដូច្នេះ វាមានលក្ខណៈងាយស្រួល និងជាពិសេសចំពោះ ឌុច ថាតើមានលក្ខណៈងាយស្រួល

សម្រាប់គាត់ក្នុងការបង្ហាញជំហរបែបនេះដែរឬទេ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលបូ)** ជាការពិត វាមិនមានភាពងាយស្រួលចំពោះបុគ្គលណាមួយនោះទេ ហើយវាមិនមានភាពស្រួលសម្រាប់ ឌុច ផងដែរ ដែលគាត់លើកឡើងអំពីបញ្ហានេះ ។ ហើយប្រសិនអនុញ្ញាតនោះ ខ្ញុំសូមបន្ថែមយោបល់មួយទាក់ទងទៅនឹងការវិវត្តន៍ផ្នែកចិត្តសាស្ត្ររបស់គាត់ ដែលយើងបានពិនិត្យក្នុងពេលកោសល្យវិច័យជាមួយនឹងគាត់ ។ យើងបានធ្វើការវិភាគទៅលើរូបគាត់ នៅកាលពីឆ្នាំមុន ហើយនៅពេលថ្មីក៏យើងវិភាគទៅលើគាត់ផងដែរ ។ នេះគឺជាដំណើរការនៃការទទួលស្គាល់។ វាជាដំណើរការ ។ ហើយបានសួរថា ដំណើរការវាមានភាពស្រួលដែរឬទេ? វាមិនមានភាពងាយស្រួលនោះទេ ខ្ញុំនិយាយអំពីដំណើរការដែលថាជនជាប់ចោទ គាត់បានឆ្លងកាត់ដំណាក់កាលជាច្រើនទាក់ទងទៅនឹងអង្គហេតុដែលយើងបានពិភាក្សាជាមួយគាត់ ។ ហើយនៅពេលដំបូង គឺវាមានបដិសេធ គឺ *ឌិណាយអលមែន* គឺគោលបំណងដែលគាត់មិនចង់ទទួលស្គាល់ ។ ខ្ញុំនឹងនិយាយនៅទីនេះ អំពីយន្តការយុទ្ធសាស្ត្រ ហើយបន្ទាប់មកយើងឃើញអំពីការបដិសេធមួយទៀត គឺដំណាក់កាលទីពីរ *ឌីនីហ្គេសិន* គឺការទទួលស្គាល់អង្គហេតុតែមួយផ្នែកតែប៉ុណ្ណោះ។ បានន័យថាអង្គហេតុមួយចំនួនទទួលស្គាល់ ហើយ អង្គហេតុមួយចំនួនទៀតគឺមិនទទួលស្គាល់ឡើយ ។

[០៩:២៥:៣៧]

ដូច្នេះហើយ ផ្នែកមួយចំនួនដែលជាការពិតគាត់ទទួលស្គាល់ ហើយដំណាក់កាលទីបី ការវិវឌ្ឍន៍នោះ គឺវាជាដំណាក់មួយ ជាការចាប់អារម្មណ៍ ដែលវាជាការបង្ហាញចំពោះអង្គជំនុំជម្រះ ។ គឺជាការផ្លាស់ប្តូរចំពោះការចោទប្រកាន់ទៅលើខ្លួនឯង នៅក្នុងដំណាក់ទីបី ។

ដូច្នេះហើយយើងមិនបានឃើញថា ក្នុងករណីរបស់គាត់យើងមិនបានឃើញ ការទទួលស្គាល់ជាលក្ខណៈអព្យាក្រឹត្យមួយ ។ ដូច្នេះហើយខ្ញុំសូមបញ្ជាក់ថា គាត់បានផ្លាស់ប្តូរដំណាក់កាលទីពីរ ទៅដំណាក់កាលទីបី គឺដំណាក់កាលដែលចោទប្រកាន់ទៅលើខ្លួន ។ ដូច្នេះហើយនៅក្នុងចំណុចនេះ គឺយើងពិនិត្យឃើញអំពីយន្តការចិត្តសាស្ត្រនៅក្នុងខ្លួនរបស់ ឌុច ដែលវាពាក់ព័ន្ធទៅនឹងធាតុផ្សំចិត្តសាស្ត្រផ្សេងៗ វាផុសចេញពីកុមារភាពរបស់គាត់ផងដែរ ។ ហើយវាបានពិនិត្យនិងគិតពិចារណាឡើងវិញអំពីការទុកចិត្តទៅលើខ្លួនឯង ហើយវាបង្ហាញចេញទៅលើការចោទប្រកាន់ទៅលើខ្លួនគាត់ ។

ដូច្នេះ វាជាការវិវត្តន៍នៅក្នុងដំណាក់ការមួយទៅដំណាក់ការមួយនៃដំណើរការចិត្តសាស្ត្រ ដែល

យើងបានពិនិត្យឃើញ ។

**ស៖** សូមអរគុណលោកស្រីច្រើន គឺលោកស្រី គឺពិតជាចង់ដឹងសំណួរបន្ទាប់របស់ខ្ញុំ នៅក្នុងនេះ គឺយើងនិយាយអំពីដំណើរការចិត្តសាស្ត្រ ហើយលោកស្រីក៏បញ្ជាក់ជូនយើងខ្ញុំ ។ ដូច្នេះ គឺខ្ញុំសូមបន្ថែមថា នៅក្នុងដំណើរការនេះ វាហាក់ដូចជាមានការរារាំង ហើយវាមានលក្ខណៈពិបាកណាស់ក្នុងការដោះស្រាយ ហើយយើងមិនអាចសម្តែងចេញនូវអារម្មណ៍ទាំងអស់នេះ ។ តើវាជាអ៊ីចឹងដែរឬទេ កើតចេញពីដំណើរការហ្នឹង?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលប្ញ)** ជាការពិតលោក រួ វាអាចជាផ្នែកមួយនៅក្នុងដំណើរការចិត្តសាស្ត្រហ្នឹងដែរ ។ យើងអាចនិយាយថា វាមានចំណុចនិងរឿងរ៉ាវ ដែលពិបាកក្នុងការទទួលស្គាល់ ហើយវាមានធាតុពិបាកៗមួយចំនួន គឺអ្វីទាំងឡាយវាឆ្លងកាត់ទៅនឹងដំណើរការចំពោះបុគ្គលនីមួយៗ ។ វាអាចចំណាយពេលតិច ឬច្រើនអាស្រ័យទៅលើប្រវត្តិផ្ទាល់របស់បុគ្គល ហើយវាក៏អាស្រ័យទៅលើអាចអ្វីដែលជំរុញឲ្យគាត់បានដឹង ដូចដែលយើងបានជម្រាបកាលពីម្សិលមិញថា ដំណើរការជំនុំជម្រះ គឺជាធាតុផ្សំមួយ ហើយវាមិនមែនសម្រាប់ ឌុច ទេ។ ប៉ុន្តែ វាអាចជាសម្រាប់ជនជាប់ចោទដទៃៗទៀត និងមនុស្សទាំងឡាយ ។

[០៩:២៨:៣៩]

ដូច្នេះហើយ ជាការពិតការជំនុំជម្រះវាជាការចែករំលែកចំពោះការទទួលស្គាល់មួយផ្នែកដែរ ។ ហើយខ្ញុំសូមបន្ថែមថា វាមានធាតុមួយទៀតដែលយើងគួរតែពិចារណា គឺកេរមរតកនៃការបង្កើតអត្ត-សញ្ញាណរបស់ខ្មែរក្រហម ដែលយើងបាននិយាយកាត់ពីម្សិលមិញ ។ ដូច្នេះវានៅក្នុងខ្លួនរបស់ជនជាប់ចោទនៅក្នុងដំណើរការចិត្តសាស្ត្រ ហើយយើងអាចពិចារណា និងពិនិត្យទៅលើជីវិតផ្លូវចិត្តរបស់ជនជាប់ចោទ ដែលយើងអាចពិចារណាទៅលើបញ្ហាកងពល ទ័ព ទាហានអីផ្សេងៗ ។

ដូច្នេះហើយធាតុផ្សំទាំងអស់នេះ គឺវាបង្ហាញនៅក្នុងការដំណើរការបង្កើតអត្តសញ្ញាណរបស់ខ្មែរក្រហម ។

**ស៖** លោកនិងលោកស្រីអ្នកជំនាញ គឺថា មិនបានឆ្លើយផ្ទាល់ទៅលើសំណួរដែលបានសួរទៅលោកអ្នកទាក់ទងទៅនឹងភាពស្មោះត្រង់ក្នុងការសម្តែងនូវការសោកស្តាយរបស់គាត់ ។ តើខ្ញុំអាចសួរលោក លោកស្រីនូវសំណួរដូចខាងក្រោមនេះបានទេ?

ទៅតាមការយល់ដឹងរបស់លោក តើលោកយល់ថា គាត់មានភាពស្មោះត្រង់ទេ នៅពេលដែល

គាត់ធ្វើការសម្តែងនូវការសោកស្តាយរបស់គាត់នោះ? នៅក្នុងដំណើរការនៃការទទួលស្គាល់នូវការទទួលខុសត្រូវរបស់គាត់។ តើលោកមានអារម្មណ៍ថា គាត់មានចិត្តស្មោះត្រង់ក្នុងការសម្តែងនូវមតិហ្នឹងដែរឬទេ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលប្ញ)** ខ្ញុំចង់ផ្តល់វេទិកានេះឱ្យទៅសហសេវិករបស់ខ្ញុំបន្តមកទៀត បន្ទាប់ពីខ្ញុំឆ្លើយរួច។ ទៅតាមការយល់ដឹងរបស់ខ្ញុំ ហើយខ្ញុំបានពិភាក្សាកិច្ចការនេះជាមួយនឹងសហសេវិករបស់ខ្ញុំដែរ ភាពស្មោះត្រង់របស់គាត់នៅក្នុងដំណើរការនេះ គឺខ្ញុំចង់បន្ថែមទាក់ទងទៅនឹងភាពស្មុគស្មាញនៃសំណួរ។ គឺពេលនេះយើងមិនចង់និយាយទៅលើពាក្យដែលលោកនិយាយថា ភាពស្មោះត្រង់នោះទេ ប៉ុន្តែគេចង់អំពីភាពស្មុគស្មាញ ទាក់ទងទៅនឹងដំណើរការនេះ ឬក៏អំពីអាទិភាពដែលជនជាប់ចោទគាត់មាននៅក្នុងយុទ្ធសាស្ត្ររបស់គាត់ក្នុងការបង្ហាញអំពីអាទិភាពនោះ ដើម្បីថាឲ្យគាត់ហ្នឹងអាចធ្វើការផ្លាស់ប្តូរស្ថានភាពបានដែរឬក៏អត់? ក៏ប៉ុន្តែនៅក្នុងយុទ្ធសាស្ត្ររបស់គាត់ យន្តការដែលគាត់ប្រើប្រាស់នូវអំពីការយល់ដឹងរបស់គាត់ អំពីអ្វីដែលបានកើតឡើងចំពោះគាត់ ចំពោះប្រវត្តិសាស្ត្ររបស់ប្រទេសគាត់ គឺជាដំណាក់កាលមួយនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសនេះ ។ តើសហសេវិករបស់ខ្ញុំ គាត់ចង់បន្ថែមអ្វីទៅលើសំណួរនេះដែរឬទេ លោក ស៊ុនបូណាត?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំមានយោបល់ដូចលោកស្រី ស៊ីរ៉ូនី ដែរ ប៉ុន្តែដូចដែលខ្ញុំបានឆ្លើយជូនពីថ្ងៃម្សិលមិញថា យើងមិនបានធ្វើការសិក្សាស្រាវជ្រាវដើម្បីស្វែងរកអំពីភាពស្មោះត្រង់នោះទេ ព្រោះអីប្រធានបទដែលយើងត្រូវស្វែងរកនោះគឺផ្សេង ។ ប៉ុន្តែ ខ្ញុំបានលើកឡើងផងដែរថា លោក ឌុច នៅពេលដែលបានជួបសម្ភាសន៍ជាមួយពួកយើង ពេលនោះយើងមិនបានសួរនាំអំពីអ្វីទាំងអស់នៅឡើយទេ តែលោកបានសម្តែងឲ្យយើងដឹងថា លោកនឹងធ្វើការសូមទោស ។ ដូច្នេះ ស្ថិតក្នុងសភាពបែបនេះ យើងអាចផ្ទុះបញ្ចាំងផងដែរថា តើលោកមានភាពស្មោះត្រង់នៅក្នុងការសម្តែង ការសូមទោសហ្នឹង ឬក៏ដោយមានសម្ពាធពីណាមួយ? ត្រង់នេះខ្ញុំគ្រាន់តែបង្ហាញអំពីសភាពការណ៍ ដែលស្ថានភាពដែលលោក ឌុច គាត់បាននិយាយថា គាត់មានបំណងសូមទោស ដើម្បីយើងពិចារណាទាំងអស់គ្នា ថាតើវាអាចមានភាពស្មោះត្រង់ ឬក៏អាចមកអំពីមានសម្ពាធ ឬក៏មានគោលបំណងណាផ្សេងពីនេះទៀត ។ ដោយសារយើងខ្ញុំមិនបានធ្វើការពិចារណា និងស្វែងយល់ឲ្យដល់ថា នេះជាការឆ្លើយដោយភាពស្មោះត្រង់ ឬក៏អត់ទេ ។ ខ្ញុំសូមឆ្លើយជូនដោយស្មោះត្រង់ ។

[០៩:៣៣:៤៣]

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលហ្វូ)** ខ្ញុំចង់បន្ថែមបន្តិចទៀត ទាក់ទងទៅនឹងបញ្ហានៃភាពស្មោះត្រង់របស់គាត់នោះ គឺថាបេសកកម្មរបស់យើងមិនមែនមកដើម្បីស្វែងរក តើនរណាគេភរកុហក ឬក៏មិនភរកុហកនោះទេ ។ គោលបំណងរបស់យើងដែលជាអ្នកជំនាញ គឺនិយាយអំពីតួនាទីរបស់គាត់ ហើយតួនាទីរបស់យើងវិញជាអ្នកជំនាញនោះ គឺយើងត្រូវពិនិត្យមើលជានិច្ចកាលនោះ យើងពិនិត្យមើល និងចាំជាក់នៅក្នុងចិត្តថា យើងមិនមែនស្ថិតនៅក្នុងដំណាក់កាលនៃការព្យាបាលចិត្តសាស្ត្រនោះទេ ប៉ុន្តែយើងធ្វើការនៅក្នុងគម្រោងការច្បាប់មួយ ហើយយើងពិនិត្យមើលទៅលើធាតុផ្សំផ្សេងៗ ដើម្បីធ្វើការកំណត់ថាតើមានការបំប្លែងការពិត ឬក៏យ៉ាងម៉េចនោះ? គឺថាគ្រប់ពេលទាំងអស់យើងមិនមានអារម្មណ៍ថា យើងត្រូវបានគេបំភាន់ ឬក៏បំភ្លៃនៅក្នុងការធ្វើរបាយការណ៍របស់យើងនោះទេ ពីព្រោះគឺថាពាក្យថា ការស្មោះត្រង់នេះ មិនមែនជាប្រធានបទមួយដែលយើងផ្ដោតអារម្មណ៍នោះទេ ។

**ស៖** បាទ, ចម្លើយរបស់លោក លោកស្រី ដែលបានផ្ដល់ទៅលើសំណួររបស់ខ្ញុំនេះ បណ្ដាលឲ្យទាក់ទងទៅដល់សំណួរមួយទៀត ថាតើលោក ឌុច ហ្នឹងគួរតែត្រូវបាននរណាម្នាក់ជំរុញចិត្តឬ ឬមួយក៏តើយើងគួរតែស្ដីបន្ទោសឲ្យគាត់ ដែលថាគាត់មិនបាននិយាយឲ្យបានពេញលេញ ឬក៏គ្រប់គ្រាន់នោះឬ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលហ្វូ)** គឺថាខ្ញុំមិនបដិសេធ អ្វីដែលលោកបានលើកឡើងទេ ក្នុងនាមយើងខ្ញុំជាអ្នកជំនាញ យើងមិនអាចធ្វើការស្ដីបន្ទោសទៅលើបុគ្គលណាម្នាក់នោះទេ បើពុំដូច្នេះទេគឺថា យើងស្ថិតនៅក្នុងគំនិតមួយ ថាពួកគេហ្នឹងជាជនអាក្រក់ ឬក៏ជាអ្នកដែលមាន ជាមនុស្សមានចិត្តទុច្ចរិត ឬក៏អាក្រក់ ហើយនោះគឺមិនមែនជាការយល់ដឹង ជាគតិរបស់យើងក្នុងការធ្វើការវិភាគផ្នែកចិត្តសាស្ត្ររបស់បុគ្គលណាម្នាក់នោះទេ ។ នៅពេលដែលយើងពិនិត្យមើលទៅលើ គោលជំហររបស់ជនរងគ្រោះនៅក្នុងប្រទេសណាមួយ គឺថាយើងបានកត់សម្គាល់ឃើញចំណុចដ៏ច្រើនទាក់ទងទៅនឹងកាលៈទេសៈអស់ទាំងនុ៎ង ។ ហើយក្នុងនាមយើងជាអ្នកជំនាញ គឺថាយើងមិនធ្វើការស្ដីបន្ទោស ឬក៏ជំរុញឲ្យជន ធ្វើការបង្ហាញនូវការសូមទោសនោះទេ ។ នោះគឺជាដំណើរការផ្លូវចិត្តរបស់ជនម្នាក់នោះ ហើយបុគ្គលម្នាក់ៗ គឺមានភាពខុសៗគ្នាអាស្រ័យទៅលើធាតុផ្សំនានានៃជីវិតរបស់គាត់ ទៅលើកុមារភាពរបស់គាត់ទៅលើបទពិសោធន៍ជីវិតរបស់គាត់ ហើយគឺថាមានភាពខុសៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ ព្រមទាំងពេលវេលាដែលពួកគាត់បានឆ្លងកាត់នោះ ។ ហើយយើងមិនអាចធ្វើការបន្ទច់បង្អាក់ ឬក៏ជំរុញឲ្យ

គាត់ធ្វើឲ្យបានលឿនជាងនោះទេ គឺមានន័យថា ក្នុងដំណាក់កាលនេះ យើងមិនអាចបង្ខំ ឬក៏បន្ទច់បង្អាក់ការគិត ឬក៏ដំណើរការរបស់ជនជាប់ចោទបានទេ ។

[០៩:៣៧:១៧]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំសូមបន្ថែមផងដែរថា ក្នុងនាមខ្លួនខ្ញុំជាអ្នករងគ្រោះនៃរបបនេះ ខ្ញុំមិនបានដាក់ចិត្តថា ខ្ញុំជាអ្នករងគ្រោះនៅពេលបំពេញបេសកកម្មនេះទេ ហើយខ្ញុំបានយកវិធីសាស្ត្រដែលមានលក្ខណៈអព្យាក្រឹត្យមកអនុវត្តបំពេញការងារ ទៅតាមអ្វីដែលសំណូមពររបស់អង្គជំនុំជម្រះនេះ ។ ហេតុដូច្នេះ អ្វីដែលយើងបានជម្រាបជូន គឺអ្វីដែលយើងធ្វើក្នុងក្របខ័ណ្ឌជាអ្នកអព្យាក្រឹត្យដោយមិនបានយកនូវគំនិតខ្លួន ការរងគ្រោះរបស់ខ្លួនមកលាយឡំទេ ។ ដូចដែលយើងបានស្បថ និងក៏ដូចដែលយើងបានបំពេញតួនាទីជាអ្នកជំនាញដែលអព្យាក្រឹត្យជាសាកល ។ សូមអរគុណ ។

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** ខ្ញុំចង់ជម្រាបប្រាប់លោក ហ្វ្រង់ស្វ័រ រូ ហើយនិងអង្គជំនុំជម្រះផងដែរថា ភាពខុសគ្នានៅក្នុងការសម្ភាសន៍ ជាមួយនឹងជនជាប់ចោទ រវាងខ្ញុំហើយនិងលោកដុកទ័រ កា ស៊ុនបូណាត នោះ គឺថាយើងបានជួបគាត់ជាច្រើនដង ហើយនិងជួបជាមួយអ្នកបកប្រែផងដែរ នៅក្នុងវគ្គទាំង១៣វគ្គ ដែលយើងបានជួបជាមួយជនជាប់ចោទនោះ ។ ហើយអ្នកបកប្រែ គឺជាអ្នកបកប្រែដែលបានស្បថស្បែរួចហើយ។ ហើយយើងបានពិភាក្សានៅក្នុងចំណោមពួកយើងផងដែរអំពីបញ្ហានៃការផ្ទេរពីបុគ្គលនោះមកដល់ពួកយើងតាមរយៈអ្នកបកប្រែ ។ នេះគឺចំណុចសំខាន់ណាស់សម្រាប់បុគ្គលមួយៗដើម្បីធ្វើកិច្ចការរបស់យើង ដោយឈរលើជំហរអព្យាក្រឹត្យ ដូចដែលសហសេវិករបស់ខ្ញុំបានលើកឡើងអម្បាញ់មិញនេះ ។

ដូច្នេះ ជាការចាប់ផ្ដើម គឺយើងបានធ្វើការចាប់ផ្ដើមការអនុវត្តបែបនេះជាមុន គឺយើងធ្វើការពិភាក្សាក្នុងចំណោមយើងទាំងបីនាក់ជាមុន ហើយបើសិនជាមានបញ្ហាអ្វីក្នុងដំណាក់កាលដំបូងនោះដែលខ្ញុំជាអ្នកជំនាញគោលក្នុងចំណោមពួកយើងខ្ញុំនេះ គឺខ្ញុំនឹងមិនចាប់ផ្ដើមដំណើរការធ្វើការវាយតម្លៃផ្នែក-ចិត្តសាស្ត្រនោះទេ គឺដើម្បីជៀសវាងឥទ្ធិពលផ្សេងៗដែលជាបញ្ហាផ្លូវចិត្តផ្ទាល់របស់យើង ឬក៏ការយល់ដឹងអំពីប្រវត្តិសាស្ត្ររបស់យើង ឬក៏ការយល់ដឹងជាសមូហភាពរបស់យើងដែលអាចធ្វើឲ្យប៉ះពាល់ដល់ការធ្វើរបាយការណ៍ផ្នែកចិត្តសាស្ត្ររបស់យើងនោះ ។

**ស៖** លោក លោកស្រី ក៏បាននិយាយផងដែរ នៅពេលដែលលោក លោកស្រី និយាយអំពីជនជាប់ចោទ គឺនិយាយអំពីភាពលំបាកដែលគាត់បានមាន និងដែលគាត់កំពុងតែមាននៅក្នុងការសម្ដែង

អារម្មណ៍របស់គាត់ចេញ ។ ក៏ប៉ុន្តែ នៅពេលដំណាលគ្នាផងនោះដែរ នៅក្នុងដំណើរការផ្នែកច្បាប់នេះ យ៉ាងហោចណាស់ក៏មានចំនួនពីរដងដែរ ដែលយើងបានឃើញជនជាប់ចោទមានភាពច្របូកច្របល់ក្នុងចិត្តហើយគាត់ចង់បញ្ចេញទឹកភ្នែករបស់គាត់ ។

[០៩:៤០:៤៨]

ហើយនៅក្នុងដំណាក់កាលមួយនោះទៀត គឺនៅពេលការសម្តែងឡើងវិញនៅជើងឯក គឺថាតាមពិតគឺថាគាត់បានស្ទើរតែដួលខ្លួនទៅហើយ នៅពេលដែលនិយាយអំពីកន្លែងដែលសាកសពរបស់កូនក្មេងត្រូវបានគេរកឃើញ ។ ហើយដំណាក់កាលទីពីរ នៅពេលដែលធ្វើការសម្តែងឡើងវិញ នៅទួលស្លែង គឺថាគាត់បានយំ នៅលើស្មារបស់អ្នកយាមម្នាក់ ហើយគាត់បានយំ ហើយសុំខមាលទោសពីជនរងគ្រោះទាំងអស់នោះ ។ ហើយនៅពេលមួយទៀត នៅក្រោយមកទៀតក៏គាត់បានសម្តែងនូវអារម្មណ៍បែបនេះដែរ ។ បាទនៅលើកទីបី គឺនៅក្នុងនិងនៅចំពោះមុខអង្គជំនុំជម្រះនេះ នៅពេលដែលគាត់និយាយអំពីជនរងគ្រោះម្នាក់ គឺលោក ភីង តុន នៅស-២១ នោះ នៅពេលដែលប្រពន្ធរបស់គាត់ដែលជាស្ត្រីមេម៉ាយហើយនិងកូនក្តីរបស់គាត់មានវត្តមាននៅក្នុងអង្គសវនាការ គឺថាគាត់មានការពិបាកចិត្តនៅពេលដែលគាត់បានឮឈ្មោះនោះភ្លាម គឺថាគាត់បានបញ្ចេញទឹកភ្នែកតែម្តង នៅពេលដែលនិយាយអំពីឈ្មោះលោក ភីង តុន នោះ ។ ដូច្នេះខ្ញុំចង់សួរទៅលោក លោកស្រី ជាអ្នកជំនាញថាតើធ្វើការវិភាគយ៉ាងម៉េចដែរនៅពេលដែលយើងរៀបរាប់អំពីជនម្នាក់ ដែលតែងតែលាក់កំបាំងនូវអារម្មណ៍របស់គាត់ ក៏ប៉ុន្តែនៅពេលដំណាលគ្នានោះដែរ ម្តងហើយម្តងទៀត គាត់បានធ្វើឲ្យអារម្មណ៍របស់គាត់នោះសម្តែងចេញមកក្រៅដោយគាត់មិនអាចត្រួតពិនិត្យបាន គឺថាគាត់បើកចំហឲ្យអារម្មណ៍នោះបានចេញមកក្រៅ តើនេះគឺជាផ្នែកមួយនៃដំណាក់កាល ដែលថាគាត់បានឆ្លងកាត់នោះឬ? ខ្ញុំចង់បានចម្លើយនេះជាក់ច្បាស់ពីលោក លោកស្រី ។

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលប្ញ)** ចាស, នេះគឺជាផ្នែកមួយនៃដំណើរការ ។ ម្យ៉ាលមិញ យើងបាននិយាយអំពីយន្តការនៃការអល់អែកទទួលយក ឬក៏មិនទទួលយកការពិត ។ នៅក្នុងការបែងចែកឲ្យបានច្បាស់លាស់អំពីអារម្មណ៍របស់គាត់ ពីផ្នែកមួយទៀតដែលជាខ្លួនរបស់គាត់ផ្ទាល់ ។ មានន័យថាអារម្មណ៍របស់គាត់ ដែលគាត់បានគៀបសង្កត់ទុកជាយូរមកហើយនោះ ប៉ុន្តែគឺថាគាត់មិនអាចសង្កត់អារម្មណ៍ឲ្យបានអស់មួយជីវិតរបស់គាត់បាននោះទេ ។ នៅក្នុងដំណាក់កាលណាមួយនោះ គឺនឹងអាចត្រូវសម្តែងចេញ ហើយនេះគឺជាជំនាញរបស់យើង ដែលជាអ្នកពិនិត្យមើលទៅលើផ្នែកចិត្តសាស្ត្ររបស់គាត់នោះ។

ហើយទាក់ទងទៅនឹងការព្យាបាលផ្នែកចិត្តសាស្ត្រនោះ គឺគេធ្វើយ៉ាងម៉េច ដើម្បីធ្វើការបើកចំហឲ្យអារម្មណ៍នោះបានចេញ ដើម្បីធ្វើឲ្យគាត់ពិនិត្យឲ្យបានច្បាស់លាស់ ថាអ្វីទៅថាជាពិត និងឬអ្វីទៅដែលមិនមែនជាការពិតនោះ ។ គឺមានន័យថា នៅម្ខាងគឺជាអារម្មណ៍របស់គាត់ ម្ខាងទៀតគឺជាការយំរបស់គាត់ដែលជាការបង្ហាញនូវការពិតដែលថា គាត់មានអារម្មណ៍មួយដែលជួនកាលមិនអាចទទួលបាន ឬក៏ទទួលបាននូវការពិត ។ ហើយនេះគឺជាតួនាទីផ្នែកចិត្តសាស្ត្រមួយ ហើយបើសិនជាយើងចង់ធ្វើការវិភាគឲ្យបានវែងឆ្ងាយជាងទៀតនោះ គឺអាចមានស្ថានភាពផ្សេងៗទៀត ដែលបណ្តាលឲ្យគាត់មានអារម្មណ៍បែបនេះនៅក្នុងចំណោមជនជាប់ចោទដទៃៗទៀត ។

[០៩:៥៤:១០]

ប្រហែលជានៅពេលដែលគាត់ប្រឈមមុខនៅជាមួយបុគ្គលណាម្នាក់ដែលគោរពគាត់ ។ គឺថាការដកចេញអំពីអារម្មណ៍ដែលទទួលយក ឬក៏មិនទទួលយកបាននូវការពិតនោះ គឺជាផ្នែកមួយនៃដំណើរការ គឺថាអ្វីទៅដែលអាចធ្វើឲ្យប៉ះពាល់អារម្មណ៍របស់គាត់ ប៉ះពាល់ដល់ការគោរពរបស់គាត់ជាពិសេសទាក់ទងទៅនឹងលោកគ្រូ ភឹង តុន នេះជាដើម ។ ពេលនុ៎ង គឺថាគាត់មិនអាចបង្ហាញ ឬក៏សម្តែងនូវការពិតបាន ឬក៏យ៉ាងម៉េចនោះ ។ ហើយការយំ ការបញ្ចេញទឹកភ្នែកនៅពេលដំណាក់កាលមួយជាក់លាក់នេះ ក៏វាមានភាពស្រដៀងគ្នានេះដែរនៅពេលដែលមានវត្តមានរបស់លោក ប៊ូ ម៉េង ហើយគាត់ជនជាប់ចោទហ្នឹង ស្គាល់លោក ប៊ូ ម៉េង ។ ហើយជាមនុស្សដែលថាឥឡូវនេះមើលទៅដូចជាចាស់ណាស់ តាមពិតអាយុប្រហាក់ប្រហែលគ្នានោះក៏ដោយ ។ មានន័យថា បើនិយាយពីរាងកាយគឺថាមានភាពខុសគ្នានៅពេលដែលគាត់ឃើញ ។ បើនិយាយពីរាងកាយគឺមានភាពខុសគ្នា នៅពេលគាត់ ឃើញដូច្នេះគឺអារម្មណ៍គាត់វាមានភាពរំជើបរំជួល ។ ហើយបើយើងយោងទៅតាមឧទាហរណ៍នោះ មានន័យថាការទទួលបាន ឬក៏មិនទទួលយកបានការពិតនោះ គឺមិនមែនជាការមួយកំណត់ឲ្យបានជាក់លាក់ថាទទួលយកទាំងស្រុង ឬក៏អាចទទួលយកបានទាំងស្រុងនោះទេ គឺថាមិនអាចកំណត់ឲ្យបានច្បាស់លាស់ដូច្នេះទេ ។

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** បើនិយាយដោយងាយស្រួលតាមបែបខ្មែរដែលជាប្រពៃណីមួយទំនៀមទម្លាប់មួយដែលច្រើនតែនិយាយដោយសម្តែងទៅលើតែ ដោយសង្កត់ទៅលើអ្វីដែលជាអាកប្បកិរិយា ជាជាងទៅលើយន្តការផ្លូវចិត្ត គឺម្នាក់ៗអាចនឹងទប់អារម្មណ៍មិនឲ្យសម្តែងចេញមកក្រៅបាន ។ ប៉ុន្តែ ក្រសែភ្នែកមិនអាចភូតកុហកបានទេជាទូទៅ ។ ក្នុងករណីដែលលោក ឌុច បានសម្រក់ទឹកភ្នែក

ជាពិសេសក្នុងករណីដែលបានឮសួរឈ្មោះលោក ភឹង តុន ហើយគាត់បានស្រក់ទឹកភ្នែកនេះគាត់ក៏បានរៀបរាប់ផងដែរថា គាត់សោកស្តាយណាស់ ពីព្រោះអីលោក ភឹង តុន ជាគ្រូរបស់គាត់ ។ អ៊ីចឹងពាក្យថា គ្រូមួយម៉ាត់ចំពោះគាត់ គឺជាអ្នកដែលគួរគោរពដែលគាត់ស្រលាញ់ ។ ដូច្នេះពាក្យឈ្មោះរបស់លោក ភឹង តុន នេះបានធ្វើឱ្យអារម្មណ៍របស់គាត់ កញ្ជ្រោលខ្លាំងដែលហួសពីសមត្ថភាពទប់សង្កត់របស់គាត់បាន ។ ហេតុដូច្នេះហើយបានជានៅក្នុងប្រពៃណីខ្មែរយើង គឺតែងតែសួរនាំមនុស្សអំពីបញ្ហាធូរស្រាលទៅបញ្ហាតានតឹងដើម្បីពិនិត្យមើលឥរិយាបថ ក្រសែភ្នែក និងជាពិសេសទឹកភ្នែក ។ បើសិនជាសំណួរនោះវាមានឥទ្ធិពលលើសលប់ទៅលើអ្វីដែលជាសមត្ថភាពទប់ទល់ ឬក៏សង្កត់មិនឱ្យមានការបញ្ចេញមកក្រៅនូវអារម្មណ៍ គេអាចនឹងស្រាវជ្រាវរកឃើញភស្តុតាងតទៅទៀត ។ នេះជាការអនុវត្តរបស់ខ្មែរយើងដែលមានការចង់ដឹងអំពីដំណើរការផ្លូវចិត្ត ។ សូមអរគុណ ។

**ស៖** សូមអរគុណលោក លោកស្រី ដែលបានផ្តល់ឱ្យយើងអំពីគោលជំហរនៃប្រពៃណីរបស់ខ្មែរឱ្យពួកយើងខ្ញុំបានស្តាប់ ។ នៅពេលដំណាលគ្នានោះដែរយើងក៏បានមើលឃើញនៅក្នុងដំណាក់កាលនៃការជំនុំជម្រះនេះ អំពីការយំរបស់ជនរងគ្រោះដែលពួកគាត់មានអារម្មណ៍ថា ឌុច ហ្នឹងមិនបានធ្វើឱ្យបានគ្រប់គ្រាន់ទេ ។ នៅក្នុងរបាយការណ៍របស់លោក លោកស្រី លោកបានរំឭកថា ពួកលោកទាំងពីរបានប្រើពាក្យមួយទាក់ទងទៅនឹងរបបមួយ ដែលជារបបមួយដែលតែងតែមានការភ័យខ្លាចនោះ ខ្ញុំមិនដឹងថាជានៅទំព័រណាទេ ដែលថាជនរងគ្រោះគឺថា មិនអាចទទួលបាននូវចម្លើយទាំងអស់អំពីអ្វីដែលបានកើតឡើងនៅក្នុងរបបនោះពីព្រោះអី ឌុច គាត់មិនអាចមានចម្លើយទាំងអស់នោះទេ ។ តើលោក លោកស្រីអាចប្រាប់យើងបានទេថា ក្នុងនាមជាអ្នកជំនាញតើលោកអាចនិយាយថា អារម្មណ៍នៃការភ័យខ្លាចដែលកើតមាននៅក្នុងរបបនោះវាយ៉ាងម៉េចដែរ? នៅថ្ងៃនេះ តើមាននរណាម្នាក់អាចផ្តល់និយមន័យទៅលើអ្វីដែលបានកើតឡើងនៅក្នុងរបបនោះដែរឬទេ? តើវាមានន័យទេក្នុងការបង្ហាញអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបនោះ ឬមួយក៏មានន័យថាយើងត្រូវតែឆ្លងកាត់នូវពាក្យពេចន៍ដែលថាមានអារម្មណ៍ដែលធ្វើឱ្យមានការភ័យខ្លាចនោះ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលបូ)** នេះគឺជាសំណួរមួយដ៏សំខាន់ ។ ដំបូង គឺថាពួកយើងមិនមែនជាប្រវត្តិវិទូទេ ហើយយើងក៏មិនអាចនិយាយអំពីរបបនោះបានដែរ។ ក៏ប៉ុន្តែទាក់ទងទៅនឹងវិធីសាស្ត្រដែលយើងបានធ្វើទាក់ទងទៅនឹងប្រវត្តិសាស្ត្រ ហើយនិងនយោបាយយើងបានដឹងថា នៅក្នុងប្រទេសមួយដែលទទួលរងនូវអារម្មណ៍នៃការភ័យខ្លាចនោះ ហើយគឺមានតែអ្នកដឹកនាំទេដែលមានអារម្មណ៍បែបនោះ។

ហើយបើសិនជាយើងចង់ធ្វើវោគវិច្ឆ័យទៅលើចំណុចនេះ គឺយើងពិនិត្យមើលទៅលើនិយមន័យនៃពាក្យថា អារម្មណ៍នៃការភ័យខ្លាច ឬក៏ *ផារ៉ាណាយ* នោះ ។ ហើយពេលនេះគឺថាពិនិត្យ មើលអំពីស្ថានភាពរបស់សត្រូវ និងអ្វីដែលយើងធ្វើដើម្បីធ្វើការការពារខ្លួនពីសត្រូវទាំងនោះ គឺថាមិនមានអ្វីមួយដែលធ្វើឲ្យអ្នកមានអារម្មណ៍ *ផារ៉ាណាយ* ហ្នឹងមានការពេញចិត្តស្ងប់អារម្មណ៍បានទេ ។ ហើយទាក់ទងទៅនឹងជនជាប់ចោទ គឺវាមិនត្រឹមតែទាក់ទងគាត់ទេ វាអាចទាក់ទងដល់ប្រទេសទាំងមូលតែម្ដង ជាពិសេសគឺបន្តិចម្ដងៗប្រទេសទាំងមូល និងកិច្ចការទាំងឡាយគឺត្រូវបានប្រណិប័តន៍ការឡើង ដោយបុគ្គលនីមួយៗ ហើយការផ្លាស់ប្ដូរផ្នែកផ្លូវចិត្តរបស់បុគ្គលម្នាក់ៗ ក៏មានការផ្លាស់ប្ដូរទៅតាមរបបនៃការគ្រប់គ្រងនោះដែរ ។ ហើយមានន័យថាបន្ទាប់មកទៀតនោះគឺថា ទាំងការគិតនិងដំណើរការនៅក្នុងរបបនោះគឺបានធ្វើការស្របគ្នា ។ ហើយមានន័យថាប្រជាជនហ្នឹងគាត់ហ្នឹងមានអារម្មណ៍ *ផារ៉ាណាយ* នោះទេ ។ ប៉ុន្តែពួកគេត្រូវធ្វើការសម្របសម្រួលខ្លួនរបស់ពួកគេទៅតាមយន្តការចិត្តសាស្ត្រមួយ ដើម្បីអាចរស់រានមានជីវិតបាន នៅក្នុងដំណាក់កាលនៃរបបបែបនេះ ។ មានន័យថា ត្រូវដាក់ខ្លួនឲ្យចូលរួមនៅក្នុងសង្គមនោះបាន អាចធ្វើការកំណត់ទៅលើការទទួលយក ឬក៏មិនទទួលយកបាននូវការពិត ឬមួយក៏ថា ខំធ្វើការជ្រុលខ្លាំងពេក ឬក៏ធ្វើយ៉ាងម៉េចដើម្បីឲ្យខ្លួនអាចរស់រានមានជីវិតបាន ។

ដូច្នេះ ជាសង្ខេប គឺមានចិត្តសាស្ត្រមួយអំពីមនុស្សម្នាក់ដែលរស់នៅក្នុងប្រទេសមួយដែលស្ថិតនៅក្នុងរបបផ្ដាច់ការ ហើយដូច្នេះចិត្តសាស្ត្ររបស់គាត់ហ្នឹង គឺមិនដូចគ្នាទៅនឹងចិត្តសាស្ត្ររបស់បុគ្គលម្នាក់ដែលរស់នៅក្នុងរបបធិបតេយ្យនោះទេ ។ តើលោក ស៊ុនបូណាត ចង់បន្ថែមអ្វីទៀតទេ ?

[០៩:៥៣:១៣]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំចង់ជម្រាបជូនផងដែរ នូវអ្វីដែលលោកបានលើកឡើងថា គំនិតមិនទុកចិត្ត ឬក៏សង្ស័យអ្នកដទៃនេះ ដែលជាភាសាបារាំងហៅថា *ផារ៉ាណាយយ៉ាត* ។ ជាការពិតណាស់នៅពេលដែលខ្ញុំឈានចូលដំបូងទៅដល់ដែនដីរំដោះ ដែលជាដែនដីត្រួតត្រាដោយអ្នកដឹកនាំខ្មែរក្រហម យើងមានអារម្មណ៍មួយហាក់ដូចជាអ្នកដែលជាខ្មែរក្រហម ឬក៏ជាជនកុម្មុយនីស្តទាំងនោះ ហើយនិងក្រុមពួកយើង ដែលបានជម្លៀសទៅនៅនោះ ជាមនុស្សក្នុងភពមិនដូចគ្នា ។ យើងហាក់ដូចជាមានការទុកចិត្ត និងជឿជាក់ទៅលើអ្វីដែលគេបានរៀបរាប់ប្រាប់ ឲ្យយើងបានថ្លឹងថ្លែងពិចារណា ។ តែអ្នកដែលជា...

**ប្រធានអង្គជំនុំ៖**

យ៉ាងម៉េចទៅលោកតំណាងសហព្រះរាជអាជ្ញា?

**លោក អានីស អះមេដ៖**

លោកប្រធានតាមពិតខ្ញុំមិនចង់ឡើងមករំខានទេ ដូចដែលខ្ញុំបាននិយាយអ៊ីចឹងជាពិសេសទាក់ទងទៅនឹងសក្ខីកម្មរបស់អ្នកជំនាញ ។ ក៏ប៉ុន្តែ ខ្ញុំចង់ស្នើឡើងថា សុំឲ្យលោកប្រធាន សូមឲ្យលោកអ្នកជំនាញជាពិសេសគឺអ្នកជំនាញកម្ពុជានេះ កុំឲ្យគាត់ធ្វើការអង្កេតពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ទាក់ ទងទៅនឹងរបបខ្មែរក្រហមនោះ ។ គាត់ថាគាត់ជាជនរងគ្រោះម្នាក់ ប៉ុន្តែនៅពេលដែលគាត់ផ្តល់នៅក្នុងសក្ខីកម្មរបស់គាត់ហ្នឹងមិនមានអ្វីទាក់ទងទៅនឹងបទពិសោធន៍របស់ជនរងគ្រោះទេ នេះគឺជាបទពិសោធន៍ ជាអត្តនោម័តរបស់គាត់ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អរគុណចំពោះការកត់សម្គាល់របស់លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដែលបានលើកឡើងពីបញ្ហានេះ ។ អង្គជំនុំជម្រះសូមរំឮកដល់អ្នកជំនាញថា អ្នកជំនាញនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មនេះមិនគប្បីលើកអំពីហេតុផលទាំងឡាយដែលជារឿងបុគ្គលផ្ទាល់ខ្លួនរបស់លោកទេ ទាំងពាក្យថា ជាជនរងគ្រោះ ទាំងអ្វីដែលកើតឡើងសម្រាប់បុគ្គលរបស់លោក គឺមិនគប្បីលើកឡើងនៅក្នុងអំឡុងពេលដែលលោកធ្វើសក្ខីកម្ម ធ្វើរបាយការណ៍ក្នុងនាមអ្នកជំនាញទេ ដើម្បីចៀសឲ្យផុតពីថាអ្វីដែលជាយកការដឹងផ្ទាល់ខ្លួនមកបង្ហាញ ។ អង្គជំនុំជម្រះសង្ឃឹមថា លោកនឹងអាចយល់អំពីបញ្ហានេះ ។

[០៩:៥៦:២០]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** សូមអរគុណ ។ យោងទៅតាមអ្វីដែលយើងបានសិក្សាផងដែរ បានមើលអត្ថបទ បានមើលឯកសារគឺក្នុងរបបប៉ុលពត គេបានលើកពាក្យស្លោកថា “ប្រុងប្រយ័ត្នខ្ពស់ មិនសន្តិភាពនិយម មិនស្តាប់ស្តល់និយម ដែលជាទិសដៅជាទូទៅក្នុងរបបកុម្មុយនីស្តរបស់ខ្មែរក្រហម មិនត្រូវទុកចិត្តអ្នកដទៃ” នេះជាគោលការណ៍របស់របបខ្មែរក្រហម ដែលបង្កើតឲ្យមានជាគំនិតមិនទុកចិត្តគេឯង ឬក៏សង្ស័យគេជាប្រចាំ។ បានសេចក្តីថាជាផ្នត់គំនិតមួយដែលត្រូវបានបណ្តុះទៅលើជនកុម្មុយនីស្តតាមបែបខ្មែរក្រហម ទើបបានបង្កើតទៅជាបរិយាកាសមួយមិនទុកចិត្ត និងសង្ស័យគេជាប្រចាំ ។ សូមអរគុណ ។

**ស៖** សូមអរគុណលោក ខ្ញុំនៅសល់សំណួរចំនួនពីរទៀត ។ ជាបឋមបន្ទាប់ពីការលើកឡើងប្រតិកម្ម របស់លោកទៅនឹងរបបខ្មែរក្រហម ។ នៅពេលដែល ឌុច គាត់បានជម្រាបជូនសហចៅក្រមស៊ើបអង្កេត ហើយគាត់ថា គាត់ជាចំណាប់ខ្មាំងនៃរបបនោះ ថាតើវាស៊ីគ្នាទៅនឹងអ្វីដែលលោកទើបតែបានរៀបរាប់ដែរឬទេ ក្នុងស្ថានភាពផ្ទាល់ខ្លួនរបស់គាត់ គាត់ជាតួអង្គមួយ ហើយក៏ជាចំណាប់ខ្មាំងមួយដែរនៅក្នុងរបបនុ៎ង?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ចំពោះពាក្យដែលលោកបានសួរថាលោក ឌុច បានរៀបរាប់ថាគាត់ ជាចំណាប់ខ្មាំងក្នុងរបបនោះ នេះជាទស្សនៈរបស់លោក ឌុច ប៉ុន្តែដើម្បីស្វែងយល់ឲ្យអស់លុះត្រាតែក្រុមយើងនេះ ធ្វើការងារស្រាវជ្រាវសំដៅស្វែងយល់ឲ្យឃើញថា គាត់ជាមនុស្សមួយស្ថិតក្នុងភាពចំណាប់ខ្មាំងឬអត់? តែគោលបំណងនៃការដែលយើងធ្វើការស្រាវជ្រាវជំនាញ មិនមានផ្តោតទៅលើការស្រាវជ្រាវ ឲ្យឃើញថាគាត់ជាចំណាប់ខ្មាំងឬក៏អត់ទេបាទ ។ ហេតុដូច្នេះ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំអត់អាចឆ្លើយសំណួររបស់លោកបាន ។

[១០:០០:០០]

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូល)** ខ្ញុំសូមធ្វើការបន្ថែមយល់នៅត្រង់ចំណុចនេះ អ្នកដែលជាចារីឬក៏ជាតួអង្គ គឺជាការវាយតំលៃផ្សេងៗ ដែលយើងធ្វើឡើងចំពោះជនជាប់ចោទ ។ យើងដឹងហើយថាតួអង្គ ឬក៏ចារីនោះ គឺយ៉ាងម៉េចនោះទេ? ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់អំពីពាក្យថា “ចំណាប់ខ្មាំង” នោះទេ ។ ខ្ញុំអាចវិភាគទៅលើការងារ ឬដំណើរការនោះបាន ។ តួនាទីពីរនេះ គឺវាមានលក្ខណៈខុសគ្នាហើយខ្ញុំមិនដឹងថាគាត់ប្រើពាក្យ ចំណាប់ខ្មាំងនេះក្នុងស្ថានភាពណា ។ គាត់បានទទួលស្គាល់ថា គាត់ជាតួអង្គមួយរូបនៅក្នុងរបបហ្នឹង ហើយគាត់ស្ថិតនៅក្នុងស្ថានមួយដែលគាត់មិនអាចដកខ្លួនរបស់គាត់ ឬក៏ដកជើងចេញពីដំណើរការយន្តការរបបនោះ។ ហើយសហសេវិករបស់ខ្ញុំប្រើពាក្យថា ទាក់ទងទៅនឹងដំណើរការការងារ ហើយជនជាប់ចោទក៏បានពន្យល់ជូនយើងខ្ញុំ ថាគាត់នៅក្នុងស្ថានភាពពីរនុ៎ង ទោះបីជាយើងមិនបានទទួលចាត់ឲ្យសួរសំណួរនេះជាក់លាក់ចំពោះចំណុចហ្នឹងក៏ដោយ ប៉ុន្តែយើងអាចបញ្ជាក់ដូច្នេះ ។

**ស៖** សូមអរគុណច្រើន ។ នេះគឺជាសំណួរចុងក្រោយរបស់ខ្ញុំ លោក លោកស្រី អ្នកជំនាញបានលើកឡើងថា មនុស្សទាំងឡាយមិនមែនកើតឡើងជាអ្នកធ្វើទារុណកម្មនោះទេ ។ មនុស្សនឹងក្លាយទៅជាអ្នកធ្វើទារុណកម្ម ។ ដូច្នេះ ខ្ញុំសួរថា តើយើងអាចក្លាយទៅជាមនុស្សធម្មតាឡើងវិញដែរឬទេ? លោក លោកស្រី បានលើកឡើងថាឃាតក គឺមានត្រូវតែធ្វើឲ្យមានលក្ខណៈអមនុស្សធម៍ខ្លួនឯងសិន មុនពេល

ដែលគាត់ធ្វើឲ្យមានភាពអមនុស្សធម៌ចំពោះជនរងគ្រោះ ។ ដូច្នេះហើយ ថាតើជនជាប់ចោទ គាត់អាចធ្វើឲ្យគាត់ស្ថិតនៅក្នុងស្ថានភាពជាមនុស្សធម្មតាឡើងវិញដែរឬទេ? ដូចដែលអ្វីដែលលោក លោកស្រីបានលើកឡើងទាក់ទងទៅនឹងការស្តាលទ្ធភាពពលកម្មនិងសម្បទារបស់គាត់ និងការដាក់ចូលទៅក្នុងសង្គមឡើងវិញ ។

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលប៊ូល)**ជាការពិត យើងខ្ញុំអាចឆ្លើយតបទៅនឹងសំណួរនេះបានបញ្ជាក់ថា ពិតជាបានមែន ។ ប្រសិនបើ យើងពិនិត្យមើលធាតុផ្សំទាំងឡាយដែលយើងបានធ្វើកោសល្យវិច័យទាក់ទងទៅនឹងអំពីបុគ្គលិកលក្ខណៈរបស់គាត់ ទាក់ទងទៅនឹងការបង្កើតអត្តសញ្ញាណសមូហភាពដែលបង្កើតឡើងចំពោះជនជាប់ចោទ ហើយធ្វើការវិភាគទៅលើចិត្តសាស្ត្ររបស់ជនជាប់ចោទ តាំងពីការចាប់ផ្តើមដំណើរការក្តីនេះពីដំបូងមកគឺខ្ញុំសូមឆ្លើយថា ពិតជាអាចស្តារលទ្ធភាពពលកម្មឡើងវិញ ។ មនុស្សមិនមែនកើតជាអ្នកធ្វើទារុណកម្មនោះទេ គាត់នឹងក្លាយទៅជាអ្នកធ្វើទារុណកម្ម ហើយយើងអាចកែប្រែឲ្យជាស្ថានភាពមនុស្សធម្មតាឡើងវិញ ។ វិធីសាស្ត្រផ្សេងៗ គឺត្រូវធ្វើឡើងនៅក្នុងការកែប្រែ ឬក៏ពិចារ-ណាទៅលើស្ថានភាពនេះ ។

ខ្ញុំសូមបញ្ជាក់ដោយខ្លីៗ លោកបានសួរទាក់ទងទៅនឹងជនជាប់ចោទ ខ្ញុំក៏សូមបញ្ជាក់ផងដែរថាមនុស្សមួយចំនួននៅក្នុងទូទៅទាំងពិភពលោក គឺគាត់ដែលមកធ្វើការទទួលការគាំទ្រចិត្តសាស្ត្រដោយសារបញ្ហាហិង្សាសមូហភាពនោះ មិនថាគាត់ជាអ្នកប្រព្រឹត្ត គាត់ទទួលបញ្ហា ឬក៏គាត់រងគ្រោះ ។ ជាទូទៅនៅក្នុងការគាំទ្រចិត្តសាស្ត្ររបស់យើងខ្ញុំ យើងអាចពិនិត្យឃើញថាវាមានលទ្ធភាព យើងកត់សម្គាល់ឃើញថា វាលទ្ធភាពក្នុងការកែប្រែ និងផ្លាស់ប្តូរចំពោះបុគ្គលគ្រប់គ្នា ហើយក៏ជនជាប់ចោទ ក៏គាត់មានលទ្ធភាពទទួលបាននូវការកែប្រែ និងស្ថានភាពមនុស្សឡើងវិញផងដែរ ។

[១០:០៥:២៨]

**ស៖** ដូច្នេះ ខ្ញុំអាចប៉ានសួរសំណួរទៅកាន់លោកស្រី ទាក់ទងទៅនឹងការគិតពិចារណា លោកស្រី បានលើកឡើងថាឃាតក គាត់ត្រូវតែមានលក្ខណៈអមនុស្សធម៌ក្នុងខ្លួនសិន មុនពេលដែលគាត់ដកភាពអមនុស្សធម៌ទៅលើជនរងគ្រោះ ។ ដូច្នេះ តើលោកស្រីយល់ស្រប ក្នុងការលើកឡើងដែរឬទេ? ថាឃាតករអាចមានស្ថានភាពជាមនុស្សធម្មតាឡើងវិញ ហើយក៏អាចផ្តល់លក្ខណៈមនុស្សធម៌នោះ ទៅដល់ជនរងគ្រោះឡើងវិញផងដែរ ។

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហៀលបូល)** ខ្ញុំអាចនិយាយថា ការផ្តល់ស្ថានភាពមនុស្សធម៌ដល់ឃាតកឡើងវិញ គឺជាយន្តការចាំបាច់មួយ ហើយវាជាយន្តការសំខាន់និងធាតុមួយសំខាន់ ជាការពិត ។ ការផ្តល់ស្ថានភាពដល់ជនរងគ្រោះឡើងវិញ ដែលគាត់ទទួលរងភាពអមនុស្សធម៌ពីឃាតករនោះ គឺជាដំណើរការមួយផងដែរសម្រាប់ជនរងគ្រោះ ។ ដោយសារតែវាមានភាពពាក់ព័ន្ធទៅនឹងការឈឺចាប់ ហើយភាពអមនុស្សធម៌វាកើតមាន ។ ហើយពេលខ្លះទៅ វាមិនអាចកើតមានចំពោះឃាតករនោះទេ ដោយសារតែគាត់ស្ថិតនៅក្នុងស្ថានភាពមួយចំនួន ប៉ុន្តែយ៉ាងណាក៏ដោយ គឺយើងអាចឆ្លើយតប ហើយជម្រាបថា ដោយសារតែខ្ញុំមានបទពិសោធន៍ម្ភៃឆ្នាំជាមួយនឹងជនរងគ្រោះពីរបបប្រល័យពូជសាសន៍ឬក៏របបផ្សេងៗ គឺថាជនរងគ្រោះ វាអាចទទួលបានស្ថានភាពនេះឡើងវិញ ។ ប្រសិនបើមានបញ្ហានិទណ្ឌភាពនៅក្នុងប្រទេស ឬក៏អ្នកដែលជាចារីមិនទទួលស្គាល់ទៅលើសកម្មភាពនោះទេ អ៊ីចឹងវាជាភាពចាំបាច់ដែលមានលក្ខណៈលំបាកក្នុងការឲ្យជនរងគ្រោះគាត់ទទួលបាននូវអារម្មណ៍ធូរស្រាលឡើងវិញ ចំពោះការឈឺចាប់និងការកើតឡើងចំពោះគាត់ ។ ដូច្នេះហើយ វាទាក់ទងទៅនឹងបញ្ហានៃប្រទេសមួយ ដែលវាជាក្របខ័ណ្ឌនៃការពិចារណាផងដែរ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ខ្ញុំពុំមានសំណួរបន្ថែមទៀតទេ ហើយខ្ញុំសូមសម្តែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកជំនាញទាំងពីររូប ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះផ្តល់ឱកាសដល់ជនជាប់ចោទ ដើម្បីការកត់សម្គាល់នូវសេចក្តីការណ៍របស់អ្នកជំនាញទាំងពីររូបដែលបានធ្វើកាលពីម្សិលមិញ ហើយនិងអម្បាញ់មិញនេះ ។ សូមអញ្ជើញ ។

[១០:០៧:៥៨]

**ជនជាប់ចោទ៖**

សូមគោរពលោកប្រធាន! ខ្ញុំសូមអរគុណ លោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំមានមតិ ។ តាមរយៈលោកប្រធាន ខ្ញុំសូមអរគុណដល់អ្នកជំនាញទាំងពីរ ដែលបានជួយខ្ញុំឲ្យយល់បញ្ហាជាជម្រៅខាងចិត្តសាស្ត្រ សភាពការណ៍ផ្លូវចិត្តរបស់ខ្ញុំច្រើន ។ ទន្ទឹមនេះ ខ្ញុំពិតជាមានបំណងចង់មនុស្សជាតិទាំងមូលលោកអាចទទួលស្គាល់ខ្ញុំជាមនុស្សម្នានឹងគេតទៅទៀត នេះជាបំណងដ៏ខ្លាំងក្លារបស់ខ្ញុំ ។ ដែលរំពឹងថា

លោកសាស្ត្រាចារ្យជាអ្នកជំនាញទាំងពីរនឹងជួយខ្ញុំតទៅទៀត តាមការអនុញ្ញាតរបស់អង្គជំនុំជម្រះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោក លោកស្រី អ្នកជំនាញ អង្គជំនុំជម្រះអរគុណចំពោះលោកស្រី លោក ដែលអញ្ជើញមកធ្វើសេចក្តីថ្លែងការណ៍ ធ្វើរបាយការណ៍បង្ហាញអំពីចិត្តសាស្ត្ររបស់ជនជាប់ចោទ និងឆ្លើយទឹងសំណួរពាក់ព័ន្ធទៅនឹងចិត្តសាស្ត្ររបស់ជនជាប់ចោទនេះ ពីសំណាក់អង្គជំនុំជម្រះ និងភាគី ហើយការកត់សម្គាល់នូវសំណួរចម្លើយទាំងនោះ គឺពោរពេញទៅដោយភាពស្មុគស្មាញនិងលំបាក ប៉ុន្តែអង្គជំនុំជម្រះកត់សម្គាល់ឃើញថា អ្នកជំនាញមានការតស៊ូអត់ធ្មត់ ហើយខិតខំអស់ពីលទ្ធភាពក្នុងការឆ្លើយតបទៅនឹងសំណួរ ហើយរហូតដល់ពេលនេះដល់ទីបញ្ចប់ហើយ ។

ហើយដូច្នេះ គឺដំណើរការនៃការស្តាប់សេចក្តីថ្លែងការណ៍របស់អ្នកជំនាញឃើញថាចប់ហើយ។ លោក លោកស្រី អាចវិលត្រឡប់ទៅកាន់ទីកន្លែង ឬក៏គោលដៅដែលអស់លោក លោកស្រី ចង់ទៅបានហើយ ។ ហើយដោយសារដំណើរការបន្តទៀត គឺត្រូវដំណើរការសវនាការមួយម៉ោងកន្លះ ដើម្បីកុំឲ្យវាបញ្ហា អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការស្តាប់សាក្សី បញ្ជាក់អំពីអត្តចរិតជនជាប់ចោទ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:១១ នាទីដល់ម៉ោង ១០:៣២ នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ មន្ត្រីតុលាការអញ្ជើញសាក្សី ស៊ូ សាត ចូលមកកាន់សាលសវនាការ ។

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន ។ កាលពីព្រឹកម្សិលមិញ ខាងមេធាវីការពារក្តីបានលើកឡើងនូវសំណូមពរមួយចំនួនទាក់ទងទៅនឹងសាក្សីដែលនឹងផ្តល់សក្ខីកម្ម ហើយជាសាក្សីដែលបានស្នើឡើងដោយខាងមេធាវីការពារក្តី ។ ខ្ញុំចង់សូមលោកប្រធាន អនុញ្ញាតឲ្យខ្ញុំធ្វើការសម្តែងមតិយោបល់តបមួយចំនួនទាក់ទងទៅនឹងការលើកឡើងរបស់មេធាវីការពារក្តីនេះ ។

**ប្រធានអង្គជំនុំ៖**

ដោយឥឡូវនេះមានសំណើពីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធទៅនឹងវិធីនៃការធ្វើសក្ខីកម្មរបស់សាក្សី សក្ខីកម្មអំពីអត្តសញ្ញាណរបស់ជនជាប់ចោទ ដោយម្សិលមិញមានការចំណាប់អារម្មណ៍ពីលោកមេធាវីការពារក្តីអន្តរជាតិ ដែលមានការពាក់ព័ន្ធអំពីទម្រង់ ឬក៏របៀបនៃដំណើរការស្តាប់នូវសក្ខីកម្មរបស់សាក្សីដែលត្រូវមកបង្ហាញអំពីអត្តចរិតរបស់ជនជាប់ចោទ ។

ដើម្បីឲ្យច្បាស់លោកមេធាវីការពារក្តីអន្តរជាតិ សូមលោកបង្ហាញសាជាថ្មីម្តងទៀតអំពីជំហររបស់មេធាវីការពារក្តីអំពីនីតិវិធី ឬក៏របៀបនៃការស្តាប់នូវសក្ខីកម្មរបស់សាក្សី បញ្ជាក់អំពីអត្តចរិតជនជាប់ចោទ ដែលលោកមានបំណងប្រាថ្នាបាននិយាយបង្ហាញពីម្សិលមិញ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន ។ សម្រាប់ធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ទៅលើចំណុចនេះ ខ្ញុំសូមលើកឡើងថា ខ្ញុំចង់ឲ្យសាក្សីហ្នឹងគាត់ធ្វើសេចក្តីថ្លែងការណ៍ខ្លីមួយ មុននឹងយើងចាប់ផ្តើមសួរសំណួរទៅលើពួកគាត់ ។ ខ្ញុំគិតថា នេះគឺជាវិធីមួយដែលអនុញ្ញាតឲ្យយើងធ្វើការបានលឿន ហើយស៊ីសង្វាក់គ្នាផងដែរ ។ សាក្សីបានយល់ដឹងច្បាស់លាស់ហើយ ថាហេតុអ្វីបានជាពួកគាត់មកទីនេះ គឺពួកគាត់មកដើម្បីនិយាយអំពីអត្តចរិតរបស់ជនជាប់ចោទ ហើយខ្ញុំសូមស្នើឲ្យលោកប្រធានអនុញ្ញាត ឲ្យលោកប្រធានសួរគាត់ ថាតើគាត់អាចនិយាយបានអ្វីខ្លះអំពីអត្តចរិតរបស់ជនជាប់ចោទនៅក្នុងការផ្តល់សក្ខីកម្មរបស់គាត់នោះ ។ សូមអរគុណ ។

[១០:៣៨:៤៧]

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ លោក ហ្វ្រង់ស្វ័រ រ៉ូ ខ្ញុំមានសំណួរមួយទាក់ទងទៅនឹងសំណូមពររបស់លោកនេះ ។ នៅពេលដែលយើងនិយាយអំពីលោកបណ្ឌិត ហ្គូលស្ទួន ខ្ញុំបានទទួលព័ត៌មានពីខាងផ្នែកគាំទ្រអ្នកជំនាញ និងសាក្សីថា គាត់ចង់យល់ដឹងឲ្យបានច្បាស់អំពីទំហំនៃការធ្វើសក្ខីកម្មដែលគាត់

នឹងផ្តល់ជូនដល់អង្គសវនាការនេះ ។ ហើយខ្ញុំមិនបានព្យាយាមធ្វើការឆ្លើយតបទៅការលើកឡើងនេះទេ តើលោកមានបំណងឲ្យគាត់ធ្វើសេចក្តីថ្លែងការណ៍ផងដែរឬ? ទៅតាមរបៀបដែលលោកស្នើឲ្យធ្វើការធ្វើជាសេចក្តីសង្ខេប ដែលបានលើកឡើងអម្បាញ់មិញនេះទាក់ទងទៅនឹងគោលបំណងនៃការធ្វើសក្ខីកម្មរបស់គាត់ មានន័យថា តើខ្ញុំត្រូវប្រាប់ទៅខាងផ្នែកអង្គភាពគាំពារសាក្សី និងអ្នកជំនាញអំពីចំណុចនេះឬដែលថា ខាងមេធាវីការពារក្តីចង់ឲ្យសាក្សីនោះធ្វើការពិភាក្សាគ្នាសិនមុននឹងមានវត្តមាននៅចំពោះមុខអង្គសវនាការនេះ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកស្រីចៅក្រម ។ ខ្ញុំជឿថា សម្រាប់លោកចៅក្រម ហ្គូលស្ទូន គឺជាករណីមួយផ្សេងពីសាក្សីដទៃទៀត ដែលមានវត្តមានក្នុងពេលខាងមុខនេះ ។ ដូច្នេះ យើងអាចស្តាប់សក្ខីកម្មរបស់គាត់ ដោយធ្វើការចោទសួរជាសំណួរ យើងបានបញ្ជាក់ច្បាស់ហើយថា នៅពេលដែលយើងផ្តល់នូវបញ្ជីឈ្មោះសាក្សីដែលយើងនឹងធ្វើការកោះហៅ ហើយសម្រាប់លោកចៅក្រម ហ្គូលស្ទូន អាចផ្តល់សក្ខីកម្មអំពីការស្នើទៅលើការដាក់ទោស ទៅលើពិរុទ្ធភាពរបស់គាត់នៅក្នុងយុត្តាធិការអន្តរជាតិនោះ ។

ហើយជាពិសេសទៀតនោះ តើថាការសារភាពទោសនោះ វាមានទាក់ទងទៅលើបច្ច័យអ្វីខ្លះ? ហើយតើមានអត្ថប្រយោជន៍អ្វីទេសម្រាប់ដល់ការផ្សះផ្សាជាតិនោះ ដែលចេញពីគោលជំហររបស់យុត្តា-ធិការអន្តរជាតិ ។ នោះហើយគឺជាចំណុចសំខាន់នៃការចង់ផ្តល់សក្ខីកម្មរបស់លោក ហ្គូលស្ទូន ហើយទាក់ទងទៅនឹងរូបគាត់ផ្ទាល់ ប្រសិនបើយើងសួរគាត់នៅសំណួរដំបូងនេះ គាត់នឹងអាចធ្វើការថ្លែងការណ៍ដោយផ្ទាល់របស់គាត់បាន ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ្វីដែលលើកឡើងនេះ គឺជាការជួយដល់ខ្ញុំឲ្យបានយល់អំពីបញ្ហានេះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

តាមសភាពជាក់ស្តែង បើតាមការយល់ដឹងរបស់ខ្ញុំ គឺខាងមេធាវីការពារក្តីបានលើកឡើងនូវសំណូមពរចំនួនបួន ទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍ដែលសាក្សីនឹងត្រូវអាន ។ ទាក់ទងទៅនឹងចំណុចទាំងបួននោះ។ ចំណុចបី គឺស្នើឡើងឲ្យធ្វើការអាននូវសេចក្តីថ្លែងការណ៍របស់សាក្សីដែលទាក់

ទងទៅនឹង ហិនរី ឃើង ដែលគាត់បានស្លាប់ទៅហើយនោះ ហើយនិងគឺឲ្យផ្តល់ការអនុញ្ញាតឲ្យខាងមេធាវីការពារក្តីអាននូវសេចក្តីសម្រេចរបស់លោកចៅក្រមនោះ ហើយចុងបញ្ចប់ទៀត គឺគាត់បានស្នើឲ្យផ្តល់ពេលវេលាបន្ថែមទៀត ដល់សាក្សី ចេនណា វ៉ាអ៊ួល ។ ហើយខ្ញុំឆ្លើយតបទៅនឹងចំណុចទាំងបួននេះ គឺជាពិសេស គឺចាប់ផ្តើមមួយចំណុចដែលស្រួលជាងគេ ។

ទាក់ទងទៅនឹងការអាននូវសេចក្តីថ្លែងការណ៍របស់ លោក ហិនរី ឃើង ដែលបានទទួលមរណភាពរួចមកហើយនោះ គឺថាយើងមិនធ្វើការជំទាស់ទៅលើគោលជំហររបស់មេធាវីការពារក្តីនេះទេ នៅពេលដែលសេចក្តីថ្លែងការណ៍ហ្នឹងឯង បានដាក់ចូលទៅក្នុងសំណុំរឿង ហើយយើងមានឱកាសដើម្បីធ្វើការអង្កេតនៅក្នុងដំណើរការនីតិវិធី ទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍នេះ ។

ទាក់ទងទៅនឹងវិធីសាស្ត្រដែលបានលើកឡើងនៅថ្ងៃនេះ ឧទាហរណ៍ថា សាក្សីនីមួយៗដែលខាងមេធាវីការពារក្តីបានស្នើឡើងនោះ គឺអាចចាប់ផ្តើមនៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្ម ដោយធ្វើការសេចក្តីថ្លែងការណ៍ខ្លីមួយ។ ខ្ញុំជឿថា ទៅតាមការអនុវត្តរបស់យើង គឺលោកប្រធានជាអ្នកសួរនូវសំណួរ ហើយបន្ទាប់មកទៀត ទើបភាគីសួរសំណួរបន្តទៅតាមអ្វីដែលគេចង់សួរនោះ ។ ហើយដើម្បីជាការគោរពដល់ដំណើរការឲ្យបានស៊ីសង្វាក់គ្នាក្នុងការផ្តល់សក្ខីកម្មនេះ គឺយើងមិននិយាយអំពីដើមបណ្តឹងរដ្ឋប្បវេណីដែលមកផ្តល់សក្ខីកម្មនោះទេ ប៉ុន្តែនេះគឺសាក្សីដែលបានស្បថស្បែរួចទៅហើយ ។ ដូច្នេះយើងត្រូវគិតថា ឲ្យមានភាពស៊ីសង្វាក់គ្នានូវការអនុវត្ត ដែលយើងបានអនុវត្តកន្លងមកនៅចំពោះមុខអង្គសវនាការនេះ ។

ទាក់ទងទៅនឹងការអានសេចក្តីថ្លែងការណ៍ ឬក៏សេចក្តីសម្រេចរបស់ចៅក្រម គឺថាយើងសូមធ្វើការជំទាស់ទៅលើចំណុចនេះ ពីព្រោះសេចក្តីសម្រេចនោះ មិនមែនជាភស្តុតាងនោះទេ ពីព្រោះនេះជា

ចំណុចមួយទាក់ទងទៅនឹងច្បាស់ *ខេសឡ* (Case Law) ហើយមេធាវីការពារក្តីនឹងអាចប្រើបាននៅក្នុងការសូមសម្រាលទោស ការសារភាពទោសនៅពេលក្រោយនោះ បើសិនជានោះជាភស្តុតាងដែលពាក់ព័ន្ធ ។ ហើយនៅទាក់ទងទៅនឹងការសារភាពទោសផងដែរ ទៅតាមការយល់ដឹងរបស់ខ្ញុំនៅក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក យើងគឺមិនអនុញ្ញាតឲ្យធ្វើការអានសេចក្តីថ្លែងការណ៍បែបនេះទេ ឬក៏សេចក្តីសម្រេចបែបនេះទេ ។

ទៅតាមវិធានផ្ទៃក្នុង គឺអាស្រ័យទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថាតើភស្តុតាងនុ៎ង និងហើយក៏ត្រូវមានវត្តមានរបស់រដ្ឋប្បវេណីផងដែរនៅក្នុងអង្គសវនាការនេះ ។ ហើយការ

សារភាពទោសនោះ គឺមិនត្រូវបានគេរំពឹងទុកក្នុងទម្រង់ដូចគ្នានេះទេនៅចំពោះតុលាការអន្តរជាតិ បើយើងធ្វើការយល់ដឹងនេះតាមច្បាប់ខំមិនឡ ។ ហើយទាក់ទងទៅនឹងការស្នើសុំពេលវេលាបន្ថែមសម្រាប់លោកស្រី ហៀ្សណាល ក្នុងពេលគាត់ផ្តល់សក្ខីកម្ម ខ្ញុំយល់ថា ពេលវេលាដែលអង្គសវនាការបានផ្តល់ឲ្យនោះ គឺគ្រប់គ្រាន់ហើយ ។ នេះមិនមែនដើម្បីចៀសវាងទៅលើការនិយាយដដែលឡើងវិញទៅលើអត្តចរិតរបស់ជនជាប់ចោទនោះទេ ក៏ប៉ុន្តែវាក៏ទាក់ទងទៅនឹងសេចក្តីសម្រេចដោយមានធ្វើរួចជាហើយទៅលើរបាយការណ៍ដែលបានដាក់ទៅក្នុងសំណុំរឿងរួចហើយនោះ ។

របាយការណ៍របស់ខាងមេធាវីការពារ-- សាក្សីរបស់មេធាវីការពារក្តីទាក់ទងផ្ទាល់ទៅនឹងស-២១ លោក ហ្វ្រង់ស្វ័រ រូ កាលម្សិលមិញគាត់បានទុកពេលវេលាក្នុងពិនិត្យមើលឯកសាររបស់លោកក្រេក អេតឆេសាន់ ដែលមានច្រើនទំព័រ គឺមានដល់៥០ទំព័រ ហើយនិងមានចំណុចសម្គាល់ចុងទំព័រជាច្រើនទៀត ហើយនោះ គឺជារបាយការណ៍របស់អ្នកជំនាញ ។ ដូច្នេះ យើងឃើញមានការលើកឡើងនូវចំណុចចំនួនបួន ពីខាងមេធាវីការពារក្តីដែលស្នើឲ្យខាងលោកប្រធានធ្វើការសម្រេចទៅលើចំណុចអស់ទាំងនោះ ។ នេះជាការកត់សម្គាល់របស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសោកស្តាយណាស់ ដែលខាងសហព្រះរាជអាជ្ញា ដែលគាត់មិនមានវត្តមាននៅទីនេះកាលពីព្រឹកមិញ-- ព្រឹកម្សិលមិញនៅពេលដែលខ្ញុំផ្តល់សេចក្តីអង្កេតរបស់ខ្ញុំ មានន័យថាគាត់ទទួលបានព័ត៌មានមិនគ្រប់គ្រាន់ទេ ។ ទទួលបានព័ត៌មានពីបុគ្គលនៅក្នុងការិយាល័យរបស់គាត់ទាក់ទងទៅនឹងសំណើរបស់ខ្ញុំនេះ ។

[១០:៤៨:១៤]

ចំណុចទីមួយ គឺថាខ្ញុំមិនដែលស្នើឲ្យសាក្សីធ្វើការអានសេចក្តីថ្លែងការណ៍នោះទេ ផ្ទុយទៅវិញខ្ញុំបានស្នើថា ពួកគេអាចផ្តល់នូវសក្ខីភាពភ្លាមៗ ហើយដែលដូចជា ខាងសហព្រះរាជអាជ្ញាបានដឹងហើយនេះ គឺជាប្រព័ន្ធនៅ-- ដែលគេប្រើប្រាស់អនុវត្តនៅក្នុងស៊ីវិលឡូ ហើយខ្ញុំចង់និយាយថា គឺគាត់បានទទួលព័ត៌មានមិនត្រឹមត្រូវទេ ទាក់ទងទៅនឹងចំណុចនេះទីមួយនេះ ។ ដូចគ្នាផងដែរ គាត់បានទទួលព័ត៌មាន

មិនត្រឹមត្រូវទាក់ទងទៅនឹងសេចក្តីសម្រេច *អូប្រេណូវិច* (Obrenovic) គឺថាខ្ញុំមិនដែលឲ្យធ្វើការអាន សេចក្តីសម្រេច របស់ *អូប្រេះណូវិច* នោះទេ ។

ខ្ញុំបាននិយាយយ៉ាងច្បាស់ថា មេធាវីការពារក្តី គឺអាចទទួលយកបាននូវកាសែតវីដេអូរ នៃការធ្វើសវនាការនៅក្នុងសំណុំរឿងក្តី *អូប្រេណូវិច* ហើយបានធ្វើការដាក់ស្រង់នៅចំណុចខ្លះពីកាសែតវីដេអូទាំងនោះ ។ ជាពិសេស គឺការស្នើឡើងរបស់មេធាវី របស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងសំណុំរឿង *អូប្រេះណូវិច* នេះ ហើយគឺខ្ញុំស្នើឲ្យធ្វើការពិនិត្យមើលទៅលើការដកស្រង់ពីចំណុចខ្លះរបស់កាសែតវីដេអូនោះ ។ មានន័យថា ខ្ញុំមិនបានស្នើឲ្យធ្វើការអានសេចក្តីសម្រេចនៅក្នុងសំណុំរឿងនោះទេ គឺគ្រាន់តែខ្ញុំស្នើឲ្យធ្វើការចាក់វីដេអូ នៅចំណុចមួយចំនួនតែប៉ុណ្ណោះ ។ ហើយខ្ញុំចង់ធ្វើការធានាអះអាងដល់ខាងសហព្រះរាជអាជ្ញថា បើសិនជា នេះជាការពិនិត្យមើលកាសែតវីដេអូ នោះគឺជាទស្សនះរបស់គាត់ គឺថាខ្ញុំនឹងអាចធ្វើសេចក្តីថ្លែងការណ៍ចុងក្រោយរបស់ខ្ញុំ ដែលខ្ញុំមានសេចក្តីសម្រេចក្នុងការធ្វើអាចធ្វើការចាក់វីដេអូនោះបាន ។ នៅក្នុងបរិបទនៃការពិភាក្សាគ្នានៅពេលនេះ ហើយបើសិនជាពួកគេមិនយល់ព្រមទេ គឺខ្ញុំអាចប្រើបាននៅក្នុងសេចក្តីសន្និដ្ឋានបញ្ចប់របស់ខ្ញុំនៅពេលក្រោយទៀត ។

នេះជាជម្រើសរបស់ពួកគេ គឺថាប្រសិនបើពួកគេមិនទទួលយក បើជា-- នេះរឿង-- នេះ សេចក្តីសម្រេចរបស់ខ្ញុំទេ។ ហើយគឺថានៅទីនេះ យើងមិននិយាយអំពីការចោទអំពីការសារភាពទោសនោះទេ ។ ហើយខាងមេធាវី-- ខាងការិយាល័យសហព្រះរាជអាជ្ញាការក៏មិនបានផ្តល់ព័ត៌មានឲ្យបានគ្រប់គ្រាន់ទាក់ទងទៅនឹងការចរចារទៅការសារភាពទោសនោះដែរ ។ ព័ត៌មានដែលខាងគេផ្តល់ឲ្យនោះ គឺវាមិនគ្រប់គ្រាន់ទេ ។ ទាក់ទងទៅនឹងសេចក្តីថ្លែងការណ៍របស់អ្នកជំនាញ ចេនណា តើមានអ្វីទៅដែលធ្វើឲ្យខាងសហព្រះរាជអាជ្ញាមានការព្រួយបារម្ភនោះ? តើអ្វីទៅអាចជាហេតុផល ដែលថា ខាងសាក្សីរបស់មេធាវីការពារក្តីនោះ បានទទួលផលអ្វីទៅបើប្រៀបធៀបទៅនឹងសាក្សីរបស់ខាងសហព្រះរាជអាជ្ញា ដែលបានចំណាយពេលវេលាច្រើនជាងនោះ? ដែលពួកគេបាននិយាយអំពីប្រធានបទដដែលនោះ ហេតុអ្វីបានជាពួកគេនៅតែបារម្ភអំពីសេចក្តីថ្លែងការណ៍ ឬក៏សក្ខីកម្មរបស់សាក្សី ចេនណា នោះ ។

[១០:៥១:៣៥]

ខ្ញុំយល់ថា ពួកគាត់មានសិទ្ធិក្នុងការបារម្ភអំពីរឿងនេះ ក៏ប៉ុន្តែ ខ្ញុំនៅតែរក្សាគោលជំហររបស់ខ្ញុំដដែលគឺថា ខ្ញុំចង់ឲ្យធ្វើការពន្យារពេលបន្ថែមទៀត ទៅលើសេចក្តីថ្លែងការណ៍ ឬក៏សក្ខីកម្មរបស់លោក

ចេនណា ក្នុងការប្រៀបធៀបទៅលើសក្ខីកម្ម និងពេលវេលាដែលបានផ្តល់ដោយ ក្រេក អេតធេសាន់ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក វ៉ាំងសង់ ដឺវ៉ាយេដ៍ ដេស្មាឯល៖**

ទាក់ទងទៅនឹងការអានសេចក្តីថ្លែងការណ៍ ឬក៏ការឆ្លើយតបភ្លាមៗនោះ គឺថាយើងអត់ជំទាស់ទេ ។ ហើយគឺលោកប្រធានទេ ជាអ្នកសម្រេចថា តើវិធីណាជាការសមស្រប? ហើយសំណួរណាដែលលោកប្រធានសួរនៅពេលចាប់ផ្តើមសក្ខីកម្មនោះ?

ទាក់ទងទៅនឹងការស្នើឲ្យចាក់វីដេអូនោះ ខ្ញុំចង់លើកឡើងអំពីសំណួរ អំពីភាពពាក់ព័ន្ធនៃការសម្រេចនៅក្នុងសេចក្តីនោះ មកនៅក្នុងរឿងបច្ចុប្បន្ននេះ ហើយសូមបន្ទាប់មកទៀតឲ្យលោកប្រធានធ្វើការសម្រេចទៅលើចំណុចនេះ ។

ទាក់ទងទៅនឹងសាក្សី ចេនណា វិញខ្ញុំយល់ថា គ្មានអ្វីធ្វើឲ្យប៉ះពាល់ដល់ខាងសហព្រះរាជអាជ្ញាយើងទេ គ្រាន់តែខ្ញុំធ្វើការកត់សម្គាល់ថា របាយការណ៍ដែលបានបង្ហាញជូនក្នុងការគាំទ្រដល់សេចក្តីថ្លែងការណ៍របស់គាត់នោះ គឺខ្លីៗណាស់ ។ ដូច្នេះ គឺមិនចាំបាច់ធ្វើការអនុញ្ញាតឲ្យមានពេលវេលាបន្ថែមទៀតនោះទេ នេះជាចំណុចទាំងអស់ដែលខ្ញុំចង់លើកឡើង ។ សូមអរគុណលោកប្រធាន ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីសាក្សី តើលោកស្រីមានឈ្មោះអ្វី?

[១០:៥៣:៤៦]

**ឆ៖** ចាស, ខ្ញុំឈ្មោះ ស៊ូ សាត ។

**ស៖** តើលោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ចាស, ខ្ញុំអាយុ ៦៦ឆ្នាំហើយ ។

**ស៖** តើលោកស្រីរស់នៅទីកន្លែងណាសព្វថ្ងៃនេះ? ហើយប្រកបមុខរបររកស៊ីអ្វីដែរ?

**ឆ៖** ចាស, សព្វថ្ងៃខ្ញុំនៅភូមិពោធិ៍សែនស្នាយ សង្កាត់ស្រយ្យូវ ក្រុងស្ទឹងសែន អត់មានរបរទេ គឺជាគ្រូបង្រៀនចូលនិវត្តន៍ ។

**សៈ** តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា លោកស្រីមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធ ឬក៏ជាសហព័ទ្ធជាមួយនឹងភាគីណាមួយនៃរឿងក្តីនេះទេ ហើយថាលោកស្រីបានស្បថរួច ហើយមុននឹងអញ្ជើញចូលមកក្នុងបន្ទប់សវនាការនេះ ។ តើជាការពិតដែរឬទេ?

**ឆៈ** ចាស, ជាការពិត ។

**សៈ** អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិ និងករណីកិច្ចដល់សាក្សីលោកស្រី ស៊ូ សាត ក្នុងនាម លោកស្រីជាសាក្សីអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏អំណះអំណាងណាមួយឬច្រើនដែលនាំឲ្យមានពិរុទ្ធភាពលើខ្លួនឯង ។ មានន័យថា ដោយសារតែចម្លើយនោះ ឬអំណះអំណាងនោះនាំលោកស្រីហ្នឹងត្រូវទទួលរងការចោទប្រកាន់ ។ ទន្ទឹមនឹងនេះ លោកស្រីមានករណីកិច្ចនិយាយតែការណាដែលពិតដែលលោកស្រីបានដឹង បានឮ បានឃើញ ដោយផ្ទាល់ពាក់ព័ន្ធជាមួយនឹងខ្លឹមសារដំណើរប្រព្រឹត្តទៅនៃផ្តល់សក្ខីកម្មនេះ ។

**ឆៈ** ចាស ។

**សៈ** លោកស្រី ស៊ូ សាត ចូរលោកស្រីនិយាយរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីអត្តចរិតរបស់ជនជាប់ចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលលោកស្រីធ្លាប់បានដឹងក្នុងអំឡុងពេលដែលលោកស្រីបានធ្លាប់ប្រាស្រ័យទាក់ទងជាមួយនឹងគាត់ ។

**ឆៈ** ចាស, សូមគោរពលោកប្រធាន ។ ខ្ញុំសូមជម្រាបអង្គជម្រះក្តីថា ខ្ញុំបានរៀនក្លឹបរួមគ្នាជាមួយ កាំង ហ្កេកអ៊ាវ ពីរឆ្នាំ គឺពីឆ្នាំសិក្សា១៩៥៩ ដល់ ៦០ និងឆ្នាំសិក្សា ១៩៦០ ដល់៦១ ។ ហើយ កាំង ហ្កេកអ៊ាវ នេះពីមុនគឺក្មេងដែលមានអត្តចរិតស្លូតបូត ស្មោះត្រង់ ចេះយោគយល់គ្នា មានចិត្តទូលាយ ពិសេសគឺថា គេជាសិស្សពូកែនៅក្នុងថ្នាក់ ។ ហើយដែលខ្ញុំយកចិត្តទុកដាក់ គឺគេមិនចេះលាក់គំនិតចំណេះដឹងដែលគេចេះ គឺថាគេតែងតែយកមកពន្យល់មិត្តនៅក្នុងក្លឹបទាំងអស់មានលាក់លៀមទេ។ រាល់ដំណោះស្រាយគណិតវិទ្យាក្តី រូបវិទ្យាក្តី គីមីក្តី គឺថាយើងដោះស្រាយរួមគ្នា គេជាសិស្សដែលល្បីឈ្មោះនៅក្នុងសាលា ប៉ុន្តែក៏គេមិនសូវមានមិត្តភក្តិច្រើនទេ ។

[១០:៥៧:២៦]

ហើយជាពិសេស គឺថាគេជាមនុស្សដែលមិនខ្វល់ខ្វាយរឿងស្រីញីទេ មិនដែលមានពាក់ព័ន្ធរឿងស្នេហាអីទាំងអស់ ។ ហើយជាមិត្តដែលជួយពង្រឹងស្មារតីយើងឲ្យខំតស៊ូរៀនសូត្រឲ្យបានរឹងមាំ ចាស មានតែប៉ុណ្ណឹងទេ ។

**សៈ** លោកស្រីបានធ្វើការរៀបរាប់អំពីអត្តចរិតរបស់ជនជាប់ចោទ នៅក្នុងនៅក្នុងអំឡុងពេលដែលគាត់បានធ្វើការសិក្សាជាមួយនឹងលោកស្រីក្នុងអំឡុងរយៈពេលពីរឆ្នាំ, ឆ្នាំ១៩៥៩ ដល់១៩៦០ និងឆ្នាំ១៩៦០ ដល់១៩៦១ ហើយកាលនោះលោកស្រី និងគាត់រៀននៅថ្នាក់ទីប៉ុន្មានដែរ ហើយការសិក្សានុំងនៅទីកន្លែងណា?

**ឆៈ** ចាស, គឺយើងរៀននៅថ្នាក់ទី៤ និងទី៣ ទំនើប គឺស្មើនឹងថ្នាក់ទី៨ និង៩ បច្ចុប្បន្ននេះ ហើយរៀននៅអនុវិទ្យាល័យកំពង់ធំ ។

**សៈ** ហេតុផលយ៉ាងម៉េចទៅ វាមានភាពខុសគ្នាបន្តិចរវាងអត្តចរិតរបស់គាត់ស្លូតបូត ស្មោះត្រង់ យោគយល់គ្នា ចេះឈឺឆ្អាល ជួយធុរៈដល់អ្នកដទៃ ហើយជួយបង្ហាត់បង្ហាញដល់មិត្តភក្តិផ្សេងទៀតនៅក្នុងក្តីបអំពីចំណេះដឹងរបស់គាត់ ដែលគាត់មានជាពិសេសនៅវិស័យគណិតវិទ្យា មុខវិទ្យាគណិតវិទ្យា ដែលគាត់មានការចេះច្បាស់លាស់ជាងអ្នកដទៃ ឬក៏ជាសិស្សពូកែនោះ ប៉ុន្តែបែបគាត់ទៅជាមនុស្សពុំមានមិត្តភក្តិទៅវិញ វាមានហេតុផលយ៉ាងម៉េចទៅបញ្ហាពីរនេះ? វាមានហេតុផលយ៉ាងម៉េចបានវាមានភាពខុសគ្នារវាងស្ថានភាពនៃលទ្ធភាពរបស់គាត់ ដែលអាចធ្វើឲ្យអ្នកផ្សេងទៀត អាចចូលចិត្តដោយសារការជួយឈឺឆ្អាល ការយោគយល់ ស្មោះត្រង់ ស្លូតបូត និងជួយបង្ហាត់បង្រៀនដល់អ្នក ប៉ុន្តែបែរជាមិនសូវមានមិត្តភក្តិ?

[១១:00:00]

**ឆៈ** ចាស, ខ្ញុំមិនដឹងមូលហេតុដែរ ។

**សៈ** នៅក្នុងអំឡុងពេលដែលលោកស្រីបានធ្វើការសិក្សាជាមួយគ្នា ហើយអាចស្គាល់អំពីអត្តចរិតរបស់គាត់ ដែលលោកស្រីបានកត់សម្គាល់ ហើយបាននិយាយរួចហើយនេះ ។ សួរថា តើក្នុងអំឡុងពេលនោះ គាត់មានដែលមានទំនាស់ ទាស់ទែងជាពាក្យសម្តី ឬក៏កាយវិការជាមួយនឹងមិត្តភក្តិផ្សេងទៀតទេ រួមថ្នាក់ក្តី មិនរួមថ្នាក់ក្តី ឬក៏នៅក្នុងភូមិជាមួយគ្នា ដែលកត់សម្គាល់ឃើញមានដែរឬទេ?

**ឆៈ** ចាស នៅក្នុងភូមិខ្ញុំមិនដែលបានតាមដានទេ តែនៅក្នុងសាលាគាត់មិនដែលទាស់ជាអ្នកណាទេ ។

**សៈ** ចុះអាប្បកិរិយារបស់គាត់ជាមួយនឹងគ្រូបង្រៀននៅអនុវិទ្យាល័យ ដែលលោកស្រីបាននិយាយថាបានរៀននៅក្នុងថ្នាក់ទីបួនហើយនិងថ្នាក់ទីបីកាលនោះ ។ តើវាមានលក្ខណៈយ៉ាងម៉េចដែរអំពីអាប្បកិរិយាចំពោះគ្រូបង្រៀន ឬក៏ចំពោះថ្នាក់ដឹកនាំសាលាពេលនោះ?

**ផ៖** ចាស, គាត់តែងគោរពគ្រូ ហើយនិងថ្នាក់នាំសាលាជានិច្ច មិនដែលមានទំនាស់អីនៅក្នុងសាលាទេ ។

**ស៖** ចុះអំពីផ្នែកខាងវិន័យវិញ ការសិក្សារៀនសូត្ររបស់គាត់ហ្នឹង គាត់មករៀនទៀងទាត់ពេលវេលា ឬក៏ទៀងទាត់ម៉ោងទេ នៅពេលដែល-- ក្នុងអំឡុងពេលសិក្សាជាមួយលោកស្រី?

**ផ៖** ចាស គាត់គោរពវិន័យបានល្អ ទៀងទាត់ ហើយមិនដែលអវត្តមានទេ ។

**ស៖** ចុះពាក្យសម្ដីវិញ តើសម្ដីសំដៅវិញគាត់ក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងមិត្តភក្ដិនៅក្នុងអំឡុងពេលដែលសិក្សារៀនសូត្រជាមួយនឹងលោកស្រីហ្នឹង តើគាត់មានពាក្យសម្ដីទៅកាន់មិត្តភក្ដិ ឬក៏អ្នកដទៃក្នុងស្ថានភាពយ៉ាងម៉េចដែរ? ជាការក្រអឺតក្រទម ឬក៏ជាការស្លូតបូតរាបសា?

**ផ៖** ចាស, ខ្ញុំបានជម្រាបហើយថា គាត់ជាមនុស្សស្លូតបូតសុភាពរាបសា មិនដែលច្រងេងច្រងាងអីទាំងអស់ ។

**ស៖** តើចាប់ពីឆ្នាំ១៩៦២ បានន័យថា ផុតពីឆ្នាំ១៩៦១ ចូលទៅក្នុងឆ្នាំ១៩៦២ រហូតមកដល់បច្ចុប្បន្ន តើលោកស្រីធ្លាប់បានធ្វើការប្រាស្រ័យទាក់ទង ឬក៏ជួបប្រាស្រ័យទាក់ទងជាមួយគាត់ដែរឬទេ?

[១១:០៣:២៦]

**ផ៖** រហូតមក គឺថាយើងអត់ដែលបានទាក់ទងទេរហូត ។ ខ្ញុំមិនចាំថា តើគាត់ទៅរកខ្ញុំវិញនៅឆ្នាំណា? ឆ្នាំ៦៥ ក៏មិនដឹង ៦៦ ក៏មិនដឹង តែគ្រាន់តែខ្ញុំចាំថា ខ្ញុំអត់ទាន់មានកូនទេ គាត់បានទៅផ្ទះខ្ញុំ ។

**ស៖** ហើយនៅក្នុងអំឡុងពេលចាប់ពីឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩ និងថ្ងៃទី០៧ មករា ឆ្នាំ៧៩ និងចាប់តាំងពី០៧ មករា ឆ្នាំ៧៩ រហូតដល់ពេលនេះ តើលោកស្រីបានធ្លាប់បានជួបប្រាស្រ័យទាក់ទងជាមួយនឹងគាត់ដែរឬទេ?

**ផ៖** *(អត់មានសំឡេង)*

**ស៖** សូមឆ្លើយម្ដងទៀត ដោយសារសូមរង់ចាំភ្លើងខៀវនៅក្បាលមីក្រូ ដើម្បីលោកស្រីឆ្លើយបាន បើឆ្លើយទៅ ដើម្បីឲ្យប្រព័ន្ធសំឡេងរបស់លោកស្រីចូលទៅក្នុងប្រព័ន្ធសំឡេងនៃសាលសវនាការ ក៏ដូចជាប្រតិចារឹក ឬការកត់ត្រាកំណត់ហេតុនៅក្នុងសាលសវនាការបាន ។ សូមឆ្លើយម្ដងទៀត ។

**ផ៖** សូមគោរពលោកប្រធាន! សូមលោកប្រធានសួរម្ដងទៀត ចាស ។

**ស៖** ខ្ញុំគ្រាន់តែចង់ដឹងថា នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមេសា ឆ្នាំ៧៩ និងក្រោយមកទៀត គឺចាប់ពី០៧ មករា ៧៩ រហូតដល់ពេលបច្ចុប្បន្ននេះ ថាតើលោកស្រីធ្លាប់បានជួបប្រាស្រ័យទាក់ទងជាមួយគាត់ដែរឬទេ?

**ឆ៖** ចាស, អត់ដែលបានជួបសោះ ។

**ស៖** ចំណុចមួយទៀតត្រឡប់ទៅក្រោយវិញ ដោយសារមានការពាក់ព័ន្ធបន្តិច ។ សំណួរសួរថា តើលោកស្រីមានបាន-- មានព័ត៌មានអ្វីដែរទេ នៅក្នុងអំឡុងពេលដែលគាត់បានសិក្សាជាមួយនឹងលោកស្រីពីរថ្នាក់ គឺនៅថ្នាក់ទីបួន និងថ្នាក់ទីបីទំនើប នៅអនុវិទ្យាល័យនោះ នៅកំពង់ធំនោះ ។ ថាតើកាលនោះមានបានដឹងអំពីព័ត៌មានស្តីពីការទទួលរងនូវឥទ្ធិពលពីលទ្ធិកុម្មុយនីស្តនៅទីនោះនៅក្នុងអំឡុងពេលសិក្សាដែរឬទេ?

**ឆ៖** ចាស, ខ្ញុំអត់បានទទួលព័ត៌មានអីសោះ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី ។ លោក លោកស្រីចៅក្រម តើមានសំណួរអ្វីសួរដល់សាក្សីរូបនេះដែរឬទេ? បើមានសូមអញ្ជើញ ។

ជាបន្តនេះដោយចៅក្រមនៃអង្គជំនុំជម្រះពុំមានសំណួរទេ-- មានសំណួរ សូមអញ្ជើញ លោកចៅក្រមហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** អរុណសួស្តីលោកស្រី លោកស្រីបាននិយាយថា ជនជាប់ចោទទៅជួបលោកស្រីនៅឆ្នាំ ១៩៦៥ គឺជាពេលចុងក្រោយ ដែលលោកស្រីជួបជាមួយគាត់ បន្ទាប់មក គឺអត់មានការទាក់ទងជាមួយនឹងគាត់ទៀតទេ ។ តើលោកស្រីអាចជម្រាបបានដែរឬទេ ថាតើនៅពេលដែលគាត់ទៅលេងលោកស្រីនៅឆ្នាំនុ៎ង គាត់សួរនាំអំពីអ្វីដែរ?

**ឆ៖** ចាស, គាត់បានទៅនៅឆ្នាំ៦៥ គាត់បានប្រាប់ថា គាត់បង្រៀននៅស្គន់ ។

**ស៖** តើគាត់មានមកជំរុញឲ្យលោកស្រីធ្វើជាគ្រូជាគាត់ដែរឬទេ?

**ឆ៖** ចាស, អត់មានជំរុញទេ ព្រោះខ្ញុំធ្វើគ្រូស្រាប់ហើយ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកស្រីច្រើន ខ្ញុំពុំមានសំណួរសួរទៅលើសាក្សីរូបនេះ អំពីអត្តចរិតទៀតទេ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីឲ្យមានឱកាសក្នុងការសួរសំណួរដល់សាក្សីរូបនេះ ។ ប្រសិនបើមាន ហើយសូមអញ្ជើញ ហើយមានពេលវេលាដប់នាទី ក្នុងការសួរនេះ ។

**សួរដោយលោក តាន់ សេណារ៉ុង៖**

សូមគោរពនិងអរគុណលោកប្រធានអង្គជំនុំជម្រះ និងសូមស្វាគមលោកស្រី ស៊ូ សាត។តំណាងសហព្រះរាជអាជ្ញាពុំមានសំណួរច្រើនទេ គឺមានសំណួរតែមួយជូនលោកស្រី ។ នៅក្នុងនោះលោកស្រីបានរៀបរាប់ជូនអង្គជំនុំជម្រះអម្បាញ់មិញថា លោកស្រីធ្លាប់បានរៀនសូត្រជាមួយ កាំង ហ្គេកអ៊ាវ តែពីរឆ្នាំប៉ុណ្ណោះ គឺឆ្នាំ១៩៥៩ ឆ្នាំ១៩៦០ និង ឆ្នាំ១៩៦០ ទៅឆ្នាំ១៩៦១ ដែលស្ថិតនៅក្នុងក្លឹបជាមួយគ្នា ហើយបានបញ្ជាក់ពីអត្តចរិតថា គាត់ស្លូតបូត មានចិត្តទូលាយ និងបង្ហាញនូវបំណងល្អៗជាច្រើនដល់មិត្តភក្តិរបស់គាត់ ។

[១១:១០:១២]

**ស៖** សំណួរសួរថា ក្រៅតែពីរឆ្នាំហ្នឹងដែលលោកស្រីធ្លាប់បានរៀនជាមួយគ្នា តើលោកស្រីដែលហានអះអាងថា គាត់ជាមនុស្សដែលមានចរិតល្អ ចិត្តទូលាយ និងមិត្តភក្តិនោះ តើលោកស្រីធ្លាប់ដែលមានបានទៅស្គាល់ផ្ទះ និងភូមិ និងលំនៅដ្ឋានពីក្រុមគ្រួសាររបស់គាត់ហ្នឹងដែរឬទេ?

**ឆ៖** ចាស, ខ្ញុំអត់ដែលស្គាល់សម្បែងរបស់គាត់ តែនៅក្នុងក្លឹបហ្នឹងគឺថាមានមិត្តខ្លះ គឺថាគេចង់លាក់ អារឿងគេចេះហើយ គេមិនចង់បង្ហាញទេ តែគាត់ៗអត់លាក់ទេ គាត់បង្ហាញទាំងអស់ ថាស៊ីដែលជាគន្លឹះនៃការដោះស្រាយគណិតក្តី រូបវិទ្យាក្តី គីមីក្តី គឺថាគាត់យកមកចែករំលែក អត់មានលាក់លៀមថា អ៊េ្ហ! មិនចេះទេ អីទេ ។ តែផ្ទះសម្បែងខ្ញុំអត់ស្គាល់ទេ គ្រាន់តែដឹងថា ឪពុកគាត់ជាឆាយហ៊្វនៅឡូត៍នៃសាទ ។

**ស៖** អរគុណលោកស្រី ខ្ញុំសូមសួរបន្តសំណួរភ្ជាប់មួយទៀតចុះថា ការជួបគ្នាតែពីរឆ្នាំនៅក្នុងការសិក្សារបស់លោកស្រីនៅក្នុងអនុវិទ្យាល័យ ហាក់ដូចជាវាតិចណាស់ ។ នៅក្នុងនោះដែរ ខ្ញុំចង់សួរថា នៅពេលដែលការសិក្សានៅពេលនោះ គឺថាត្រឹមថ្នាក់ទីបួន និងទីប្រាំ នៅអនុវិទ្យាល័យប៉ុណ្ណោះ ។ ទីបួន

ទីប្រាំអ៊ីចឹង? បាទថាការសិក្សានៅអនុវិទ្យាល័យជាមួយគ្នា ក្រៅតែពីលោកស្រីឃើញពីចិត្តគំនិតរបស់គាត់ដែលមានលក្ខណៈទូលំទូលាយហ្នឹង តើលោកស្រីមានកត់សម្គាល់ឃើញពីទស្សនវិស័យរបស់បុគ្គលហ្នឹងដែរទេ ថាបុគ្គលនោះមានទស្សនវិស័យទៅមុខយ៉ាងដូចម្តេចដែរ? មានៗកំណត់សម្គាល់នូវបញ្ហានុ៎ងទេ?

**ឆ៖** ចាស, នៅពេលរៀនជាមួយគ្នាយើងគិតតែរៀន យើងអត់បានកត់សម្គាល់ពីទស្សនវិស័យរបស់គាត់ទេ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោកស្រី ស៊ូ សាត និងអរគុណលោកប្រធានអង្គជំនុំជម្រះ ខ្ញុំសូមបន្តសំណួរហ្នឹងជូនសហការីរបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

[១១:១២:៥៨]

**សួរដោយលោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្វាឯង៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោកស្រី ស៊ូ សាត លោកស្រីទើបតែជម្រាបយើងខ្ញុំថាជនជាប់ចោទ គឺជាប្រធានក្រុមសហសិក្សា ដែលលោកស្រីជាសមាជិកនៅក្រុមសហសិក្សានោះ ។ ថាតើគោលបំណងនៃក្រុមសហសិក្សានោះយ៉ាងម៉េចដែរ? តាមការយល់ឃើញរបស់ជនជាប់ចោទ ដែលលោកស្រីជម្រាបថា គាត់ជាសិស្សពូកែ ថាក្រុមសហសិក្សានោះ គឺជាការបង្កើតឡើងដើម្បីចង់ឲ្យគេទទួលស្គាល់គាត់ ឬក៏គាត់រៀបចំក្រុមនេះឡើងដោយមិនមានការចាប់អារម្មណ៍ហ្នឹងគោលបំណងដូច្នោះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា គឺថាមិនមែនតែគាត់ជាសិស្សពូកែ ខ្លួនខ្ញុំផ្ទាល់ក៏ជាសិស្សពូកែដែរ ហើយមិនអាចចាត់តាំងគាត់ថា ជាប្រធានក្រុមទេ គឺយើងស្ម័គ្រចិត្តរួមគ្នា រៀនជាមួយគ្នា អត់មានអ្នកណាដឹកនាំអ្នកណាទេ ។

**ស៖** លោកស្រីនិយាយអម្បាញ់មិញថាពិបាកក្នុងការពន្យល់ថា ហេតុអ្វីបានជាគាត់មិនមានមិត្តភក្តិច្រើន និក ដនឡុប ក៏បានលើកឡើងនៅទំព័រទី៤៦ នៃសៀវភៅរបស់គាត់ កថាខណ្ឌចុងក្រោយផងដែរ ។ លោកស្រីបានរៀបរាប់ថា គាត់ទទួលជោគជ័យនៅក្នុងការសិក្សារបស់គាត់នៅសាលា ហើយ

គាត់ក៏ល្បីផងដែរ ។ ថាតើលោកស្រីជឿថាគាត់មានការរងប៉ះពាល់ទៅលើស្ថានភាពនោះដែរឬទេ? បានន័យថា ស្ថានភាពហ្នឹងមានការប៉ះពាល់ផ្លូវចិត្តគាត់យ៉ាងម៉េចដែរឬទេ?

**ឆ៖** ចាស, ខ្ញុំអត់បានដឹង ព្រោះយើងគិតតែពីរៀន ។

**ស៖** សូមអរគុណច្រើនលោកស្រី ស៊ូ សាត ។ តើលោកស្រីស្គាល់គ្រូ កែ គឹមហួត ដែលជាគ្រូរបស់គាត់ តាំងពីឆ្នាំ១៩៥៨ ដែរឬទេ? តើលោក កែ គឹមហួត នោះជាគ្រូរបស់លោកស្រីដែរឬទេនៅពេលនុ៎ង?

**ឆ៖** ចាស, ខ្ញុំអត់បានរៀនជាមួយលោកគ្រូ កែ គឹមហួត ទេ តែខ្ញុំបានស្គាល់គាត់ ។ តែមិនបានទាក់ទងអ្វីទេ គ្រាន់តែស្គាល់ថា គាត់បង្រៀននៅអនុវិទ្យាល័យ ។

**ស៖** តើជនជាប់ចោទ ធ្លាប់និយាយអំពីគ្រូនោះដែរឬទេ? ហើយគាត់ដែលនិយាយថា គាត់ទទួលឥទ្ធិពលពីគ្រូនោះយ៉ាងម៉េចដែរឬទេ? ហើយគាត់មានទំនាក់ទំនងធម្មតាជាមួយនឹងគ្រូរបស់គាត់នោះដែរឬទេ ឬក៏គាត់មានទំនាក់ទំនងពិសេស តាមអ្វីដែលលោកស្រីបានដឹងនោះ?

**ឆ៖** ចាស, គាត់មិនដែលនិយាយអ្វីពីទំនាក់ទំនងរវាងគាត់ហើយនិងគ្រូរបស់គាត់ទេ ។ ហើយខ្ញុំក៏មិនបានដឹងថា ពីមុនមកគាត់ជាសិស្សរបស់លោកគ្រូ កែ គឹមហួត ដែរ ។

**ស៖** តាមការយល់នូវចម្លើយរបស់លោកស្រី តាមអ្វីដែលលោកស្រីចាំអំពីជនជាប់ចោទពុំមានអ្វីជំរុញឲ្យលោកស្រី ជឿថា នៅពេលនោះគ្រូរបស់គាត់មួយរូបនឹងមកជាប់ឃុំនៅស-២១ ក្រោមការគ្រប់គ្រងរបស់គាត់នោះទេ?

**ឆ៖** ខ្ញុំអត់បានដឹងទេ ទើបតែមើលសៀវភៅ ពេជ្ឈឃាតបាត់ខ្លួន ទើបខ្ញុំដឹងថា លោកគ្រូ កែ គឹមហួត ត្រូវស្លាប់នៅគុកទួលស្លែង ។

**ស៖** តើលោកស្រីមានប្រតិកម្មយ៉ាងម៉េចនៅពេលដែលលោកស្រីទទួលព័ត៌មានអំពីករណីស្លាប់គ្រូរបស់គាត់នៅស-២១ នៅពេលដែលលោកស្រីមើលសៀវភៅទាំងអស់នោះ?

[១១:១៨:៤២]

**ឆ៖** ខ្ញុំមានការតក់ស្លុតជាខ្លាំង ។

**ស៖** លោកស្រីមុនហ្នឹងនិយាយថា លោកស្រីមិនដែលឃើញហេតុការណ៍ ដែលជនជាប់ចោទបាត់បង់ទៅលើស្ថានភាពនូវការគ្រប់គ្រងខ្លួន នៅពេលដែលគាត់ប្រាស្រ័យទាក់ទងជាមួយនឹងមិត្តភក្តិ

របស់គាត់នោះទេ ។ ថាតើពីអ្នកដែលចេះដឹងនោះ នៅពេលដែលគាត់ឈ្លោះប្រកែកជាមួយនឹងមិត្តភក្តិរបស់គាត់នោះ ថាតើគាត់មានប្រតិកម្មយ៉ាងម៉េច? គាត់មានការតតាំងជម្នះទៅលើពួកគេដែរឬទេ?

**ផ៖** សូមលោកសហព្រះរាជអាជ្ញាសួរសំណួរម្តងទៀត ខ្ញុំស្តាប់មិនសូវបាន ។

**ស៖** ខ្ញុំចង់ដឹងថាតើនៅពេលដែលជនជាប់ចោទ ទាក់ទងប្រាស្រ័យជាមួយនឹងមិត្តភក្តិនៅសាលា ថាតើជនជាប់ចោទមានបានធ្លាប់និយាយអ្វី? ហើយនៅពេលដែលមានសិស្សណាមួយជំទាស់ជាមួយនឹងគាត់ដោយសារតែមិនយល់ស្រប ជាមួយនឹងជនជាប់ចោទ ថាតើនៅពេលនុំងជនជាប់ចោទ គាត់មានប្រតិកម្មយ៉ាងម៉េច? គាត់នៅស្ងៀម? ហើយធ្វើឲ្យគាត់ខឹងសម្បាដែរឬទេ ឬក៏គាត់ជំរុញឲ្យមិត្តភក្តិដែលគាត់ជំទាស់នោះ ជឿគាត់ ឬគាត់ព្យាយាមសង្កេត និងស្វែងយល់យោបល់របស់មិត្តភក្តិដែលជំទាស់នឹងគំនិតរបស់គាត់?

**ផ៖** ចាស, ខ្ញុំអត់ដែលឃើញគាត់ទាស់ជាមួយនឹងនរណាទេ ។

**ស៖** ខ្ញុំនៅមានសំណួរពីរខ្លីៗ ។ លោកស្រី ស៊ូ សាត តើលោកស្រីបានដឹងដែរឬទេ អំពីនៅពេលដែលគាត់បរាជ័យក្នុងស្នេហារបស់គាត់ នៅពេលដែលលោកស្រីជាសិស្សនៅសាលាកំពង់ធំនោះ?

**ផ៖** ខ្ញុំមិនដែលដឹងថា គាត់បរាជ័យក្នុងស្នេហាអីទេ អត់សោះហើយ ។

**ស៖** ចំណុចចុងក្រោយ ខ្ញុំចង់សួរថាតើនៅពេលនោះជនជាប់ចោទ គឺគាត់លាក់លៀមអំពីដើមកំណើតចិនរបស់គាត់ អំពីសកម្មភាពផ្ទាល់ខ្លួនរបស់គាត់ និងលាក់លៀមអំពីមហិច្ឆិតារបស់គាត់ដែរឬទេ? តើជនជាប់ចោទគាត់ហាក់ដូចជាសម្តែងថា គាត់ចាប់អារម្មណ៍ចំពោះនយោបាយដែរឬទេ? ឬក៏គាត់គ្រាន់តែផ្តោតអារម្មណ៍ទៅលើការសិក្សាគាត់តែប៉ុណ្ណោះ?

**ផ៖** ឃើញអង្កាល់នៅរៀនជាមួយគ្នា គឺគាត់មិនដែលនិយាយអីទេ ។

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំពុំមានសំណួរបន្ថែមសួរទៅកាន់សាក្សីនេះទេ ។

[១១:២២:៥០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងក្រុមបី ។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោក លោកស្រីចៅក្រម ។ លោក លោកស្រីដឹង ហើយថាដើមបណ្តឹងរដ្ឋប្បវេណី គាត់មិនចូលរួមនៅក្នុងដំណើរការនេះទេ ហើយស្នើសុំឲ្យមេធាវីមានវត្តមាននៅទីនេះដើម្បីឲ្យសាក្សីគាត់បានដឹងអំពីមូលហេតុនៃការអវត្តមានដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ ហើយខ្ញុំស្នើសុំ លោកប្រធានឲ្យជម្រាបមួយមាត់ពីរមាត់ ពន្យល់ទៅកាន់សាក្សី ហេតុអ្វីបានពុំមានដើមបណ្តឹងរដ្ឋប្បវេណី ចូលរួមនៅក្នុងដំណើរការសវនាការនៅក្នុងថ្ងៃនេះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានបង្ហាញពីម្សិលមិញហើយ អំពីការឆ្លើយតបនឹងមេធាវី អំពីករណីនេះថា អង្គជំនុំជម្រះមិនធ្វើការរៀបរាប់ប្រាប់អំពីមូលហេតុនេះចំពោះសាក្សីនេះ អំពីមិនមានវត្តមានរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការស្តាប់សក្ខីកម្មរបស់សាក្សីក៏ដូចជាអ្នកជំនាញទេ ។ ដូចជាច្បាស់លាស់ហើយ គ្មានមូលហេតុអ្វីត្រូវជម្រាបប្រាប់ដល់សាក្សី អំពីករណីនេះទេ អំពីមូលហេតុនៃសេចក្តីសម្រេចពាក់ព័ន្ធនាំឲ្យសាក្សី នាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីសម្រេចមិនចូលរួមនៅក្នុងដំណើរការនីតិវិធី គឺអង្គជំនុំជម្រះបានជម្រាបរួចហើយ អំពីសំអាងហេតុនៃសេចក្តីសម្រេចនោះ និងផ្តល់ជូនឲ្យដល់ភាគីនៅក្នុងអំឡុងពេលនៃដំណើរការ ពិភាក្សារបស់អង្គជំនុំជម្រះបានចប់សព្វគ្រប់ ។

**លោកស្រី គ្រីស្ទីន ម៉ាទីណូ៖**

ខ្ញុំបានយល់នូវអ្វីដែលលោកប្រធាន បានលើកឡើងកាលពីម្សិលមិញ ប៉ុន្តែវាជាសវនាការមួយសំខាន់ណាស់ ។ ដូច្នេះ ខ្ញុំជឿថា វាជាភាពចាំបាច់ដែលសាក្សីត្រូវតែគាត់ទទួលព័ត៌មាន ហេតុអ្វីបានជាដើមបណ្តឹងរដ្ឋប្បវេណីអវត្តមាន? ហើយហេតុអ្វីបានជាមានការដកសិទ្ធិបែបនេះ? ដើម្បីកុំឲ្យពន្យារទៅលើដំណើរការសវនាការរបស់យើង ប្រហែលជាលោកស្រីគាត់មិនបានដឹងអំពីបញ្ហានោះទេ ហើយយើងដឹងថា យើងនឹងទទួលបានសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៅក្នុងពេលឆាប់ៗ ។ ហើយយើងក៏បានទទួលព័ត៌មានថា តាមរយៈសារព័ត៌មានផ្សេងៗផងដែរ ដែលកាសែតបានចុះទៅលើករណីទាំងអស់នេះ ។

[១១:២៦:០៦]

**ប្រធានអង្គជំនុំ៖**

តទៅនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តីដើម្បីមានឱកាសក្នុងការសួរនូវសំណួរដល់សាក្សីរូបនេះ ។

សូមអញ្ជើញ ។

**ការតាំងសំណួរដោយមេធាវីការពារក្ដី**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ និងអង្គសវនាការទាំងមូល ។

**ស៖** សូមគោរពលោកស្រី ស៊ូ សាត ខ្ញុំសូមសួរលោកស្រីថា ពេលរៀនក្នុងក្លឹបសិក្សាជាមួយ កាំង ហ្គេកអ៊ាវ តើពេលនោះលោក កាំង ហ្គេកអ៊ាវ ដែលចង់ហៅលោកស្រី គាត់ហៅលោកស្រីហ្នឹងចំឈ្មោះតែម្ដង ឬក៏ហៅយ៉ាងម៉េច? ហើយទាំងមិត្តភក្ដិទាំងអស់ ដែលស្រីៗនៅជាមួយគ្នា តើគាត់ហៅយ៉ាងម៉េច? សូមលោកស្រីមេត្តាបញ្ជាក់ ។

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី គាត់តែងហៅខ្ញុំថា មីង មីងរហូតមក ឯមិត្តមួយទៀតនោះហៅឈ្មោះតែម្ដង ព្រោះក្នុងក្លឹបហ្នឹងមានប្រុស ៣នាក់ ស្រី ២នាក់ ។ ហើយចំពោះម្នាក់ទៀត គាត់ហៅឈ្មោះ ហេតុតែខ្ញុំនឹងគាត់អត់ហៅឈ្មោះទេ ។ *(អត់ឮសម្លេង)* -- មីង ។

**ស៖** សូមអរគុណ សូមលោកស្រីបញ្ជាក់បន្ថែមទៀត ហេតុអីបានជាគាត់មិនហៅលោកស្រីចំឈ្មោះ បែជាហៅមីងទៅវិញ?

**ឆ៖** ខ្ញុំមិនចាប់អារម្មណ៍ដែរ ព្រោះអង្កាល់ហ្នឹងខ្ញុំគិតថាប្រហែលជាគាត់ហៅតាមក្មួយៗខ្ញុំ ព្រោះក្មួយខ្ញុំ ក៏នៅរៀននៅហ្នឹងច្រើនដែរ តែមិនដឹងគាត់យល់យ៉ាងម៉េចទេ បានគាត់ហៅខ្ញុំថាមីង ។ ហើយគាត់ហៅប្ដី ដល់ទៅនេះ គាត់ហៅប្ដីខ្ញុំថា ពូ ដែរ ។

**ស៖** សូមអរគុណ ហើយក្នុងមួយរយៈកាលដែលលោកស្រីបានស្គាល់ កាំង ហ្គេកអ៊ាវ តើលោកស្រីអាចបានដឹង អំពីជីវភាពរស់នៅរបស់ កាំង ហ្គេកអ៊ាវ ទេ តើគាត់ជានៅក្នុងគ្រួសារគាត់ក្រយ៉ាប់យ៉ឺន ឬក៏ធូរធារ? សូមលោកស្រីបញ្ជាក់មើល៍?

**ឆ៖** ចាស, លោកមេធាវី ខ្ញុំអត់បានដឹងទេ គ្រាន់ដឹងថា គាត់រឹតត្បិតណាស់ក្នុងការចាយវាយ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ ។ សូមអរគុណលោកប្រធាន សូមឲ្យលោកមេធាវីការពារអន្តរជាតិ សួរបន្តខ្ញុំមិនសួរអីទៀតទេ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។

**ស៖** សួរស្តីលោកស្រីសាក្សី សូមអរគុណ ដែលលោកស្រីបានមានវត្តមាននៅទីនេះ ។ ខ្ញុំចង់សួរលោកស្រីនូវសំណួរមួយចំនួន ។ តើជាការត្រឹមត្រូវទេ ដែលថាលោកស្រីខ្លួនឯងផ្ទាល់ហ្នឹងធ្លាប់បានធ្វើការឲ្យអង្គការសិទ្ធិមនុស្សមួយ ជាច្រើនឆ្នាំមកហើយនៅទីក្រុងភ្នំពេញនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី ខ្ញុំធ្លាប់ធ្វើការនៅអង្គការលីកាដូរយៈពេលដប់ឆ្នាំ គឺពីឆ្នាំ ៩៥ រហូតដល់២០០៥ ។

**ស៖** តើលោកស្រីអាចផ្តល់ព័ត៌មានឲ្យយើងបានខ្លះទេ ថាតើលោកស្រីធ្វើអ្វីខ្លះដែរនៅក្នុងអង្គការលីកាដូ ដែលលោកស្រីធ្វើការនោះ? តើលោកស្រីមានតួនាទីជាអ្វី?

**ឆ៖** ចាស, ខ្ញុំមានតួនាទីជាគ្រូបង្រៀនសិទ្ធិមនុស្ស ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! ខ្ញុំអត់មានសំណួរអ្វីទៀតទេ សម្រាប់សាក្សីនេះ។ ក៏ប៉ុន្តែខ្ញុំសម្គាល់ថា ឃើញថាលោកស្រី ស៊ូ សាត ចង់ស្នើសុំការអនុញ្ញាតពីលោកប្រធាន ដែលថាគាត់ចង់ធ្វើការសួរសុខទុក្ខដល់ជនជាប់ចោទ ។ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅពេលដែលសាក្សីបានបញ្ចប់ការផ្តល់សក្ខីកម្មហើយ គឺថាគាត់បានស្នើសុំធ្វើការសួរសុខទុក្ខដល់ជនជាប់ចោទ ពីព្រោះអីការស្នើសុំសួរសុខទុក្ខបែបនេះមិនអាចធ្វើបានទេ មុនពេលដែលសាក្សីនោះគាត់ផ្តល់សក្ខីកម្មនោះ ហើយមានតែលោកប្រធានទេ ដែលមានសិទ្ធិការអនុញ្ញាតបែបនេះ ។

**ប្រធានអង្គជំនុំ៖**

សាក្សីដូចអត់មានបំណងហ្នឹងទេ តែបំណងនេះបែរចេញមកពីមេធាវី ហ្វ្រង់ស្វ័រ រូ ទៅវិញ ។ សាក្សីនិយាយតាំងពីដើមរហូតមកដូចអត់ទាន់ឮ ។ ម៉េចទៅសាក្សី តើមានបំណងចង់សួរសុខទុក្ខជនជាប់ចោទដូចអ្វីដែលលោកមេធាវី ហ្វ្រង់ស្វ័រ រូ និយាយទេ?

**លោកស្រី ស៊ូ សាត៖**

ចាស ខ្ញុំក៏ចង់ជួបគាត់មួយភ្លែតដែរ ប្រហែលជាដប់នាទីចុះយ៉ាងយូរ ។

**ប្រធានអង្គជំនុំ៖**

សំណើសុំរបស់លោកស្រីនេះ អង្គជំនុំជម្រះនឹងពិចារណា ហើយនិងជម្រាបជូនលោកស្រីជាក្រោយ ហើយនិងបើមិនមានយល់ទាស់ទេនោះ គឺរៀបកម្មវិធីសមស្របសម្រាប់លោកស្រីជួបប្រាស្រ័យទាក់ទងជាមួយគាត់ជាក្រោយ ប៉ុន្តែដំណើរការសវនាការឥឡូវនេះបានចប់ហើយក្នុងការស្តាប់សក្ខីកម្មរបស់លោកស្រី ដែលបង្ហាញអំពីអត្តចរិតរបស់ជនជាប់ចោទ ។

ហើយអង្គជំនុំជម្រះអរគុណដល់ចំពោះលោកស្រី ដែលបានអញ្ជើញមកចូលរួមនៅក្នុងកិច្ចដំណើរសវនាការតាមការកោះហៅរបស់តុលាការ ។ ហើយឥឡូវនេះដល់ទីបញ្ចប់ហើយ លោកស្រីអាចរកទីកន្លែងសម្រាកបាននៅកន្លែងសាលសវនាការ ឬមួយក៏កន្លែងណាមួយសមស្រប ដោយចាប់ពីពេលនេះទៅ លោកស្រីអាចចូលរួមនៅក្នុងដំណើរការជាសាធារណជនបានហើយ ។ ហើយនៅក្នុងអំឡុងពេលថ្ងៃនេះអង្គជំនុំជម្រះនឹងពិភាក្សា ហើយនិងសម្រេចអំពីការជួបប្រាស្រ័យទាក់ទងលោកស្រីជាមួយសួរសុខទុក្ខជាមួយនឹងជនជាប់ចោទនោះ ថាតើគួរតែធ្វើពេលណា ព្រោះពេលវេលាកំពុងតែដំណើរការសវនាការ ។

អញ្ជើញចុះ ហើយមន្ត្រីតុលាការ អញ្ជើញសាក្សីមួយរូបទៀតចូលមកកាន់សាលសវនាការ គឺលោក ទេព សែម ។

*(សាក្សី លោក ទេព សែម ចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីសាក្សី! តើលោកមានឈ្មោះ ទេព សែម អ៊ីចឹងពិតមែនដែរឬទេ?

**ឆ៖** ខ្ញុំបាទ ជាដំបូងសូមគោរពប្រធាន សហប្រធាន សហមេធាវី សហព្រះរាជអាជ្ញាអីទាំងអស់ ជាទីគោរព និងសូមគោរពលោកគ្រូ ជាលោកគ្រូរបស់ខ្ញុំ ។ ខ្ញុំជាដំបូង គឺខ្ញុំ ខ្ញុំបាទឈ្មោះ ទេព សែម ពិតប្រាកដមែន ។

**ស៖** លោក ទេព សែម តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំអាយុ៦១ ឆ្នាំហើយ ។

**ស៖** លោក ទេព សែម អង្គជំនុំជម្រះសូមណែនាំលោកថា លោកកុំអាលនិយាយឆ្លើយឆាប់រហ័សពេក លោករង់ចាំមើលភ្លើងសញ្ញានៅក្បាលមីក្រូ មានសញ្ញាភ្លើងក្រហម ចាប់ពីពេលនោះទើបលោកអាចនិយាយបាន ដើម្បីឲ្យប្រព័ន្ធសំឡេងរបស់លោកហ្នឹង ត្រូវបានកត់ត្រាទុកនៅក្នុងកំណត់នៃដំណើរការសវនាការ និងបានផ្សព្វផ្សាយនៅក្នុងប្រព័ន្ធផ្សព្វផ្សាយសំឡេងនៅក្នុងអង្គសវនាការ ហើយមានការបកប្រែជូនទៅភាគីផ្សេងទៀត ដែលប្រើប្រាស់ភាសាបរទេស មានបារាំង និងភាសាអង់គ្លេសជាដើម ទាំងអ្នកចូលរួមដំណើរការនីតិវិធី ទាំងសាធារណជនផង ។ លោកយល់ដែរឬទេ?

លោកសព្វថ្ងៃនេះ លោករស់នៅទីកន្លែងណា? ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** ខ្ញុំបាទសព្វថ្ងៃនេះ រស់នៅភូមិតាសែន ឃុំសន្ទុក ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ របររកទទួលទានជាកសិករ ។

**ស៖** តាមរបាយការណ៍ក្រឡាបញ្ជីសវនាការថា លោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធ ឬក៏ជាសហព័ទ្ធជាមួយនឹងភាគីនៃរឿងក្ដីនេះទេ ហើយនិងរាយការណ៍ផងដែរថា លោកបានស្បថរួចហើយ មុននឹងចូលមកកាន់សាលសវនាការ តើជាការពិតដែរឬទេ?

**ឆ៖** បាទ, ក្នុងសេចក្ដីដែលគាត់បានសាកសួររាយការណ៍មកនេះ គឺពិតមែន គឺថាខ្ញុំបាទនេះមិនមានជាសាច់សាលោហិតអីអ្វីជាមួយនឹងលោក ឌុច ទេ ។

**ស៖** ក្នុងនាមលោកជាសាក្សី អង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិនិងករណីយកិច្ចដូចខាងក្រោមនេះ។ លោក ទេព សែម ក្នុងនាមលោកជាសាក្សី លោកអាចបដិសេធទៅនឹងសំណួរ ឬក៏អំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនលោក ហើយក្នុងនាមលោកជាសាក្សី លោកមានករណីយកិច្ចនិយាយតែការណ៍ ដែលពិតដែលលោកបានដឹង បានឮ បានឃើញដោយផ្ទាល់ ។

លោក ទេព សែម អាចនិយាយប្រាប់អង្គសវនាការបានដែរឬទេ ថាតើលោកធ្លាប់ធ្វើការប្រាស្រ័យទាក់ទងជាមួយនឹងជនជាប់ចោទ រយៈពេលកន្លងមកនៅក្នុងអំឡុងពេលណាដែរ? អស់រយៈពេលប៉ុន្មានឆ្នាំ ហើយនៅទីកន្លែងណា? មូលហេតុអីបានជាមានការប្រាស្រ័យ នាំឲ្យលោកមានការស្គាល់ ហើយនិងធ្លាប់ប្រាស្រ័យទាក់ទងជាមួយនឹងជនជាប់ចោទ?

**ឆ៖** បាទ, ខ្ញុំបាទបានប្រាស្រ័យទាក់ទង កាលនោះ កាលនៅឆ្នាំយើង១៩៦៥-៦៦ គាត់ជាសាស្ត្រាចារ្យបង្រៀននៅសាលាស្រុកជើងព្រៃ ខេត្តកំពង់ចាមយើងហ្នឹង បានជាស្គាល់គាត់ហ្នឹង ។ គាត់ជាគ្រូរបស់ខ្ញុំ ។

**ស៖** លោកប្រាស្រ័យទាក់ទងក្នុងនាមជាសិស្សគ្រូ ជាមួយនឹងគាត់ហ្នឹងអស់រយៈពេលប៉ុន្មានឆ្នាំ?

**ឆ៖** គិតចាប់ពីឆ្នាំ១៩៦៥ ទៅ ៦៦, ១៩៦៦ ទៅ ៦៧, ១៩៦៧ ទៅ ១៩៦៨ ។ ក្នុងរយៈបីឆ្នាំ ។

**ស៖** កាលនោះ លោករៀនជាមួយគាត់ហ្នឹង គាត់បង្រៀននៅថ្នាក់ទីប៉ុន្មានដែរ? អត់សំឡេងទេ លោកអាចភ្លេច ចាំរង់ចាំបង្អង់បន្តិច សូមឆ្លើយ ។

តើកាលដែលលោកប្រាស្រ័យទាក់ទង ជាមួយនឹងគាត់ក្នុងរយៈពេលបីឆ្នាំនោះ តើកាលនោះហ្នឹង លោករៀននៅថ្នាក់ទីប៉ុន្មានដែរជាមួយហ្នឹងគាត់? ហើយកាលនោះ គាត់បង្រៀនមុខវិជ្ជាអ្វីនៅទីនោះ?

[១១:៤១:១៨]

**ឆ៖** នៅឆ្នាំ១៩៦៥ ទៅដល់ទល់៦៦ គាត់បានបង្រៀនខ្ញុំនៅថ្នាក់៣ អាទីបីទំនើបពីដើម គាត់បង្ហាត់នូវមុខវិជ្ជា គឺថាគណិតវិទ្យា ហៅ *ម៉ាតេម៉ាទិក* គណិតវិទ្យា និង *ហ្សេអូមេទ្រី* ។ គាត់បានបង្ហាត់ខ្ញុំនៅឆ្នាំ១៩៦៥ និង៦៦ ហ្នឹង ថ្នាក់ទី៣ ។

**ស៖** ចុះពីឆ្នាំ១៩៦៦-១៩៦៧?

**ឆ៖** នៅឆ្នាំ១៩៦៦ មក៦៧ ខ្ញុំរៀននៅហៅថាថ្នាក់ *សេហ្គុង* គឺថ្នាក់ទី២នោះ គាត់បានបង្រៀនជាមុខវិជ្ជាខ្មែរ ។

**ស៖** ចុះនៅឆ្នាំ១៩៦៧ និង១៩៦៨?

**ឆ៖** នៅឆ្នាំ១៩៦៧ និង ៦៨ទល់៦៨ គាត់បង្រៀនខ្ញុំនៅថ្នាក់ទី១ ទី១ទំនើប ពីដើមហៅថា *ម៉ាតេម៉ាទិក* គឺថា *ម៉ាតេម៉ាទិក* នៅថ្នាក់១ហ្នឹង ។ សាស្ត្រាចារ្យរបស់ខ្ញុំដែរ ក្នុងរយៈបីឆ្នាំហ្នឹង ។

**ស៖** លោក ទេព សែម ចូលលោកនិយាយរៀបរាប់ប្រាប់ដល់អង្គសវនាការ អំពីអត្តចរិតរបស់ជនជាប់ចោទឈ្មោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលលោកធ្លាប់បានដឹង បានកត់សម្គាល់នៅក្នុងអំឡុងពេលដែលលោកធ្លាប់ធ្វើប្រាស្រ័យទាក់ទងជាមួយនឹងគាត់រយៈពេលបីឆ្នាំ ចាប់ពីឆ្នាំ១៩៦៥ រហូតដល់ឆ្នាំ១៩៦៨ កាលនោះក្នុងនាមទំនាក់ទំនងជាសិស្សគ្រូ តើលោកកត់សម្គាល់ ឬក៏សង្កេតឃើញអត្តចរិតរបស់គាត់យ៉ាងណាដែរ?

**ឆ៖** ពេលដែលធ្លាប់ជួបប្រាស្រ័យទាក់ទងជាកូនសិស្សនិងគ្រូ ដូចឆ្នាំដែលខ្ញុំបានរៀបរាប់ពី១៩៦៥ មក៦៦, ពី៦៦មក៦៧, ពី៦៧មក៦៨ ហ្នឹង អត្តចរិតរបស់គាត់ជា មនុស្សស្លូតបូត ត្រឹមត្រូវល្អ មិនប្រកាន់វណ្ណៈ ហ្នឹងចរិតរបស់គាត់ ។ ទុកកូនសិស្ស គឺថាទៅវិញទៅមក មិនយក គេហៅថាប្រើសិទ្ធិរបស់គាត់មកគាបសង្កត់លើកូនសិស្សនោះ អត់ទេ គឺថាសឹងថាស្មើគ្នា ។

[១១:៤៤:៤៣]

**ស៖** មានសង្កេតឃើញអ្វីទៀតទេ? គាត់កាចទេ នៅពេលដែលគាត់បង្រៀនលោក ដូចជាបីថ្នាក់បានន័យថាមានការកត់សម្គាល់យ៉ាងច្បាស់ហើយ ហើយកម្រិតនៃការយល់ដឹងរបស់លោកកាលនោះ កម្រិតរៀនថ្នាក់ទី៣ ថ្នាក់ទី២ ថ្នាក់ទី១ ហ្នឹង ក៏ជាកម្រិតនៃការយល់ដឹងខ្ពស់ដែរ ហើយសម័យនោះគឺមានមនុស្សបានទទួលការរៀនសូត្រ ការបណ្តុះបណ្តាលហ្នឹង ការអប់រំនេះបានតិចតួចណាស់ ។

បានន័យថានៅក្នុងសង្គមកម្ពុជាអ្នកដែលរៀនកម្រិតនេះ គឺមានមនុស្សតិចទេ កាលសម័យនោះ។ តើលោកមានកត់សម្គាល់ឃើញអាកប្បកិរិយាក្នុងការបង្ហាត់បង្រៀន ឧទាហរណ៍ដូចជា សិស្សខ្សោយ ឬក៏សិស្សទីទ័លក្រ ឬក៏មានការមកយឺតចូលយឺត ឬក៏មានការអវត្តមានអីជាដើម តើការប្រព្រឹត្តិរបស់គាត់ចំពោះសិស្សដូចដែលយើងបានរៀបរាប់អ៊ីចឹង តើលោកកត់សម្គាល់ឃើញយ៉ាងដូចម្តេចដែរ?

**ឆ៖** បាទ, ក្នុងការកត់សម្គាល់របស់ខ្ញុំក្នុងរយៈបីឆ្នាំហ្នឹង គឺថាការសិក្សាគាត់បង្រៀនមកលើយើងខ្ញុំបាទនេះគឺថាត្រឹមត្រូវតាមពេលតាមវេលាកំណត់ម៉ោងវាងវៃណាស់ មិនធ្វេសមិនប្រហែសក្នុងការងារដែលគាត់ធ្វើទេ កាលជំនាន់ហ្នឹង ។ គឺថាកាន់ការងារអីគឺគាត់ប្រាកដក្នុងការងាររបស់គាត់ ធ្វើឲ្យកូនសិស្សចូលចិត្តស្រលាញ់គ្រប់ៗគ្នាហ្នឹង ។

**ស៖** ចុះគាត់បានសម្តែងប្រតិកម្ម ឬក៏ការធ្វើ សម្តែងនូវអាការៈ ឬក៏អាកប្បកិរិយាយ៉ាងម៉េចដែរចំពោះសិស្សខ្ជិល ឬក៏សិស្សដែលមិនគោរពវិន័យសាលាជាដើម?

**ឆ៖** ចំពោះសិស្សខ្ជិល សិស្សមិនគោរពវិន័យគាត់មិនដែលបានធ្វើបាបអីទេ គ្រាន់តែដាស់តឿនឲ្យខំសិក្សារៀនសូត្រ ដាស់តឿនឲ្យរៀនសូត្រ ឲ្យបង្កើតជាក្តីបអីរៀនសូត្រអ៊ីចឹង យកចិត្តទុកដាក់ខំរៀនអ៊ីចឹងទៅ គ្រាន់តែប៉ុណ្ណឹង អត់មានទៅអីខុស ។

**ស៖** ក្រៅពីកិច្ចការនេះតើវាមានកិច្ចការអីទៀតដែលលោកកត់សម្គាល់ដែរឬទេ? ដូចជាចំពោះអ្នកក្រីក្រ សិស្សក្រីក្រ ឬក៏គ្រូបង្រៀនដូចគ្នា ប៉ុន្តែមានជីវភាពក្រីក្រដោយសារមូលហេតុនៃកូនច្រើន ឬក៏ទិដ្ឋភាពផ្សេងៗគ្នា នាំឲ្យមានការបញ្ហាជួបលំបាកនៅក្នុងជីវភាពរស់នៅ តើអាកប្បកិរិយារបស់គាត់នឹងសម្តែងចំពោះអ្នកដែលក្រីក្រ អ្នកដែលទន់ខ្សោយជាងគាត់ហ្នឹង យ៉ាងដូចម្តេចដែរ?

**ឆ៖** ចំពោះកូនសិស្សក្រីក្រតាមដែលខ្ញុំសង្កេតមកគឺថា ជួយបង្ហាត់ដោយអត់យកថ្លៃគឺគាត់ហៅកូនសិស្សទាំងអស់ហ្នឹងដែលបានមួយថ្នាក់ ឬពីរថ្នាក់ទៅបង្ហាត់ជាគួរអ៊ីចឹងគាត់អត់យកតម្លៃទេ អត់មានយក ថ្លៃអីពីកូនសិស្សទេ ជួយៗកូនសិស្សផ្តល់ចំណេះវិជ្ជាឲ្យកូនសិស្សដើម្បីឲ្យចេះដឹង ។

[១១:៤៨:០៦]

**ស៖** ចុះកាលដែលគាត់ប្រាស្រ័យទាក់ទងជាមួយនឹងសង្គមដូចជាជាមួយនឹងគ្រូបង្រៀនដូចគ្នាក៏ដូចជាបុគ្គលិកនៃវិទ្យាល័យដែលគាត់បានទៅបង្រៀននៅទីនោះ តើលោកកត់សម្គាល់ឃើញយ៉ាងម៉េចដែរ?

**ឆ៖** ចំពោះបុគ្គលិកខ្លួនគាត់ផ្ទាល់តាមការអង្កេតរបស់ខ្ញុំគឺ មិនដែលឃើញគាត់បានជាល្អក់កករទាស់គ្នាអីក៏មិនដែលឃើញដែរ មិនដែលឃើញគាត់ទាស់គ្នា ព្រោះគាត់ទោះបីថាគេគិតឃើញយ៉ាងម៉េចថាស្អប់ ស្រលាញ់គាត់យ៉ាងម៉េចតែគាត់មិនអ្នកថា រករឿង ឈ្លោះវៃ ទៅប្រកាន់ទៅអីនឹងចំពោះមិត្តភក្តិគ្រូដូចគ្នានោះ អត់ទេអាន៎ុងមិនដែលសង្កេតឃើញទេ ធ្លាប់តែបបួលដាស់តឿនទៅមានគ្រូមួយ គ្រូពីរអ៊ីចឹងទៅបង្ហាត់គួ អត់យកលុយមាន ។ កាលនោះមានពីរ លោកគ្រូជាគ្រូពូកម៉ាក់ គាត់ហៅប្រូហ្វេសើគាត់ហ្នឹង នាយកសាលាផង ហៅឈ្មោះ កៅ តិចខន បានទៅបង្រៀនជាមួយនឹងគាត់ដែរ គាត់អត់យកលុយដូចគ្នា បានពីរនាក់ហ្នឹង ។

**ស៖** ចុះជាមួយនឹងមជ្ឈដ្ឋានសង្គមខាងក្រៅផ្សេងទៀត ដូចជាសង្គមដែលគាត់រស់នៅ ដែលលំនៅដ្ឋានរបស់គាត់រស់នៅក្នុងភូមិនៅទីកន្លែងដែលគាត់រស់នៅស្នាក់នៅ ដើម្បីគាត់ធ្វើគ្រូកាលណោះ តើលោកមានសង្កេតឃើញថា ការប្រាស្រ័យទាក់ទងជាមួយនឹងពលរដ្ឋនៅក្នុងសង្គមសហគមន៍ដែលគាត់រស់នៅនោះយ៉ាងម៉េចដែរ ធ្លាប់មានការបង្កទំនាស់ទាស់ទែងជាមួយនឹងអ្នកដទៃដែរឬទេ? ឬក៏ទំនុកបម្រុយ៉ាងដូចម្តេចដែរ?

**ឆ៖** នៅក្នុងសង្គមការរស់នៅរបស់គាត់ គាត់និងខ្ញុំបាននៅឆ្ងាយពីគ្នាដែរ ដូច្នេះខ្ញុំវាមិនសូវបានសង្កេតឃើញថាគាត់និងប្រជាជនហ្នឹងយ៉ាងម៉េចទេ អាហ្នឹងខ្ញុំតាមអត់ដឹងអត់ឃើញដែរ ។ អត់ដឹងអត់ប៊ានថាទេ ។

**ស៖** ក្រៅពីសកម្មភាពនៃការបង្រៀន ហើយនិងមានទឹកចិត្តនៅក្នុងការអនុគ្រោះ ដល់យោគយល់ដល់សិស្សហើយនិងមានចរិតឬកពាស្លូតបូតល្អមិនចេះប្រកាន់ខ្លួន ឬក៏ប្រកាន់ឫក អានោះសួរថាតើគាត់ធ្វើអ្វីខ្លះដែរទេ បង្កើតស្នាដៃអ្វីខ្លះនៅក្នុងអំឡុងពេលដែលគាត់ទៅបង្រៀននៅវិទ្យាល័យនោះ?

**ឆ៖** កាលណោះពេលរយៈគាត់ពេលក្នុងបីឆ្នាំហ្នឹង ដូចថា ឃើញតែការធ្វើដាស់តឿនកូនសិស្ស បង្រៀនយកចិត្តទុកដាក់ក្នុងវិន័យជាគ្រូបង្ហាត់សិស្សទាន់ពេលម៉ោងវេលា អនុវត្តត្រឹមត្រូវ និងជួយកូនសិស្សក្នុងការបង្រៀនក្នួអត់យកថ្លៃយកអីហ្នឹង ។ អាហ្នឹងការសង្កេតរបស់ខ្ញុំ ។ ក្រៅពីហ្នឹងខ្ញុំអត់បានដឹងដែរ អត់ ។

[១១:៥១:១០]

**ស៖** ចុះអំពីផ្នែកខាងនយោបាយវិញ តើកាលពីឆ្នាំសិក្សាដែលលោកបានសិក្សាជាមួយគាត់បីឆ្នាំការបង្ហាត់បង្រៀនរបស់គាត់ ឬក៏ដូចជាទស្សនៈនយោបាយរបស់គាត់ដែលបានបញ្ចេញឲ្យលោកដឹង ឬក៏កូនសិស្សផ្សេងទៀតដឹងទេថា គាត់ហ្នឹងជាមនុស្សមាននិន្នាកាក្រហម បានន័យថា នៅមាននិន្នាការដែលលទ្ធិកុម្មុយនីស្តនៅក្នុងសម័យនោះ ពីព្រោះសម័យ ៦៦, ៦៧, ៦៨ ហ្នឹងដូចជាមានទំនោរនៅក្នុងសង្គមខ្មែរនៅក្នុងស្រទាប់គ្រូបង្រៀន តាមសាលានានា ក៏ដូចជាស្រទាប់កសិករ ឃើញថាមានការជជែកពិភាក្សាជាច្រើនអំពីបញ្ហាលទ្ធិកុម្មុយនីស្ត ។ តើកាលពីលោករៀនលោកហ្នឹង តើលោកបានស្តាប់នូវការជជែកវែកញែក ឬក៏ការនិយាយមកកាន់លោកអំពីលទ្ធិកុម្មុយនីស្តដែរឬទេ?

**ឆ៖** កាលពីក្នុងឆ្នាំសិក្សាហ្នឹងគឺថា បាន១ខ្លះដែរ ដឹងត្រង់ថា ពេលចុងម៉ោងទៅគាត់ពិភាក្សាលេងពីរឿងកសិករ លើកសិករកណ្តាល កសិករក្រោមអីចឹង វណ្ណៈនាយទុន អទុនអីប៉ុណ្ណឹង ដឹងតែប៉ុណ្ណឹង ទេខ្ញុំ ។ អាហ្នឹងជាការពិត ។

**ស៖** លោកបានដឹងនូវព្រឹត្តិការណ៍នៃតម្រួតសម័យសង្គមនិយមក្នុងអំឡុងឆ្នាំ ចន្លោះក្នុងអំឡុងទស្សវត្សរ៍៦០ ហ្នឹង មានការចាប់ខ្លួនគាត់ដែរឬទេ? ព្រឹត្តិការណ៍នៃការចាប់ខ្លួន ។

**ឆ៖** កាលនៅទសវត្សរ៍៦០ ហ្នឹង គ្រាន់តែដឹងថាចាប់ខ្លួន តែមិនដឹងថាចាប់ខ្លួនពីរឿងម៉េចអីម៉េចផង អត់ដឹងចាប់ពីរឿងអី គឺបែកគ្នាត្រឹមឆ្នាំ១៩៦៨ លែងជួបគាត់ទៅ អត់ដឹងដែរទេ ។

**ស៖** កាលនោះលោករៀនថ្នាក់ទីមួយជាមួយគាត់ហ្នឹងរៀនបានចប់ទេ? ចប់ឆ្នាំទេ? ឬក៏បាត់ខ្លួនគាត់មុនពេលកម្មវិធីសិក្សាត្រូវបានបញ្ចប់?

**ឆ៖** មិនចាំដែរ ដូចជាវាក់នៅពេលនុ៎ង ដូចជាវាក់ដែរ ដូចជាចប់មិនដឹង មិនចប់ទេក៏មិនដឹងអាហ្នឹង សូមទោសចុះ ព្រោះខ្ញុំមិនចាំដែរទេ ប៉ុនបានរៀន គឺថាបានរៀននៅថ្នាក់ទីមួយហ្នឹងបានរៀន ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអីសួរដល់សាក្សីរូបនេះដែរឬទេ?

ជាបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាដើម្បីសួរសំណួរទៅកាន់សាក្សីរូបនេះ ។ ប្រសិនបើមានសំណួរសូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**លោក តាន់ សេណារ៉ុង៖**

**ស៖** អរគុណលោកប្រធានអង្គជំនុំជម្រះ និងសូមស្វាគមន៍លោក ទេព សែម ។ សំណួរទីមួយរបស់ខ្ញុំជូនលោក សួរថាតើនៅពេលដែលលោកជាសិស្សរបស់គាត់នៅពេលនោះ តើលោកដែលធ្លាប់ត្រូវបានលោកនិយាយជម្រាបអង្គជំនុំជម្រះអម្បាញ់មិញថាលោកបានដឹងពីទំនោរនៃលទ្ធិកុម្មុយនីស្តខ្លះៗដែលគាត់ធ្លាប់បានជួបលោកនិយាយពីវណ្ណៈនាយទុន និងកសិករ ។ តើនៅពេលនោះក្នុងនាមគាត់ជាគ្រូបង្រៀនគណិតវិទ្យារបស់លោកនោះ ថាតើគាត់ហ្នឹងមានបានណែនាំលោកថា គួរយើងចុះចូលនិងរួមចលនា និងរួមដៃគ្នាដើម្បីនឹងធ្វើបដិវត្តន៍ហ្នឹង ទេលោក?

**ឆ៖** បាទ, នៅពេលនោះគឺថា គាត់គ្រាន់បានតែចុងៗម៉ោង ហើយគាត់មានប្រសាសន៍និយាយលេងសើចទេ តែការបបួលអីហ្នឹងគាត់មិនដែលបបួលទេ ។

**ស៖** អរគុណលោក ។ តើនៅក្នុងឆ្នាំសិក្សារបស់លោកដែរនោះ លោកមានចាប់អារម្មណ៍ទេថាតើចលនាកុម្មុយនីស្តដែលហៅថាចលនាខ្មែរក្រហមនោះមានការផុលផុសទេ នៅក្នុងស្រទាប់បញ្ញវន្តជាពិសេសនៅសាលាវិទ្យាល័យជើងព្រៃនោះ ?

**ឆ៖** នៅពេលនោះគ្រាន់តែយល់ថា វាមានចលនាខ្លះៗ តែមិនដឹងជាធ្វើសកម្មភាពអ្វីៗផ្សេងៗទៀត អាហ្នឹងគឺខ្ញុំអត់បានដឹងទេ មិនដឹងថាមានយ៉ាងនេះ មានយ៉ាងនោះ ប៉ុន្តែមិនដឹងថាធ្វើសកម្មភាពអីមិនដឹងថាលេចត្រឹមណាមក ពីខាងណាមកអត់ដឹងដែរទេ ។

**ស៖** អរគុណលោក នៅពេលដែលលោកជាសិស្សរបស់គាត់នោះ ក្នុងពេលនោះលោកជាសិស្សម្នាក់ពូកែដែរទេ? នៅពេលនោះ?

**ឆ៖** នៅពេលនោះខ្ញុំបាទ ជាសិស្សមិនជាសិស្សពូកែទេ គ្រាន់តែជាកូនសិស្សមធ្យម រៀនបានមធ្យម ។

**ស៖** អរគុណលោក ទេព សែម ខ្ញុំអស់សំណួរជូនលោកហើយ ។ ខ្ញុំនឹងបង្វែរសំណួរនេះទៅសហ ការីរបស់ខ្ញុំដើម្បីសួរលោកបន្ត និងអរគុណលោកប្រធានអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្មាឯល៖**

[១១:៥៧:៥៥]

**ស៖** សូមអរគុណលោកប្រធាន ។ សួស្តីលោកសាក្សី ខ្ញុំមានសំណួរខ្លីមួយចំនួនសម្រាប់សួរលោក ។ ដំបូងតើជនជាប់ចោទមានបង្ហាញអំពីអំណាចរបស់គាត់តាមលក្ខណៈធម្មជាតិទេ ឬក៏គាត់ហ្នឹងទទួលបានការគោរពពីសិស្សរបស់គាត់? ឬក៏តើអំណាចរបស់គាត់ហ្នឹងដែលត្រូវបានសិស្សធ្វើការចោទសួរដែរឬទេ?

**ឆ៖** កាលនោះក្នុងអំឡុង ក្នុងអំឡុងបីឆ្នាំហ្នឹង ពីព្រោះភាតរភាពរវាងសិស្សនិងគ្រូហ្នឹង កូនសិស្សមិនដែលបានចោទសួរពីគាត់យ៉ាងម៉េចៗអត់ទេ ចេះតែស្រួលទៅតែម្តង ថាស្រួលសហការគ្នាស្រួលទៅ។ អត់មានបានទំនាស់ទាស់កូនសិស្សដេញដោលអីយ៉ាងម៉េចក៏គ្មានដែរ ព្រោះគាត់ជាភាតរភាពចង់ស្មើគ្នាទៅហើយ ។

**ស៖** តើគាត់បានផ្តល់នូវឋានៈប្រហាក់ប្រហែលគ្នាហ្នឹងទៅឲ្យលោកដែរឬទេ ដើម្បីឲ្យគាត់ហ្នឹងហើយមានឋានៈដូចថាមានភាពស្និទ្ធស្នាលជាមួយនឹងកូនសិស្សរបស់គាត់នោះ?

**ឆ៖** បាទ, គាត់ផ្តល់ឋានៈឲ្យដល់ខ្ញុំបាទ ក៏ខ្ញុំបាទជាសិស្សទូទៅហ្នឹង ក៏ដូចតែគ្នាអត់ដែលប្រកាន់ដែលអីទេ ។ ឡើងចុះ លេងសើចយ៉ាងម៉េចៗក៏គាត់មិនដែលប្រកាន់ដែរ ។

[១២:00:00]

**ស៖** ដូច្នេះភាពជិតស្និទ្ធរវាងលោកជាមួយនិងគ្រូរបស់គាត់ហ្នឹង តើជាឱកាសមួយដើម្បីឲ្យគាត់មានឥទ្ធិពលទៅលើការគិតរបស់គាត់ អំពីផ្នត់គំនិតរបស់គាត់ និងអំពីរបៀបដែលលោកសិក្សាដែរឬទេ?

**ឆ៖** ក្នុងន័យនេះ គឺថាការស្និទ្ធស្នាល ការយល់ឃើញរបស់គាត់ អាហ្នឹងខ្ញុំមិនដឹងដែរ ក្នុងចិត្តសន្និដ្ឋានរបស់គាត់មិនដឹងយ៉ាងម៉េច ។

**ស៖** ដោយសារតែលោកស្គាល់គ្រូរបស់លោកច្បាស់ ដោយសារតែលោកស្គាល់គាត់បីឆ្នាំ តើគាត់ជាគំរូសម្រាប់លោក និងសម្រាប់សិស្សដទៃទៀតដែរឬទេ? តើលោកគោរព និងកោតសរសើរគាត់ដែរឬទេ?

**ឆ៖** បាទ,ក្នុងអំឡុងបីឆ្នាំហ្នឹង ជាអតីតហ្នឹងគឺថាអាចចាត់ទុកថា គឺគោរព គាត់ធ្វើបានត្រឹមត្រូវ មែន អាហ្នឹងកាលពីក្នុងអំឡុងនោះ ។

**ស៖** តើគាត់ធ្វើអ្វីៗដើម្បីឲ្យសិស្សគាត់កោតសរសើរ និងគោរពគាត់ដែរឬទេ? តាមអ្វីដែលលោកបានដឹង?

**ឆ៖** គាត់ធ្វើអ្វីៗទាំងអស់ហ្នឹង គឺការដែលគាត់ធ្វើហ្នឹង ហ្មត់ចត់ ដូចជាបង្រៀន ដូចអីអ៊ីចឹង ។ ដូច្នេះ ដល់គាត់ធ្វើសកម្មភាពនឹងជារាល់ពេល រាល់វេលា រាល់ឆ្នាំទៅ កូនសិស្សកាន់-- កូនសិស្សចេះតែស្រឡាញ់គាត់ជាបន្តបន្ទាប់អ៊ីចឹងទៅ ។ ហ្នឹងការងាររបស់គាត់ ។

**ស៖** ប្រសិនបើលោកយកចិត្តទុកដាក់ ហើយនិងមានភាព សុភាពរាបសារគោរពគាត់ ។ អ៊ីចឹងបានន័យថា គាត់ទទួលបានកិត្តិយស និងទទួលបាននូវតួនាទី និងការគ្រប់គ្រងថ្នាក់យ៉ាងល្អ នៅពេលដែលគាត់បង្រៀននោះ ។

**ឆ៖** អត់យល់ ។ ពេលនេះ ខ្ញុំអត់យល់សំណួរ ចង់និយាយយ៉ាងដូចម្តេច?

**ស៖** ដោយសារតែគាត់យកទុកដាក់ ហើយគាត់ចិត្តល្អ ចំពោះសិស្សដែលមក ដែលមានប្រវត្តិពីជាកូនកសិករ ហើយគាត់អាចជួយ និងជួយបង្រៀនសិស្សដទៃទៀត នៅក្នុងថ្នាក់ ។ ដូច្នេះហើយ ថាតើជនជាប់ចោទនោះ ដោយសារតែការចិត្តល្អរបស់គាត់នោះហើយ ទើបគាត់ទទួលបានកេរ្តិ៍ឈ្មោះល្អ ហើយធ្វើឲ្យគាត់អាចគ្រប់គ្រងបាននៅក្នុងថ្នាក់របស់គាត់ តើអ៊ីចឹងមែនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! ខ្ញុំជឿថាសំណួរនេះ គឺពិបាកណាស់សម្រាប់សាក្សីក្នុងការឆ្លើយ ។ គាត់មិនមែនជាអ្នកជំនាញទេ ។ គាត់គ្រាន់តែជម្រាបនូវអ្វីដែលគាត់បានឃើញ ហើយវាពិបាកណាស់នៅពេលដែលសួរសំណួរថា តើជនជាប់ចោទទទួលបានកិត្តិយសដែរឬទេ? សំណួរនេះ គួរតែលោកសួរទៅអ្នកជំនាញចិត្តសាស្ត្រវិញទៅ កុំសួរមកកាន់សាក្សីដែលមានវត្តមាននៅទីនេះ ។

[១២:០៤:៣០]

**សួរដោយលោក វាំងសង់ ដឺវ៉ាយដ៍ ដេស្វាងឈ៖**

**ស៖** ខ្ញុំសូមកែតម្រូវសំណួររបស់ខ្ញុំ ។ បានន័យថានៅពេលដែលគាត់ចិត្តល្អ និងយកចិត្តទុកដាក់ចំពោះសិស្សទាំងឡាយ ។ អ៊ីចឹងការដែលគាត់យកចិត្តទុកដាក់ និងចិត្តល្អនោះ ធ្វើឲ្យគាត់ទទួលបាននូវការគោរពស្រឡាញ់ ហើយនិងគាត់បានផ្តល់ជះឥទ្ធិពលផ្សេងៗទៅដល់សិស្សគាត់ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ, គាត់ សកម្មភាពដែលគាត់ធ្វើ គឺថាជះឥទ្ធិពលត្រឹមកូនសិស្សស្រឡាញ់រាប់អានគាត់ចូលចិត្តទៅរៀនជាមួយគាត់ គាត់បើកជាគួរជាអីហ្នឹង គឺកូនសិស្សចូលចិត្ត មិនបាច់ចាំ ដូចថា ពាក្យខ្មែរយើងថា “មិនចាំបបួលច្រើនទេ ឲ្យតែប្រាប់ទៅ ហៅទៅ ទៅហើយ” ហ្នឹងគ្រាន់ថាអ៊ីចឹង និយាយសាមញ្ញទៅចុះ ។

**ស៖** ខ្ញុំនៅសំណួរចុងក្រោយមួយទៀត ចំពោះទំនាក់ទំនងជាមួយមេរបស់គាត់ គឺជនជាប់ចោទការទាក់ទងជាមួយនឹងប្រធានរបស់គាត់ ថាតើគាត់ចង់ឲ្យសិស្សរបស់គាត់គោរពគាត់ដែរឬទេ? ដើម្បីឲ្យវាដូចទៅនឹងអ្វីដែលគាត់គោរពមេរបស់គាត់ ដូចជានាយកសាលាអ៊ីចឹងដែរ និងគ្រូផ្សេងៗទៀត តើគាត់មានចង់ឲ្យសិស្សធ្វើការគោរពអ៊ីចឹងដូចគាត់ដែរឬទេ?

**ឆ៖** បាទ, ធម្មតាពេលនោះ មិនថាជាគាត់ ឬជាគ្រូដទៃទៀតទេក្នុងការចង់ឲ្យគោរពហ្នឹង គឺថាអង្កាល់នោះ កូនសិស្សជំនាន់ពីឆ្នាំអំឡុងបីឆ្នាំ ឬមុនបីឆ្នាំហ្នឹង គឺគោរពកោតខ្លាចគ្រូជាងសព្វថ្ងៃនេះ ។

**លោក វាំងសង់ ដឺវ៉ាយដ៍ ដេស្សាឯល៖**

ខ្ញុំសូមអរគុណលោកច្រើន ខ្ញុំពុំមានសំណួរបន្ថែមទៀតទេ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ អាឡាំង វ៉ែនណឺ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណ លោកប្រធាន ។ ជាសាក្សីថ្មី ដូច្នេះហើយខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីឲ្យលោកប្រធានជម្រាបសាក្សីអំពីមូលហេតុអ្វីបានជាដើមបណ្តឹងរដ្ឋប្បវេណីមិនចូលរួមនៅទីនេះ ។ ដោយសារតែសាក្សីគាត់មិនយល់អំពីហេតុក្នុងការមិនអនុញ្ញាតឲ្យមេធាវីសួរសំណួរ ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីទៅកាន់សាក្សីនោះទេ ។ សូមអញ្ជើញលោកប្រធាន ។

[១២:០៧:៤៥]

**ប្រធានអង្គជំនុំ៖**

លោក អាឡាំង វ៉ែនណឺ ហាក់ដូចជាមានជំនាញខាងនិយាយច្រឡំដែរណាស់ មែនទេ?

យើងមិននិយាយច្រឡំដែរទេ ហើយមិនអនុញ្ញាតឲ្យលោកនិយាយទៀតទេ ។

ជនជាប់ចោទ កាំង ហ្គេកអ៊ាវ អម្បាញ់មិញនេះ លោកបានស្តាប់ហើយអំពីបំណងប្រាថ្នារបស់សាក្សី ស៊ូ សាត ដែលមានការបង្ហើបនៃបំណងនេះដោយមេធាវីរបស់លោក ហ្វ្រង់ស្វ័រ រ៉ូ ។ តើលោកអនុញ្ញាត ឬក៏មានបំណងអនុញ្ញាតឲ្យ ស៊ូ សាត ហ្នឹង បានជួបប្រាស្រ័យទាក់ទងសួរសុខទុកលោកដែរឬទេ?

**ជនជាប់ចោទ៖**

ខ្ញុំសូមគោរពលោកប្រធាន ។ ខ្ញុំទាំងពីរនាក់ស្រឡាញ់រាប់អានគ្នាណាស់ បែកគ្នាយូរហើយ ចង់ជួបគ្នា ។ ដូច្នេះសូមលោកប្រធាន អនុគ្រោះឲ្យបានជួបគ្នា ខ្ញុំអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យ ស៊ូ សាត នឹងប្រាស្រ័យទាក់ទងជាមួយលោក ហើយមន្ត្រីអនុរក្សមន្ទីរឃុំឃាំង ជាមួយនិងក្រឡាបញ្ជី សម្របសម្រួលដើម្បីឲ្យគាត់បានប្រាស្រ័យទាក់ទងគ្នា នៅក្នុងអំឡុងពេលសម្រាកពិសារអាហារថ្ងៃត្រង់នេះ ។

ហើយអង្គជំនុំជម្រះ សូមជម្រាបដល់ជនជាប់ចោទផងដែរ ថាសាក្សី-- សក្ខីកម្មអំពីអត្តចរិតទាំងប្រាំមួយរូបនេះ អង្គជំនុំជម្រះនឹងឲ្យលោកធ្វើការកត់ស្គាល់ជាសរុប ដូច្នេះ សូមលោកធ្វើការកត់សម្គាល់ជាបណ្តើរៗ ដើម្បីមានលទ្ធភាព ធ្វើការកត់សម្គាល់ជាសរុបនៅចុងក្រោយ ។

ឥឡូវនេះ ដល់ពេលត្រូវពិសារអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារ ហើយដំណើរការសវនាការគឺលើកទៅបន្ត នៅរសៀលចាប់ពីម៉ោងមួយ និងសាមសិបនាទី ។ ហើយអរគុណដល់លោក ទេព សែម ដែលអញ្ជើញមកដំណើរការចូលរួមសវនាការតាមការកោះហៅរបស់តុលាការ ។ ក៏ប៉ុន្តែដោយសារតែហេតុផលនៃពេលវេលា គឺការធ្វើសក្ខីកម្មរបស់លោកមិនទាន់ចប់ទេនៅភាគីខាងមេធាវីការពារក្តីត្រូវតាំងសំណួរចំពោះលោកទៀត ។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកនៅរសៀលនេះ ចាប់ពីម៉ោងមួយសាមសិននាទីដើម្បីលោកបន្តធ្វើសក្ខីកម្មដោយឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តី ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយនាំគាត់ត្រឡប់មកវិញ មកសាលសវនាការវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកនៅម៉ោង១២:១១នាទីដល់ម៉ោង ១៣:៣៣នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តីដើម្បីមានឱកាសក្នុងការសួរដល់សាក្សីរូបនេះ ប្រសិនបើមានសំណួរត្រូវសួរ ។ សូមអញ្ជើញ ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល ។

**ស៖** លោក សែម លោកបានធ្វើជាកូនសិស្ស លោកគ្រូ កាំង ហ្គេកអ៊ាវ នៅពេលនោះ អស់រយៈពេលបីឆ្នាំ ។ ខ្ញុំសួរថា តើក្នុងរយៈពេលបីឆ្នាំនេះ លោកដែលឮសិស្សណាម្នាក់ ឬក៏បុគ្គលិកណាមួយ ឬក៏គ្រូណាម្នាក់ ដែលរិះគន់អំពីលោកគ្រូ កាំង ហ្គេកអ៊ាវ នេះឬទេ? មានដែរទេ? មានដែលឮទេ? សូមលោកបញ្ជាក់ ។

**ឆ៖** ក្នុងអំឡុងបីឆ្នាំនេះ ចំពោះកូនសិស្ស លោកគ្រូ អ្នកគ្រូ ដែលនៅក្នុងអំឡុងបីឆ្នាំ ខ្ញុំមិនដែលបានជាឮផ្ទាល់ត្រចៀកទេ ពីព្រោះកិច្ចការអស់នេះ ទោះបីខាងគាត់រិះគន់ក៏ខ្ញុំអត់ដឹងដែរ ជៀលរិះគន់គ្នាគាត់ខ្ញុំអត់ដឹង ។

**ស៖** សូមអរគុណ ។ អ៊ីចឹងលោកអត់ដែរឮទេ បើលោកមិនដែលឮទេ អ៊ីចឹងយើងអាចនិយាយបានថា សិស្សទាំងអស់ ឬក៏គ្រូទាំងអស់ ឬបុគ្គលិកទាំងអស់ហ្នឹង គាត់អាចថា ស្រឡាញ់រាប់អានលោកគ្រូ កាំង ហ្គេកអ៊ាវ ហ្នឹងទាំងអស់គ្នា ។ អាចនិយាយបានអ៊ីចឹងបានទេ? សូមលោកបញ្ជាក់មើល?

**ឆ៖** បាទ, ក្នុងអំឡុងនោះ មិនដែលឃើញមានអាក់អន់ចិត្តទាស់ទែងគ្នាជាមួយរវាងបុគ្គលិកគ្រូ និងគ្រូ ខ្ញុំក៏អត់ដែលឃើញដែរទេ ។ ឃើញដល់ពេលម៉ោងធ្វើការងារ ចូលបង្រៀនៗ ចេញគឺចេញទៅតាមទម្លាប់របស់គាត់ជារៀងរាល់ខែអ៊ីចឹងទៅ ។

**ស៖** អ៊ីចឹងលោកអាចបញ្ជាក់បានថា គេអាច គេស្រឡាញ់គាត់គ្រប់ៗគ្នាដែរឬទេ?

**ឆ៖** ខ្ញុំមិននិយាយសន្និដ្ឋានថា គេស្រឡាញ់គាត់ទាំងអស់ទេ ពីព្រោះនៅក្នុងនោះមាន-- ក្នុងសាលាមានអ្នកគ្រប់គ្រងសាលាពីលើគាត់ទៀត ដឹងតែគេមានមតិយ៉ាងម៉េច? ហើយគេស្អប់យ៉ាងម៉េច? ស្រឡាញ់យ៉ាងម៉េច? ព្រោះខ្ញុំអត់ធ្លាប់អត់ដឹង អត់ឮ ដែលពិភាក្សានិយាយថាម៉េចៗ អត់ដែរឮ ។

[១៣:៣៦:៥៨]

**ស៖** សូមអរគុណ។ លោកព្រឹកមិញ លោកបានបញ្ជាក់ជូនអង្គសវនាការហើយថា លោក កាំង ហ្កេកអ៊ាវ នេះជាគ្រូម្នាក់ដែលមានអត្តចរិតស្លូតបូត ស្មោះត្រង់ រាប់អាន យកចិត្តទុកដាក់ជាមួយនឹងសិស្សគ្រប់ៗគ្នា ពិសេសសិស្សដែលក្រីក្រ ។ ហើយសិស្សដែលក្រីក្រ លោកបានបញ្ជាក់ប្រាប់អង្គសវនាការហើយថា គាត់ជួយបង្រៀនគួរនៅពេលវ៉ាកងក្ដី ពេលឈប់សម្រាកហ្នឹង គឺថាគាត់បង្រៀនកូនអ្នកក្រ គាត់អត់មានយកលុយទេ ។ អ៊ីចឹងមែនទេ ព្រឹកមិញ?

**ឆ៖** អ៊ីចឹង ព្រឹកមិញហ្នឹង ខ្ញុំបាទឆ្លើយដូច្នេះមែន ។

**ស៖** សូមអរគុណ ។ តើលោកដឹងទេថា លោក កាំង ហ្កេកអ៊ាវ ជាគ្រូហ្នឹង ដែលគាត់ជួយកូនអ្នកក្រ មិនគ្រាន់តែជួយបង្រៀន មិនយកលុយទេ តើលោកមានដែលដឹងថា គាត់មានយកកូនអ្នកក្រពីរបីនាក់អី ដែលក្រជាងគេនោះយកមក ដូចថាគ្នាវារកលុយជួលផ្ទះនៅមិនបានអី យកមកនៅជាមួយ តើលោកមានបានដឹងទេ រឿងហ្នឹង?

**ឆ៖** មិនបានដឹងដែរ ចំពោះដែលគាត់យកមកនៅជាមួយ ឃើញតែ-- ប៉ុន្តែកន្លែងគាត់នៅហ្នឹង ខ្ញុំឃើញតែ ខ្ញុំជិះកង់ចុះឡើង កាត់ចុះឡើងអ៊ីចឹងទៅ មុខផ្ទះគាត់ស្នាក់នៅ ឃើញមានចេញចូល មានគ្រាន់តែឃើញកូនសិស្សចូលលេងអ៊ីចឹងទៅ ។

**ស៖** បាទ, អរគុណ ។ អ៊ីចឹងចំពោះសិស្សដែលក្រ ដែលខ្វះសៀវភៅ ខ្វះប៊ិចអីហ្នឹង តើលោកជាកូនសិស្សហ្នឹង កាលជំនាន់នោះ លោកមានដែលឃើញថា លោកគ្រូ កាំង ហ្កេកអ៊ាវ នេះ ដែលជួយឧបត្ថម្ភដល់សិស្សក្ររបៀបនេះទេ?

**ឆ៖** បាទ, ចំពោះកូនសិស្សក្រហ្នឹងក៏គាត់-- ប៉ុនជាខ្លួនខ្ញុំផ្ទាល់ ខ្ញុំបានតែត្រឹមពាក្យសម្ដីប្រដៅណែនាំឲ្យខំរៀនសូត្រទេ តែចំពោះសិស្សដទៃទៀត ដែលក្រដែរ ត្រង់ថាគាត់ឲ្យយ៉ាងម៉េច អីយ៉ាងម៉េចអាហ្នឹង ខ្ញុំអត់បានដឹងផ្ទាល់ដែដែរទេ អត់ដឹងបានផ្ទាល់ខ្លួនដែរទេ ។

**ស៖** សូមអរគុណ ហើយលោកដែលធ្លាប់ទិញសៀវភៅសរសេរ សៀវភៅអីនៅក្នុងសហករណ៍របស់សិស្សទេជំនាន់ហ្នឹង? លោករកដឹងមើល តើមានសហករណ៍របស់សិស្សទេ ហើយលោកមានដែលមានបានទិញសៀវភៅពីសហករណ៍របស់សិស្សហ្នឹងទេ ដែលតម្លៃថោក?

**ឆ៖** បាទ, កាលក្នុងអំឡុងឆ្នាំនោះ ធ្លាប់ទិញសៀវភៅសហករណ៍នៅខាង-- កាលណោះគេមានទីតាំងនៅខាងកើតសាលាស្រុកជើងព្រៃ តែខ្ញុំមិនដឹងជាសហករណ៍ហ្នឹង កើតចេញមកពីប្រភពខាងណាទេ ខាងណាអ្នកតុបតែងនេះ ខ្ញុំអត់បានដឹងដែរ ។

**ស៖** សូមអរគុណ ។ លោកអត់បានដឹង គឺសហករណ៍របស់លោកគ្រូរបស់លោកហើយ ដែលជួយសិស្សក្រីក្រតាមមធ្យោបាយនេះ ។ អ៊ីចឹងលោកមានធ្លាប់បានដឹងទេ ចំពោះប្រជាជន មិនមែនថានៅជិតផ្ទះគាត់ទេ ប្រជាជនដែលធ្លាប់ស្គាល់លោកគ្រូ ឌុច ហ្នឹង ។ តើប្រជាជនទាំងនោះធ្លាប់រាប់អានគាត់ ហើយធ្លាប់មានដែលអាក់អន់ស្រពន់ចិត្តគាត់ អីរឿងអីដែរ ឬក៏យ៉ាងម៉េច? សូមលោកជួយបញ្ជាក់មើលកាលសម័យនោះ?

**ឆ៖** ក្នុងសម័យនោះ ខ្ញុំរឿងរវាងទំនាក់ទំនង រវាងប្រជាជន និងគាត់ គឺថាគាត់មិនសូវបានចេះឃើញជួបប្រជាជន ព្រោះប្រជាជនក៏គ្មានអីទំនាក់ទំនងជាមួយគាត់ដែរទេ ពីព្រោះគាត់ មុខងារគាត់ មកតែខាងសាលាបង្រៀននេះ ហើយតែគាត់ជួបគ្នា ក៏ខ្ញុំអត់ដឹង ក៏ថានៅឆ្ងាយពីគ្នាដែរ ដឹងយ៉ាងម៉េច ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ ។ សូមជម្រាបលោកប្រធាន យើងខ្ញុំទាំងពីរនាក់ជាមេធាវីការពារអស់សំណួរហើយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកសាក្សី ដែលលោកបានអញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតាមការកោះហៅ ហើយអង្គជំនុំជម្រះក៏បានដឹងដែរអំពីការលំបាកនៅក្នុងការឆ្លើយនៅសំណួរផ្សេងៗ ពីអង្គជំនុំជម្រះនិងភាគី ហើយអង្គជំនុំជម្រះក៏កត់សម្គាល់ឃើញថា លោកប្រឹងប្រែងក្នុងការឆ្លើយទៅតាមគ្រប់សំណួរ ដែលបានសួរពីអង្គជំនុំជម្រះ និងភាគី ។ ឥឡូវនេះដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោក ឃើញថា បានចប់ហើយ ។ ដូច្នេះ លោកអាចអញ្ជើញត្រឡប់ទៅលំនៅដ្ឋានរបស់លោកវិញ ឬក៏លោកអាចទៅកាន់កន្លែងសម្រាប់រៀបចំទុក សម្រាប់សាធារណជន អាចស្តាប់បន្ត ស្តាប់ដំណើរការសវនាការទៀតបាន ។ សូមអញ្ជើញទៅចុះ ។

ហើយមន្ត្រីតុលាការ អញ្ជើញសាក្សីមួយរូបទៀត ទេព សុខ ចូលមកកាន់សាលសវនាការ ។

*(លោក ទេព សុខ ចូលមកក្នុងបន្ទប់សវនាការ)*

[១៣:៤៥:00]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី តើលោកមានឈ្មោះអ្វី?

**ឆ៖** បាទ, ខ្ញុំបាទឈ្មោះ ទេព សុខ ។

**ស៖** លោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំ៦១ឆ្នាំ ។

**ស៖** តើទីលំនៅរបស់លោកបច្ចុប្បន្ននៅទីណា? ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វី?

**ឆ៖** ខ្ញុំនៅភូមិសង្កែពង ឃុំស្រម៉ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ មុខរបរខ្ញុំសព្វថ្ងៃជាកសិករ ។

**ស៖** លោក ទេព សុខ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា លោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងភាគីនៃរឿងក្តីនេះទេ ។ ហើយលោកបានស្បថរួចហើយ កាលពីព្រឹកមិញមុននឹងលោកអញ្ជើញចូលមកកាន់សាលសវនាការនេះ ។ តើការនេះជាការពិតដែរឬទេ?

**ឆ៖** ការនេះ គឺជាការពិត ។

**ស៖** តទៅនេះ អង្គជំនុំជម្រះសូមប្រាប់អំពី-- ។ អញ្ជើញ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន នៅក្នុងការបកប្រែមានការនិយាយថា គាត់គឺជាកសិករ បើទៅតាមការបកប្រែជាភាសាបារាំងថា *ខាលទីវើតធ័រ* ។ បើតាមការយល់ដឹងរបស់ខ្ញុំ គាត់ គឺជានាយកសាលាមួយ តើជាការត្រឹមត្រូវដែរឬទេ? បើសិនជាអ៊ីចឹងមែន គួរតែមានការកែប្រែនៅក្នុងប្រតិចារឹក ។

**ប្រធានអង្គជំនុំ៖**

**ស៖** លោក ទេព សុខ តើសព្វថ្ងៃនេះលោកប្រកបមុខរបររកស៊ីធ្វើអ្វី?

**ឆ៖** បាទ, ខ្ញុំពីដើមជានាយកសាលាអនុវិទ្យាល័យសាមគ្គីមានជ័យ តែឥឡូវនេះខ្ញុំរីត្រែត ហើយខ្ញុំក្លាយមកជាកសិករហើយ ។

[១៣:៤៨:២៤]

**ប្រធានអង្គជំនុំ៖**

ច្បាស់ទេលោក ហ្វ្រង់ស្វ័រ រូ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

បាទ, លោកប្រធានជាការត្រឹមត្រូវហើយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ក្នុងនាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ លោកអាចបដិសេធនៅក្នុងការឆ្លើយនឹងសំណួរ ឬក៏អំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យមានពិរុទ្ធភាពទៅលើខ្លួនលោក ។ ហើយទន្ទឹមនឹងនេះដែរ លោក ទេព សុខ ក្នុងនាមលោកជាសាក្សី លោកមានករណីកិច្ចនិយាយតែការណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮដោយផ្ទាល់ ។

**ស៖** លោក ទេព សុខ តើលោកធ្លាប់បានជួបប្រាស្រ័យទាក់-- តើពីមុនមកលោកធ្លាប់បានស្គាល់ជនជាប់ចោទឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែរឬទេ?

**ឆ៖** បាទ, កន្លងមក លោក កាំង ហ្គេកអ៊ាវ ជាសាស្ត្រាចារ្យគណិតវិទ្យា បានបង្រៀនខ្ញុំក្នុងអំឡុងឆ្នាំ១៩៦៧-៦៨ ។ បានស្គាល់លោកច្បាស់ ។

**ស៖** កាលដែលលោកមានការប្រាស្រ័យទាក់ទងគាត់ក្នុងនាមគាត់ជាសាស្ត្រាចារ្យ ហើយលោកជាសិស្សកាលណោះ តើកាលដែលលោកបង្រៀន និងលោករៀននោះនៅសាលាឯណាដែរ? ហើយការបង្រៀនរបស់គាត់ហ្នឹង គាត់បង្រៀនលោកមុខវិជ្ជាអ្វីទៅ?

**ឆ៖** បាទ, លោក កាំង ហ្គេកអ៊ាវ ជាសាស្ត្រាចារ្យបង្រៀនគណិតវិទ្យានៅវិទ្យាល័យស្គន់ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។

**ស៖** នៅក្នុងឆ្នាំសិក្សាដែលលោកបានរៀនជាមួយគាត់ហ្នឹង កាលនោះលោករៀននៅកម្រិតថ្នាក់ទីប៉ុន្មានដែរ?

**ឆ៖** កម្រិត-- កាលនោះខ្ញុំនៅរៀនកម្រិតថ្នាក់ទីបួនចូលមកថ្នាក់ទីបី ។

[១៣:៥១:១០]

**ស៖** ចុះឆ្នាំសិក្សាបន្ទាប់លោករៀនថ្នាក់ទីប៉ុន្មាន?

**ឆ៖** ថ្នាក់បន្ទាប់ខ្ញុំប្រឡងជាប់ឌីប្លូម ខ្ញុំមករៀននៅ*សេហ្គុង*នៅ *ប្រីមីញ៉េរ* ។

**ស៖** លោករៀនជាមួយគាត់នៅវិទ្យាល័យស្គន់ ដែលមានគាត់ជាសាស្ត្រាចារ្យគណិតវិទ្យា ។ អំមិញលោកថា រៀនតែពីរឆ្នាំទេជាមួយគាត់ ប៉ុន្តែលោករៀបរាប់រហូតដល់ឆ្នាំទីបួនមកថ្នាក់ទីបី ទីបីមក

ថ្នាក់ទីពីរ ហើយមកនិងថ្នាក់ទីមួយទៀត ។ តើពិតប្រាកដលោកបានរៀនជាមួយនឹងជនជាប់ចោទកាលណោះជាសាស្ត្រាចារ្យហ្នឹង នៅឆ្នាំណាជាក់លាក់? ប៉ុន្មានឆ្នាំ? ពីរឆ្នាំ ឬក៏បីឆ្នាំ?

**ឆ៖** រៀនពីរឆ្នាំ ពីរឆ្នាំ ។ ថ្នាក់ទីបួន និងថ្នាក់ទីបី ។

**ស៖** លោកបានស្គាល់ជនជាប់ចោទច្បាស់ទេ នៅក្នុងអំឡុងពេលដែលលោកបានរៀនជាមួយគាត់នៅស្គន់ ដែលជនជាប់ចោទជាសាស្ត្រាចារ្យម្នាក់ក្នុងចំណោមសាស្ត្រាចារ្យជាច្រើន ដែលបង្រៀននៅវិទ្យាល័យនោះ?

**ឆ៖** បាទ, ខ្ញុំបានស្គាល់លោកច្បាស់ ។

**ស៖** លោក ទេព សុខ ចូរលោកនិយាយរៀបរាប់ជូនដល់អង្គសវនាការអំពីអត្តចរិតរបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលលោកធ្លាប់បានដឹង ធ្លាប់បានកត់សម្គាល់នៅក្នុងអំឡុងពេលដែលលោកធ្លាប់បានប្រាស្រ័យទាក់ទងជាមួយនឹងជនជាប់ចោទ នៅក្នុងនាមជាសិស្សគ្រូ នៅក្នុងអំឡុងពេលដែលលោកបានរៀននៅវិទ្យាល័យស្គន់នោះ ។

**ឆ៖** បាទ, លោកប្រធាន កាលដែលខ្ញុំបានរៀនជាមួយលោកនោះ ខ្ញុំបានស្គាល់លោកច្បាស់ ។ លោកជាសាស្ត្រាចារ្យម្នាក់ដែលសិស្សរបស់យើងខ្ញុំស្រឡាញ់លោក ពេញចិត្តនឹងលោក ក្នុងការបំពេញភារកិច្ចបង្រៀនយើងខ្ញុំ ។ លោកមានអត្តចរិតស្លូតបូត សុភាពរាបសា ហើយជាពិសេសលោកស្រឡាញ់កូនសិស្សខ្សោយ កូនសិស្សក្រីក្រនៅជនបទ ។ លោកតែងជួយផ្តល់ដល់សិស្សទាំងនោះនូវសៀវភៅខ្មៅដៃឲ្យសិស្សរៀន ។ មិនថែមប៉ុណ្ណោះ លោកតាមដានដល់សិស្សទាំងឡាយនោះ ហើយលោកបង្រៀនជាក្តីបបង្រៀនឲ្យសិស្សពូកែបង្រៀនសិស្សខ្សោយ ។ ពេលណាដែលសិស្សមិនយល់អាចសួរលោកបានគ្រប់ពេល ។ នេះតាមដែលខ្ញុំបានសង្កេតឃើញក្នុងកាលណោះ ។

**ស៖** លោកបាននិយាយអំពីអត្តចរិតរបស់គាត់ ដែលលោកបានកត់សម្គាល់ឃើញរួចហើយ ។ សំណួរសួរថា នៅក្នុងអំឡុងពេលដែលគាត់ជាសាស្ត្រាចារ្យនៅវិទ្យាល័យដែលលោកបានរៀន សួរថាតើក្នុងកម្រិតនៃវិជ្ជាជាសាស្ត្រាចារ្យ តើគាត់មានលក្ខណៈតឹងរ៉ឹង ឬក៏មានលក្ខណៈធូររលុងយ៉ាងដូចម្តេចអំពីវិន័យការងារពេលម៉ោងធ្វើការងាររបស់ខ្លួនគាត់ផ្ទាល់ ក៏ដូចជាសិស្សចំពោះសិស្សជាដើម អំពីវិន័យសាលា? លោកដែលបានកត់សម្គាល់អំពីទិដ្ឋភាពនេះដែរទេ?

[១៣:៥៥:៣៨]

**ឆ៖** បាទ, លោកមេធាវីនៅពេលនោះ ខ្ញុំបានសង្កេតឃើញលោកមានលក្ខណៈម៉ឺងម៉ាត់ទាំងការនិយាយស្តី ទាំងការងាររបស់លោក ។ ព្រោះការនិយាយស្តីលោកតែងតែដឹកនាំឲ្យយើងខ្ញុំបំពេញនូវអំពើល្អ កសាងខ្លួន ខំប្រឹងរៀនសូត្រឲ្យបានល្អ ឲ្យក្លាយទៅជាសិស្សពូកែ សិស្សចេះជួយគ្នាទៅវិញទៅមក ។ លើការងាររបស់គាត់ គាត់ដាក់វិធានការ ដាក់ផែនការឲ្យក្មេង ឲ្យសិស្សរៀន ក្មេងតែងយកចិត្តទុកដាក់ និងធ្វើតាមលោក ។ បើមិនស្គាល់កន្លែងណា បើមិនយល់កន្លែងណា អាចសួរលោកគ្រប់ពេលវេលាទីកន្លែងណាក៏បានដែរ ។ នេះតាមដែលខ្ញុំសង្កេតកន្លងមក ។

**ស៖** ចំពោះសិស្សខ្ជិល ឬក៏សិស្សដែលល្មើសនឹងវិន័យសាលា ឬក៏វិន័យនៅអំឡុងពេលនៅក្នុងថ្នាក់រៀនជាដើម តើលោកដែលឃើញការប្រព្រឹត្តិរបស់គាត់ចំពោះករណីនេះដែរឬទេ? ហើយបើដែលឃើញ តើការប្រព្រឹត្តិរបស់គាត់នៅក្នុងស្ថានភាពនៃសិស្សខ្ជិល ឬក៏សិស្សល្មើសនឹងវិន័យសាលាហ្នឹង តើគាត់ប្រព្រឹត្តចំពោះពួកគេយ៉ាងដូចម្តេចដែរ?

**ឆ៖** កន្លងមក ដែលខ្ញុំបានសង្កេតឃើញចំពោះសិស្សខ្ជិល សិស្សគេចវេសជាមួយគាត់ដូចគ្មានមានតែចូលចិត្តជាមួយនឹងគាត់ ព្រោះគាត់តែងតែអប់រំ ហើយតាមដានសិស្សណាដែលខ្សោយ សិស្សណាដែលមិនខំប្រឹងរៀននោះ ទៅជាក្លាយសិស្សពូកែទាំងអស់គ្នាបាន ។ អ៊ីចឹង ដូចលោក ដូចគ្មានវិធានការទៅលើសិស្សទាំងអស់នោះទេ ។ ខ្ញុំសង្កេតឃើញប៉ុណ្ណឹង ។

**ស៖** ចុះក្នុងការប្រាស្រ័យទាក់ទងក្នុងចំណោមសាស្ត្រាចារ្យដូចគ្នា គ្រូបង្រៀនដូចគ្នា ឬមួយក៏បុគ្គលិកសាលាឯទៀត នៅក្នុងអំឡុងពេលដែលលោកបានរៀននៅវិទ្យាល័យស្គន់នោះ ។ តើលោកកត់សម្គាល់យ៉ាងម៉េចដែរអំពីស្ថានភាពនៃការប្រាស្រ័យទាក់ទងរវាងគាត់ជាមួយនឹងសាស្ត្រាចារ្យជាគ្រូ ឬក៏ដូចជាបុគ្គលសាលានៅទីនោះ?

**ឆ៖** ចំពោះស្ថានភាព ស្ថានការដែលគាត់រស់នៅក្នុងអំឡុងដែលខ្ញុំបានសង្កេតឃើញជាមួយនឹងបុគ្គលិកដទៃទៀត លោកបានដំណើរការល្អ មានសាមគ្គីភាពទូលាយជាមួយបុគ្គលិកទាំងឡាយនោះ មិនមានផលរមាស់នឹងគ្នាឡើយ ។ ហើយថែមទាំងមានការសាមគ្គីភាពល្អថែមទៀតផង ។

[១៣:៥៨:៥៨]

**ស៖** ក្នុងអំឡុងពេលនោះ តើលោកដែលបានជួបប្រទះនូវទិដ្ឋភាពរបស់គាត់មានការខឹងសម្បា ឬក៏មានការអាក់អន់ទៅលើបុគ្គល-- ចំពោះបុគ្គលណាមួយដែរឬទេ? ហើយបើមាន តើអាកប្បកិរិយារបស់គាត់ហ្នឹងសំដែងចេញមកយ៉ាងដូចម្ដេចខ្លះ?

**ឆ៖** បាទ, មិនដែលឃើញមានទេ ។

**ស៖** កាលនោះលោកដឹងទេនៅផ្ទះដែលគាត់ស្នាក់នៅ នៅក្នុងអំឡុងពេលដែលគាត់បង្រៀននៅវិទ្យាល័យស្គន់ តើគាត់រស់នៅកន្លែងណា? ហើយលោកដែលបានទៅកន្លែងដែលគាត់ស្នាក់នៅដែរឬទេ?

**ឆ៖** ផ្ទះដែលគាត់ស្នាក់ គឺតាមដងផ្លូវជាតិលេខប្រាំមួយ ហើយផ្ទះនោះតែងតែមានសិស្សចូលរួមនៅហ្នឹងផ្ទះគាត់ ហើយរៀនសូត្រជាមួយនឹងគាត់ ។ ខ្ញុំសង្កេតឃើញប៉ុណ្ណឹង ។

[១៤:00:00]

**ស៖** ចុះទិដ្ឋភាពក្នុងការប្រាស្រ័យទាក់ទងជាមួយនឹងមជ្ឈដ្ឋានប្រជាពលរដ្ឋជុំវិញផ្ទះ ដែលគាត់ស្នាក់នៅ សង្គម សហគមន៍ដែលគាត់ស្នាក់នៅហ្នឹង តើមានស្ថានភាពយ៉ាងម៉េចដែរ? មានការប្រាស្រ័យទាក់ទងល្អជាមួយនឹងអ្នកជិតខាងដែរឬទេ? ឬក៏មានការប្រកាន់ឬក្រអើតក្រទម ដោយសារមូលហេតុគាត់ជាសាស្ត្រាចារ្យ ដែលមានបៀវត្សច្រើនសម័យនោះ គឺ៦000 ទៅ ៧000រៀលឯណោះ ដែលធៀបជាមួយនឹងមុខរបរផ្សេងទៀត គឺសាស្ត្រាចារ្យនេះ គឺមានកម្រិតនៃបៀវត្សហ្នឹងខ្ពស់ណាស់ ។ តើលោកកត់សម្គាល់យ៉ាងម៉េចដែរពីបញ្ហានេះ?

**ឆ៖** លើបញ្ហានេះមិនមានចោទចំពោះអ្នកនៅជុំវិញរបស់លោកទេគឺលោកបានសាមគ្គីភាពទូលំទូលាយជាមួយនឹងបងប្អូនជិតខាង ។

**ស៖** នៅក្នុងអំឡុងពេលដែលលោកសិក្សា ក៏ដូចជាលោកបានធ្វើការបង្ហាញហើយ អំពីស្ថានភាពនៃការប្រាស្រ័យទាក់ទងជាមួយគាត់ ក្នុងនាមលោកជាសិស្សហើយគាត់ជាគ្រូ ។ មិនត្រឹមតែលោកទេ គឺមានសិស្សដទៃទៀត ដែលបង្កើតជាក្លឹបដើម្បីទទួលការបណ្ដុះបណ្ដាលបន្ថែម មានការបណ្ដុះបណ្ដាលក្រៅម៉ោង ឬក៏រួមគ្នារៀនដោយខ្លួនឯងជាដើម ដោយមានការចង្អុលបង្ហាញពីគាត់ ។ សំណួរសួរថា តើអំឡុងពេលនោះគាត់មានដែលធ្វើការនិយាយស្ដី ឬក៏ធ្វើការបង្ហាញអំពីទស្សនៈបុគ្គលរបស់គាត់នូវនិន្នាការទៅរកលិទ្ធិកុម្មុយនីស្ដប្រាប់ដល់លោក ឬក៏មិត្តភក្ដិរបស់លោកដែរឬទេ?

**ឆ៖** លើបញ្ហានេះមិនដែលលោកបាននិយាយពីលិទ្ធិ ឬក៏និន្នាការទៅរកកុម្មុយនីស្ដ ឬទៅរកលិទ្ធិណាមួយទេ ប៉ុន្តែគាត់តែងតែអប់រំឲ្យចេះស្រលាញ់មនុស្សជាតិ ឲ្យចេះខំប្រឹងរៀនសូត្រៗ ស្រលាញ់

មនុស្សផងគ្នា ស្រលាញ់មិត្តយើង រួបរួមសាមគ្គីមិត្តជួយគ្នាទៅវិញទៅមក ។ នេះការណែនាំរបស់លោក ប្រកបដោយសុភៈសុទ្ធចិត្ត ដោយសុចចិត្តរបស់គាត់ បាទ ។ ខ្ញុំសង្កេតឃើញប៉ុណ្ណឹង ។

**ស៖** ក្រៅពីការបង្ហាត់បង្រៀនទាំងក្នុងម៉ោងរដ្ឋ ទាំងក្រៅម៉ោងរដ្ឋ ដែលមានការបំពេញបន្ថែម ការតម្រង់ទិសបន្ថែម ការបង្កើតជាក្លឹប ឬក៏បង្រៀនគួរបន្ថែមទៀត ដោយអត់យកកំរៃចំពោះអ្នកដែលក្រីក្រ ។ សំណួរសួរថាតើគាត់បានធ្វើអ្វីខ្លះទៀត សម្រាប់ដល់សិស្សនៅវិទ្យាល័យស្គន់ នៅក្នុងអំឡុងពេលដែលគាត់ទៅបង្រៀននៅទីនោះ ហើយបានប្រាស្រ័យទាក់ទាក់ទង ដែលលោកបានប្រាស្រ័យទាក់ទងជាមួយនឹងគាត់នោះ?

[១៤:០៣:១២]

**ឆ៖** ការដែលខ្ញុំបានប្រាស្រ័យទាក់ទងជាមួយនឹងលោក លោកតែងតែជួយដល់យើងខ្ញុំនៅពេលខ្លះដែលខ្វះខាត លោកឲ្យសៀវភៅឲ្យខ្មៅដៃរៀន ហើយនិងលោកបង្រៀនដោយមិនបានយកម្រៃពីសិស្សណាមួយទេ លោកជួយទាំងអស់ ឲ្យតែកូនសិស្សចង់រៀន ។ ហើយកូនសិស្សពេលនោះ ពេញចិត្តនឹងលោក គោរពលោក ។ សូមអស់ប៉ុណ្ណឹង ។

**ស៖** ចំណុចមួយទៀតតើលោកក្នុងអំឡុងពេលដែលបានប្រាស្រ័យទាក់ទងជាមួយគាត់ ក្នុងនាមលោកជាសិស្ស ហើយគាត់ជាគ្រូ តើលោកបានកត់សម្គាល់ឃើញថា គាត់ជាមនុស្សចូលចិត្តបញ្ជាគេ ឬក៏គាត់ចូលចិត្តក្នុងការប្រាស្រ័យទាក់ទងស្មើភាពគ្នាជាមួយអ្នកដទៃ ហើយកិច្ចការណាត្រូវធ្វើដោយខ្លួនឯងគាត់ធ្វើ ឬក៏គាត់អាចមានចំណូលចិត្តមួយគេហៅថា ចូលចិត្តបង្គាប់បញ្ជាគេ ។ លោកបានកត់សម្គាល់លើលក្ខណៈនេះដែរឬទេ?

**ឆ៖** បាទ, ដូចខ្ញុំបានពោលពីលើកមុនហើយថា លោកមានលក្ខណៈសាមញ្ញ ជាមនុស្សគួរឲ្យរាប់មិនធ្វើឲ្យគេខ្លាចលោក ឲ្យគេចូលចិត្តលោក ហើយរាប់អានស្រលាញ់លោក ។ ចប់ហើយ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ?

បើមិនមានទេ យើងប្រគល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ ប្រសិនបើមានសំណួរ ។ ហើយសូមជម្រាបថា សហព្រះរាជអាជ្ញាមានពេលវេលាដប់នាទី ក្នុងការតាំងសំណួរនេះ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ និងសូមស្វាគមន៍លោក ទេព សុខ ។

**ស៖** លោក ទេព សុខ លោកធ្លាប់ជាអតីតកូនសិស្សរបស់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច សំណួរស្ទួថា រាល់ការបង្រៀនលោក ហើយនៅចុងម៉ោងនៃការបង្រៀន តើលោកដែលធ្លាប់បានសង្កេតឃើញថា គ្រូរបស់លោក ដែលមានលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹងធ្លាប់បាននិយាយរឿងរ៉ាវអ្វីខ្លះប្រាប់សិស្សនៅចុងម៉ោងរបស់គាត់ហ្នឹងទេ?

[១៤:០៦:៣៩]

**ឆ៖** បាទ, នៅពេលចុងម៉ោង ខ្ញុំពុំដែលឃើញគាត់បាននិយាយ ។ នេះចំពោះខ្ញុំផ្ទាល់តែម្តង គឺគាត់មិនដែលបានមកនិយាយក្នុងពេលចុងម៉ោងទេ ឃើញតែពេលដែលគាត់ចេញពីបង្រៀនមក គាត់មកកន្លែងលោកតែម្តង ។

**ស៖** អរគុណលោក ។ ដូចលោកជ្រាបស្រាប់ហើយ នៅក្នុងទស្សវត្សឆ្នាំ៦០ ជាងហ្នឹង ចលនាកុម្មុយនីស្តកំពុងតែមានចលនាផុលផុស ។ តើលោកដែលបានធ្លាប់ឮសាស្ត្រាចារ្យនានា ជាពិសេសដែលមានរូបគាត់នុ៎ង បាននិយាយប្រាប់សិស្ស អំពីវណ្ណៈអ្វីខ្លះ? ហើយនិងពីសង្គមបែបដូចម្តេចនៅពេលអនាគតតាមទស្សនវិស័យរបស់គាត់ជូនលោកទេ?

**ឆ៖** ជាទូទៅ កាលខ្ញុំនៅពីក្មេង ពេលនោះខ្ញុំដែលឮដែរ ដែលឮនិយាយថា ការតស៊ូវណ្ណៈ ការធ្វើអ្វីផ្សេងៗ ប៉ុន្តែឮមិនមែនឮដោយផ្ទាល់ពីគេទេ គឺឮពីចម្ងាយមកថា តស៊ូវណ្ណៈៗ ហ្នឹង ប៉ុន្តែខ្ញុំមិនយល់ថាតើតស៊ូវណ្ណៈរបៀបម៉េចមិនដែលឮទេបាទ ។

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក ទេព សុខ ខ្ញុំអស់សំណួរដើម្បីនឹងសួរលោក ហើយខ្ញុំបង្វែរសំណួរបន្ទាប់ទៅសហការីរបស់ខ្ញុំ ។ អរគុណលោកប្រធានអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក វាំងសង់ ដឺវ៉ាយដ៍ ដេស្វាឯល៖**

សូមអរគុណលោកប្រធាន ។

**ស៖** ខ្ញុំសូមចាប់ផ្តើមសួរលោក ដោយខ្ញុំចង់សួរសំណួរមួយ ដែលវាអាចមានភាពផ្ទុយគ្នាយើងកត់សម្គាល់ឃើញ ភាពផ្ទុយគ្នានោះគឺវាដូចខាងក្រោម៖

នៅក្នុងតារាងដែលយើងទទួលបានពីមេធាវីការពារក្តី គឺតារាងមានលេខសម្គាល់ E5/9 ទាក់ទងទៅនឹងសាក្សីដែលខាងការពារក្តីមានបំណងចង់កោះនោះ គឺមានការរៀបរាប់អំពីលោក ទេព សុខ ថាគាត់ជាអតីតសិស្សមួយរូបនៅអនុវិទ្យាល័យខេត្តកំពង់ចាម ក្នុងឆ្នាំ១៩៦៨,៦៩ និង៧០ ។ ហើយនៅក្នុងថ្ងៃនេះ សាក្សីគាត់បានជម្រាបថា គាត់រៀននៅស្គន់ ហើយជនជាប់ចោទជាគ្រូរបស់គាត់ក្នុងឆ្នាំ៦៧ និង ៦៨ ។ ដូច្នេះ ខ្ញុំសូមឱ្យសាក្សីគាត់ជម្រាបយើងអំពីបញ្ហាភាពផ្ទុយគ្នាដែលថា គាត់និយាយថា គាត់ជាសិស្សក្នុងឆ្នាំ៦៧,៦៨ ហើយនៅក្នុងតារាងនោះវារៀបរាប់ថា ៦៨,៦៩ និង៧០ ។ អ៊ីចឹងខ្ញុំសូមឱ្យលោកសាក្សីធ្វើការពន្យល់ ដែលចម្លើយនោះវាមានលក្ខណៈផ្ទុយពីតារាងដែលមេធាវីការពារផ្តល់ជូន ។ សូមឱ្យសាក្សីបញ្ជាក់ ។

[១៤:១០:១២]

**ឆ៖** បាទ, ពេលដែលខ្ញុំរៀនជាមួយលោកសាស្ត្រាចារ្យ កាំង ហ្គេកអ៊ាវ ពីឆ្នាំ៦៧, ៦៨ (ស៊ិក) ហើយខ្ញុំបន្តការសិក្សាពី ៦៨,៦៩ -- អ្ហ៎ា ៦៨,៦៩,៧០ ឡើងទៅ បាទច្រឡំ ។ សូមអភ័យទោស បាទ ។

**ស៖** សូមអរគុណលោក ។ ក្នុងពេលដែលលោកជាសិស្សនៅអនុវិទ្យាល័យនោះ តើគ្រូរបស់លោកថាតើធ្លាប់ត្រូវបានគេចាប់ខ្លួនគាត់ដែរឬទេក្នុងអំឡុងឆ្នាំហ្នឹង គ្រូរបស់លោកហ្នឹង?

**ឆ៖** បាទ, រឿងចាប់មិនចាប់នោះខ្ញុំអត់ដឹងទេ មិនដឹងគាត់ទៅណាទេពេលបាត់ខ្ញុំទៅ ។

**ស៖** សូមអរគុណ ។ ផ្អែកទៅតាមចម្លើយរបស់ជនជាប់ចោទ ខ្ញុំសូមធ្វើការប្រតិកម្មទៅលើចម្លើយនេះ ។ ជនជាប់ចោទ ត្រូវបានគេចាប់ខ្លួននៅថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៦៨ និងដោះលែងនៅខែមេសា ឆ្នាំ១៩៧០ ដូច្នេះហើយគឺជាពេលដែលលោកជាសិស្សរបស់គាត់ក្នុងអំឡុងពេលនោះ ប៉ុន្តែតើលោកអាចពន្យល់យ៉ាងម៉េច បើសិនជានៅពេលនុ៎ងគេចាប់ខ្លួនគាត់ ហើយលោកថា លោកជាសិស្សរបស់គាត់នោះ?

**ឆ៖** បាទ, រឿងនេះខ្ញុំជាសិស្សរៀនជាមួយនឹងលោក ពេលដែលលោកបាត់ខ្លួនទៅខ្ញុំមិនដឹងលោកទៅខាងណា ខ្ញុំមិនដឹង ឱ្យខ្ញុំទៅរកព័ត៌មានណាថាលោកជាប់គុកទៅកន្លែងណា គេចាប់ខ្លួននៅកន្លែងណាខ្ញុំអត់បានដឹងទេអាហ្នឹង ។ វាស្រាប់តែបាត់ពីខ្ញុំទៅ ខ្ញុំបានរៀនហ្នឹង បាត់ពីខ្ញុំទៅ ។

**ស៖** ដូច្នេះ លោកនៅប្រកាន់ចម្លើយដែលថា លោកនៅតែជាសិស្សធ្លាប់ជាសិស្សរបស់គាត់ក្នុងរយៈពេលពីរឆ្នាំនោះ ដែលលោកបានរៀបរាប់ជូនយើងខ្ញុំអម្បាញ់មិញ ថាតើគាត់ជាគ្រូគណិតវិទ្យាក្នុងឆ្នាំនោះដែរឬទេ? ហើយថានៅពេលណាដែលគាត់ចាប់ផ្តើមបាត់ខ្លួនហ្នឹង?

**ឆ៖** ពេលដែលខ្ញុំរៀន គាត់បាត់ខ្លួនហ្នឹង នៅពេលចុងឆ្នាំ៦៨,៦៩ ។ ៦៨ អ៊ីចឹង ខ្ញុំមិនដឹងដែរ ព្រោះកាលនោះខ្ញុំមិនបានតាមដាន លើការបាត់ខ្លួនរបស់លោកផង ។ ព្រោះខ្ញុំជាសិស្ស ខ្ញុំមិនបាននេះទេ បាត់ខ្លួនក៏ខ្ញុំមិនបានកត់សម្គាល់អី ក៏មិនបានកត់សម្គាល់ដែរបាទ ។ អ៊ីចឹង ខ្ញុំមិនអាចប្រាប់ពេល ប្រាប់បាត់ថ្ងៃណាៗបានទេ ។

**ស៖** ប៉ុន្តែ មុនហ្នឹង លោកបានបញ្ជាក់យ៉ាងច្បាស់នៅពេលដែលលោកបាន ចម្លើយរៀបរាប់អំពីគ្រូរបស់លោក ។ ដូច្នេះ តើលោកមានអារម្មណ៍យ៉ាងម៉េចដែរ ឬក៏វាមិនធ្វើឲ្យលោកសង្ស័យទេនៅពេលដែលបាត់ខ្លួនគ្រូរបស់លោកនោះ ដែលគាត់ធ្លាប់ជាគ្រូរបស់លោកនុ៎ង?

**ឆ៖** បាទ,ពេលដែលបាត់ខ្លួនហ្នឹង ខ្ញុំអារម្មណ៍របស់ខ្ញុំ គ្រាន់តែថា វាគ្មានគ្រូបង្រៀនផ្នែកគណិតវិទ្យាតែប៉ុណ្ណឹង អត់មានចាប់អារម្មណ៍ថាលោកទៅណាៗ អត់មានចាប់អារម្មណ៍អីទេ ព្រោះការងារនេះជាការងាររបស់រដ្ឋ ការងាររបស់រាជការបាទ ។ តែប៉ុណ្ណឹង ។

[១៤:១៥:00]

**ស៖** ថាតើនាយកអនុវិទ្យាល័យនុ៎ង គាត់បានពន្យល់ហេតុផលដែរឬទេ ចំពោះបញ្ហានៃការបាត់ខ្លួនហ្នឹង ហើយគាត់មានផ្តល់ជាសញ្ញាណាមួយប្រាប់ដល់សិស្សដែរឬទេ?

**ឆ៖** នាយកសាលា លោកចង់សួរខ្ញុំពីនាយកសាលាដែលបាត់ខ្លួនហ្នឹង តើខ្ញុំម៉េចទៅតាមដានបានដឹង តាមដានពីការបាត់ខ្លួនហ្នឹង ខ្ញុំមិនបានគិតគូទៅលើបញ្ហាហ្នឹងទេបាទ ។ ខ្ញុំមិនដឹងតែម្តង និយាយឲ្យខ្លី ។

**ស៖** ខ្ញុំគិតថាប្រហែលជាមានបញ្ហាបកប្រែ ថាតើនាយកសាលានោះ គាត់មានបានពន្យល់ដែរឬទេ អំពីការបាត់ខ្លួនរបស់ជនជាប់ចោទដែលជាគ្រូរបស់លោកនុ៎ង ដែលលោកបាននិយាយថាកើតឡើងនៅក្នុងចុងឆ្នាំ១៩៦៨?

**ឆ៖** ពេលនោះ លោកជានាយកនោះមិនបានប្រាប់ពីហេតុផលដល់យើងខ្ញុំជាសិស្សទេបាទ ។

**ស៖** សូមអរគុណលោក ហើយលោកបញ្ចប់ចម្លើយការឆ្លើយរបស់លោកដោយឆ្លើយតបទៅនឹងសំណួររបស់លោកប្រធានតាមរយៈចម្លើយនេះ លោកបានឆ្លើយថា ជនជាប់ចោទមិនមានគុណវិបត្តិ

ណាមួយនោះទេ ។ ដូច្នេះ ចំពោះលោក តើលោកជឿដែរឬទេថា គឺការបង្ហាញលក្ខណៈដែលថាគាត់ល្អនោះគឺដើម្បីចង់ឲ្យគេចូលចិត្តគាត់ ឬក៏អ្វីដែលគាត់សម្តែងចេញអំពីលក្ខណៈដែលថាឲ្យគេចូលចិត្តគាត់នោះ ជាការលាក់កំបាំងនូវអត្តចរិត ឬក៏បុគ្គលិកលក្ខណៈរបស់គាត់ផ្សេងទៅវិញ?

**ឆ៖** នៅពេលនេះ ខ្ញុំនិយាយបានត្រឹមតែ គាត់ដែលខ្ញុំបានជួបប្រទេះជាមួយគាត់ និងបានរស់នៅជាមួយគាត់មួយរយៈពេលប៉ុណ្ណោះ ។

**ស៖** លោក ទេព សុខ នៅពេលដែលលោកបានផ្តល់ចម្លើយអម្បាញ់មិញ ហើយលោកមិនបានគាត់ជនជាប់ចោទមិនបានលើកឡើងក្នុងអំឡុងពេលឆ្នាំ៦៥ទៅដល់៦៩ ។ អ៊ីចឹង គឺយើងមិនបានដឹងអំពីស្ថានភាពនុ៎ង ។ តើនៅពេលនុ៎ង ហើយតើលោកអាចពន្យល់ ខ្ញុំចង់និយាយអំពីលោក បានន័យថានៅក្នុងឆ្នាំ៦៥ ដល់៦៩ ថាតើលោកនៅពេលនោះ លោកមានការបាត់ខ្លួន ឬយ៉ាងម៉េច ឬក៏លោកមានចូលទៅដល់ចលនាអីផ្សេងដែរឬទេ?

*(អ្នកបកប្រែ៖ បាទ សូមកែតម្រូវគឺ ឆ្នាំ៧៥ ដល់ឆ្នាំ៧៩)*

**ឆ៖** សំណួរនេះខ្ញុំមិនអាចឆ្លើយបានទេ ព្រោះមិនយល់ពីសំណួររបស់លោក ។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ នៅក្នុងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ តើលោកបានទៅធ្វើការនៅក្នុងសហករណ៍ដែរឬទេ? ឬក៏គេឲ្យលោកធ្វើដំណើរនៅក្នុងប្រទេសកម្ពុជាដែរឬទេ? ហើយគេបង្ខំលោកឲ្យធ្វើការនៅក្នុងរបបខ្មែរក្រហមដែរឬទេ? ខ្ញុំចង់ដឹងទៅលើព័ត៌មានទាំងអស់នេះ ។

**ឆ៖** នៅក្នុងរបបខ្មែរក្រហម ខ្ញុំចូលរួមធ្វើការនៅក្នុងសហករណ៍ ។ នៅក្នុងសហករណ៍ជាមួយខ្មែរក្រហមនុ៎ងតែម្តង ។

**លោក វ៉ាំងសង់ ដឺវ៉ាយេ ដេស្សាឯល៖**

នៅពេលនេះ ខ្ញុំពុំមានសំណួរទៀតទេ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី តើចង់លើកពីបញ្ហាអី? ចង់សួរសាក្សីរូបនេះ ឬក៏យ៉ាងម៉េច?

**លោក គឹម ម៉េងឃី៖**

សូមអរគុណ លោកប្រធាន ។ តាងនាមឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ពួកយើងបានស្នើសុំឲ្យលោកប្រធាន មេត្តាជម្រាបដល់សាក្សីបន្តបន្ទាប់ទៀតគឺ D4, D5, D6 អំពីសិទ្ធិមិនអាចសួរសំណួរ

ដល់សាក្សីពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនជាប់ចោទ តាមសេចក្តីសម្រេចកាលពីថ្ងៃ២៧ ខែសីហា ឆ្នាំ ២០០៩ នេះបាទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

រឿងនេះដូចជារឿងដដែល អត់មានរឿងអីថ្មីទេ គ្រាន់តែដូរមនុស្សថ្មីប៉ុណ្ណោះ ។

អ៊ីចឹងអង្គជំនុំជម្រះមិនឆ្លើយតបនឹងអ្វីដែលដដែលនោះទេ ព្រោះឆ្លើយរួចហើយ ហើយយើងនឹងឈប់ផ្តល់ឱកាស នៅក្នុងអំឡុងពេលដំណើរការស្តាប់សក្ខីកម្មសាក្សី បង្ហាញសក្ខីកម្មអំពីអត្តចរិតនេះដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

ឥឡូវនេះអង្គជំនុំជម្រះផ្តល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ ប្រសិនបើមានសំណួរ សូមអញ្ជើញ ។

[១៤:២២:៤១]

**ការតាំងសំណួរដោយមេធាវីការពារក្តី**

**សួរដោយ លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ និងអង្គសវនាការទាំងមូល ។

**ស៖** លោក ទេព សុខ ខ្ញុំសូមអនុញ្ញាតសួរលោកថា កាលនៅរៀន លោកគ្រូ កាំង ហ្គេកអ៊ាវ ជាគ្រូរបស់លោក តើគ្រូរបស់លោកបានជួយអ្វីខ្លះដល់លោក? សូមលោកបញ្ជាក់ ។

**ឆ៖** កាលខ្ញុំរៀន លោកគ្រូ កាំង ហ្គេកអ៊ាវ បានជួយបង្រៀនខ្ញុំ យកចិត្តទុកដាក់ដល់ខ្ញុំ ចំពោះខ្ញុំដែលជាសិស្សខ្សោយ ឲ្យខ្ញុំក្លាយទៅជាសិស្សរៀនពូកែដូចគេដូចឯង ។ លោកជួយដល់យើងខ្ញុំជាមធ្យោបាយ មានសៀវភៅសរសេរ និងខ្មៅដៃ ជាដើម ហើយនិងលើកទឹកចិត្តឲ្យយើងខ្ញុំនេះ ឲ្យខ្ញុំខំប្រឹងរៀនសូត្រឲ្យចេះស្រលាញ់មិត្តភក្តិរួមថ្នាក់ជួយបង្រៀនគ្នាទៅវិញទៅមក ។ នេះខ្ញុំបានសង្កេតឃើញថាលោកបានលើកទឹកចិត្តជួយដល់យើងខ្ញុំដូច្នេះ ។

**ស៖** សូមអរគុណ អ៊ីចឹងខ្ញុំសូមលោកបញ្ជាក់បន្ថែមទៀត រឿងចម្លើយរបស់លោកអម្បាញ់មិញលោកអម្បាញ់មិញលោកបានជម្រាបអង្គសវនាការថា ពីដើមលោកជាកូនសិស្សខ្សោយ តែដោយសារលោកគ្រូ កាំង ហ្គេកអ៊ាវ នេះលោកបានក្លាយទៅជាសិស្សពូកែ អ៊ីចឹងមែនឬទេ?

**ឆ៖** បាទ, យ៉ាងដូច្នេះមែន ។

**ស៖** អ៊ីចឹងសិស្សដទៃទៀតដែលខ្សោយជំនាន់លោក តើមានសិស្សច្រើនទេ ដែលខ្សោយហើយអាចទៅជាសិស្សពូកែ ដោយសារការព្យាយាមរបស់លោកគ្រូរបស់លោក?

**ឆ៖** ក្នុងអំឡុងរៀនជាមួយយើងខ្ញុំ កូនសិស្សដែលរៀនជាមួយលោក តែងតែមានការរីកចម្រើនប្រសើរទាំងអស់ ទាំងចំណេះដឹង សមត្ថភាព និងសីលធម៌ ប្រកបដោយមានភាពក្លាហាន សិស្ស ហើយរួមចំណែកស្រលាញ់លោក ដែលលោកយកចិត្តទុកដាក់បង្រៀនដល់សិស្សទាំងអស់នោះ ។

[១៤:២៥:២៨]

**ស៖** សូមអរគុណ ។ លោកគ្រូរបស់លោក ជាសាស្ត្រាចារ្យគណិតវិទ្យា តើលោកបានដឹងថាលោកគ្រូរបស់លោកបានបង្រៀននៅវិទ្យាល័យស្ពន់ហ្នឹងមុខវិជ្ជាអីខ្លះ? លោកបានដឹងទេក្រៅពីគណិតវិទ្យា?

**ឆ៖** ដឹងតែពីគណិតវិទ្យា ត្រង់ក្រៅពីទៀតខ្ញុំដូចជាច្រឡំហើយ ប្រហែលជាមានរូបវិទ្យា គីមីដែរក៏មិនដឹង ។

**ស៖** បាទ, សូមអរគុណ អ៊ីចឹងកាលលោកនៅរៀនជាមួយលោកគ្រូរបស់លោក តើលោកជាកូនសិស្សដែលវាក្រ ឬក៏មធ្យម ឬក៏អ្នកមាន? សូមលោកបញ្ជាក់ ។

**ឆ៖** កាលដែលខ្ញុំនៅរៀនពេលនោះ ទាំងកូនសិស្ស មធ្យម កូនសិស្សធូរធារ កូនសិស្សក្រ គឺលោកយកចិត្តទុកដាក់ទាំងអស់ មិនរើសមុខដល់សិស្សគ្រប់សិស្ស គឺលោកស្រលាញ់គ្រប់សិស្សទាំងអស់។

**ស៖** សូមអរគុណ សូមលោកបញ្ជាក់ម្តងទៀត ខ្ញុំសួរលោកថា កាលដែលលោកនៅរៀន លោកហ្នឹងជាកូនអ្នកមាន ឬក៏ជាកូនអ្នកក្រ ដែលទៅរៀនហ្នឹង?

**ឆ៖** បាទ, កាលខ្ញុំនៅរៀននោះ ខ្ញុំជាកូនអ្នកក្រទេ ហើយកូនកំព្រាទៀត ។

**ស៖** សូមអរគុណ ។ អ៊ីចឹងបើលោកជាកូនសិស្សអ្នកក្រ ជាកូនកំព្រាទៀត តើលោកដែលបានធ្លាប់នៅជាមួយលោកគ្រូរបស់លោកទេ គាត់ឱ្យផ្ទះនៅទេ?

**ឆ៖** បាទ, ផ្ទះខ្ញុំនៅក្បែរសាលាហ្នឹង អ៊ីចឹងខ្ញុំអត់បានទៅនៅជាមួយនឹងគាត់ទេ ខ្ញុំអាចទៅដល់ផ្ទះខ្ញុំបាន ។

**ស៖** អ៊ីចឹងលោកមានដែលដឹងទេ ថាលោកគ្រូរបស់លោកបានចិញ្ចឹមកូនអ្នកក្រឱ្យនៅផ្ទះជាមួយទេ លោកមានដឹងទេ? សូមលោកបញ្ជាក់មើល ។

**ឆ៖** គាត់មានចិញ្ចឹមយកចិត្តទុកដាក់ដល់កូនអ្នកក្រ ។

**ស៖** សូមអរគុណ ។ សូមលោករកនឹកមើល តើក្នុងរយៈពេលដែលលោកស្គាល់លោកគ្រូរបស់លោក តើលោកគ្រូរបស់លោកបានបង្កើតស្នាដៃអ្វីខ្លះដល់សាលានិងសិស្ស?

**ឆ៖** ក្នុងរយៈកាលដែលខ្ញុំបានរៀននៅពេលនោះ ខ្ញុំសង្កេតឃើញលោកបានធ្វើ ដូចជាពិធីសហករណ៍លក់សៀវភៅ អាហ្នឹងគេហៅស្តុទេ (សហករណ៍) បាទ សហករណ៍ យកសៀវភៅមកចែកជូនលក់ដល់សិស្សានុសិស្សហ្នឹងដោយថ្លៃទាប ។ ខ្ញុំសង្កេតឃើញប៉ុណ្ណឹង ដែលជាស្នាដៃរបស់គាត់ជ្រោមជ្រែង ។

[១៤:២៩:០៨]

**ស៖** សូមអរគុណដែលលោកបាននឹកឃើញដល់ស្នាដៃរបស់លោកគ្រូរបស់លោក ។ តើមួយរយៈកាលដែលលោកស្គាល់លោកគ្រូរបស់លោក តើមានដែលសិស្ស ឬក៏បុគ្គលិក ឬក៏គ្រូដូចគ្នា អ្នកណាមួយដែលលួចរិះគន់ពីគ្រូរបស់លោកឬទេ?

**ឆ៖** ដូចជាគ្មានទេ កាលរិះគន់ចំពោះលោក ។

**ស៖** សូមអរគុណ ។ អ៊ីចឹងទាំងអស់គ្នាអត់មានអ្នកណាមួយ ដែលរិះគន់ពីគ្រូរបស់លោកទេ ព្រោះគ្រូរបស់លោកជាគ្រូល្អ ។ អ៊ីចឹងខ្ញុំសួរថា តើទាំងអស់គ្នាហ្នឹង គេស្រលាញ់គាត់គ្រប់គ្នាយ៉ាងម៉េចខ្លះ? សូមលោកនិយាយបន្តិចមើល?

**ឆ៖** អានេះចំពោះខ្ញុំជាសិស្សខ្ញុំបានសង្កេតឃើញសិស្សានុសិស្សស្រលាញ់លោកទាំងអស់ដោយមិនរើសអើងចំពោះលោកគ្រូឯង ។ ឯចំពោះបុគ្គលិកក៏ខ្ញុំសង្កេតឃើញថាលោកមានភាពសស្រាក់សស្រាំជាមួយបុគ្គលិករបស់គ្នាលោក ។ ខ្ញុំសង្កេតឃើញតែប៉ុណ្ណឹង ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ ខ្ញុំអស់សំណួរសួរលោកហើយ សូមជម្រាបទៅលោកប្រធានថា មេធាវីការពារទាំងពីររូបអស់មានសំណួរអីទៀតហើយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ។ សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធានសូមអរគុណ ។ តាមពិតខ្ញុំមានសំណួរពីរបីបន្ថែមទៀត ។ សូមអរគុណលោកសាក្សី ។

**ស៖** ខ្ញុំគិតថាយើងមានចំណុចពីរដែលត្រូវបញ្ជាក់ឲ្យបានច្បាស់លោកសាក្សី។ ចំណុចទីមួយ គឺ សំណួរទាក់ទងទៅនឹងកាលបរិច្ឆេទ សហព្រះរាជអាជ្ញាដែលបានសួរលោកអម្បាញ់មិញនេះ គឺថាបាន ត្រឹមត្រូវហើយក្នុងការឲ្យលោករំឭកឡើងវិញអំពីកាលបរិច្ឆេទនោះ ដែលថាតាមពិតទៅនៅដើមឆ្នាំ១៩៦៨ ឌុច គឺថាបានបាត់ខ្លួន ។ ដូច្នេះខ្ញុំចង់ឲ្យលោកធ្វើការរំឭកឡើងវិញ តើលោកមានចងចាំទេថា លោកមាន ការភាន់ច្រឡំឬ នៅក្នុងឆ្នាំសិក្សារបស់លោកដែរលោកបាននិយាយអំពីឆ្នាំសិក្សានេះ? ប្រសិនបើ ឌុច គាត់បានបាត់ខ្លួនពីដើមឆ្នាំ១៩៦៨មក ហើយបើសិនជាលោកជាកូនសិស្សរបស់គាត់សម្រាប់រយៈពេល ពីរឆ្នាំ មានន័យថាគឺគួរតែ ពីរឆ្នាំមុនពេលដែលគាត់បាត់ខ្លួន ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ត្រង់ ចំណុចនេះដែរឬទេ?

**ឆ៖** បាទ, មកកន្លែងនេះខ្ញុំហាក់ដូចជាភាន់ច្រឡំខ្លះដែរ ចាំពុំបានដែរ ពេលដែលខ្ញុំប្រាប់ថាខ្ញុំបាន រៀនជាមួយលោកឆ្នាំ៦៧, ៦៨ អានេះគឺជាការរំឭកខ្ញុំដែលខ្ញុំនឹកឃើញតែប៉ុណ្ណោះ ប៉ុន្តែវាយ៉ាងម៉េច យ៉ាងម៉ានោះខ្ញុំមិនបានចាំពិតប្រាកដដែរទេ ។ សូមអភ័យទោសកន្លែងហ្នឹង ។

[១៤:៣៣:២៧]

**ស៖** សម្រាប់ពួកខ្ញុំ ខ្ញុំអត់មានបញ្ហាទេ បើសិនជាលោកប្រាកដប្រជាថា លោកពិតជាបានធ្វើជា សិស្សរបស់លោក ឌុច រយៈពេលពីរឆ្នាំ ទៅតាមអ្វីដែលលោកបាននិយាយនោះ ។ ហើយបើសិនជា ចំណុចនេះជាចំណុចសំខាន់នោះគឺយើងអាចធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញទៅលើកាលបរិច្ឆេទ ។ ក៏ប៉ុន្តែអ្វីដែលច្បាស់លាស់នោះគឺថា លោកបានធ្វើជាសិស្សរបស់គាត់សម្រាប់រយៈពេលពីរឆ្នាំបន្តបន្ទាប់ មែនទេ?

**ឆ៖** បាទ ពេលនោះខ្ញុំបានរៀនជាមួយគាត់ជាបន្តបន្ទាប់ក្នុងរយៈពេលពីរឆ្នាំមែន ។ ប៉ុន្តែអាពេល ដាច់ហ្នឹងវាអាចឆ្នាំ៦៦,៦៧ ឬ ៦៧,៦៨ ក៏មិនដឹងអាហ្នឹង ចន្លោះហ្នឹងខ្ញុំច្រឡំហើយកន្លែងហ្នឹងបាទ។ ប៉ុន្តែខ្ញុំបានរៀនជាមួយគាត់ទីមួយបានរៀននៅ *កាត់ទ្រីយាម* ទីពីរ នៅ *ទ្រ័របេឡៀម* ប៉ុន្តែដាច់ខ្ញុំមិនដឹង ។ ប៉ុន្តែ*អាទ្រ័របេឡៀម* នោះវាមិនបានរៀនចប់ទេបាទ ។ មានប៉ុណ្ណឹងបាទ ។

**ស៖** សូមអរគុណសម្រាប់ការបញ្ជាក់ឡើងវិញរបស់លោក ។ លោកបាននិយាយថាពេលនោះ គឺថា លោកជាសិស្សម្នាក់ដែលមានសមត្ថភាពអន់ខ្សោយ ហើយគ្រួសាររបស់លោកវិញគឺមានជីវភាព ក្រីក្រ ហើយលោក ឌុច បានជួយដល់រូបលោកផ្ទាល់ តើត្រឹមត្រូវដែរឬទេ?

**ឌ៖** កាលដែលលោកជួយខ្ញុំនេះគឺពិនិត្យទៅលោកសាស្ត្រាចារ្យខ្ញុំ លោក កាំង ហ្គេកអ៊ាវ លោកមិនមែនត្រឹមជួយខ្ញុំទេ គឺជួយសិស្សទូទៅជាពិសេស គឺសិស្សទូទៅ មិនចាប់អារម្មណ៍តែទៅលើខ្លួនខ្ញុំម្នាក់ឯងនោះទេ ។

**ស៖** ហើយលោកខ្លួនឯងផ្ទាល់បានបន្តការសិក្សាទៀត ហើយក្រោយមកទៀតលោកក៏បានក្លាយទៅជាគ្រូបង្រៀនដែរ តើត្រឹមត្រូវដែរឬទេលោក?

**ឌ៖** ក្រោយមកទៀតខ្ញុំបានទៅជាគ្រូបង្រៀន ប៉ុនមុនឆ្លងកាត់គ្រូបង្រៀនហ្នឹង ខ្ញុំចូលធ្វើការនៅសម័យ លន់ នល់ ហើយចេញពី លន់ នល់ មកគេឲ្យខ្ញុំទៅធ្វើជាទាហាន ឡាហ្គ័រប៉ូលីទិក ។

**ស៖** អ៊ីចឹងគឺថា លោកបានធ្វើការនៅក្នុងរបប លន់ នល់ ជាគ្រូបង្រៀន ហើយក្រោយមកទៀតលោកបានក្លាយទៅជាទាហាននៅក្នុងរបប លន់ នល់ ដែរតើត្រឹមត្រូវដែរឬទេ?

[១៤:៣៦:៤៩]

**ឌ៖** ត្រឹមត្រូវ ។

**ស៖** អ៊ីចឹងខ្ញុំយល់ថា ខាងសហព្រះរាជអាជ្ញានឹងមានចម្លើយចំពោះសំណួររបស់គាត់ហើយនៅពេលនេះ ។ ហើយក្រោយពេលដែលលោកបង្រៀនហើយក្រោយមកទៀតលោកបានក្លាយទៅជានាយកអនុវិទ្យាល័យមួយ តើត្រឹមត្រូវដែរឬទេ?

**ឌ៖** បាទ, ត្រឹមត្រូវ ។

**ស៖** នៅពេលដែលយើងពិនិត្យទៅមើលអាជីពរបស់លោកដែលថាពីមុនមកលោកជាសិស្សមានសមត្ថភាពមធ្យម ក្រោយមកទៀតលោកបានក្លាយទៅជាគ្រូបង្រៀន ហើយក្រោយមកទៀតលោកបានក្លាយទៅជានាយកសាលាអនុវិទ្យាល័យមួយ តើលោកដែរមានអារម្មណ៍ថា លោកឌុច គឺជាមនុស្សម្នាក់ដែលបានជួយឲ្យលោកសម្រេចបាននូវសមិទ្ធផលដែលលោកបានទទួលរហូតមកដល់ពេលបច្ចុប្បន្ននេះមានន័យថាគឺដោយសារមានជំនួយពីរូបលោក ឌុច ហើយដែលលោកបានរៀនសូត្រចប់សព្វគ្រប់ ហើយក្រោយមកបានក្លាយទៅជាគ្រូបង្រៀន ហើយក្រោយមកទៀតបានក្លាយទៅជានាយកសាលាអនុវិទ្យាល័យនោះមែនទេ?

**ឌ៖** បាទ, ដូចយ៉ាងដូច្នេះហើយ ។

**ស៖** តើនៅពេលណាទៅដែលលោកបានដឹងថា នៅក្នុងអំឡុងពេលឆ្នាំ១៩៧៥ ដល់១៩៧៩ ឌុច គឺជាប្រធានរបស់ស-២១ នោះ ។ តើនៅពេលណាទៅទើបលោកដឹងថាលោក ឌុច ជាប្រធានស-២១ នោះ?

**ឆ៖** នៅពេលដែលខ្ញុំដឹងថា លោក កាំង ហ្គេកអ៊ាវ ហៅឌុច ជាប្រធានស-២១ នៅពេលដែលគេចាប់គាត់មកកាត់ក្តីនៅពេលនេះ ។

**ស៖** តើលោកគិតយ៉ាងដូចម្តេចដែរ នៅពេលដែលលោកបានដឹងអំពីព័ត៌មាននេះ?

**ឆ៖** នៅពេលដែលខ្ញុំបាទបានដឹងពីព័ត៌មាននេះ ខ្ញុំសោកស្តាយជាខ្លាំងចំពោះគាត់ដែលមានគុណធម៌ពីដើមមក ហើយក្លាយទៅជា ហៅថា ជនឧក្រិដ្ឋទៅវិញ ខ្ញុំសោកស្តាយខ្លាំងណាស់ ។

**ស៖** ទោះបីជាមានរឿងហេតុហ្នឹងក៏ដោយ ហើយដោយសារគាត់គឺជាមនុស្សម្នាក់ដែលបានជួយឧបត្ថម្ភដល់លោក ។ ដូច្នេះហើយបានជាលោកសម្រេចចិត្តមកផ្តល់សក្ខីកម្មដល់ជននេះក្នុងនាមជាសាក្សី បង្ហាញអំពីអត្តចរិតរបស់ជនជាប់ចោទនេះ តើត្រឹមត្រូវដែរឬទេ?

[១៤:៤០:៤៥]

**ឆ៖** បាទ, ត្រឹមត្រូវហើយ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន សូមអរគុណលោកសាក្សីសម្រាប់វត្តមានរបស់លោកនៅក្នុងសវនាការនេះ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ទេព សុខ ដែលបានអញ្ជើញមកផ្តល់សក្ខីកម្មតាមការកោះហៅរបស់អង្គជំនុំជម្រះ។ ហើយក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោកមានការខិតខំប្រឹងប្រែងក្នុងការឆ្លើយតបទៅនឹងសំណួរផ្សេងៗពីអង្គជំនុំជម្រះ និងភាគីដែលចូលរួមនៅក្នុងដំណើរការនីតិវិធីក្នុងការស្តាប់សក្ខីកម្មរបស់លោក។ ឥឡូវនេះ ដំណើរការនៃការស្តាប់សក្ខីកម្មរបស់លោកបានដល់ទីបញ្ចប់ហើយ ។ ដូច្នេះ លោកអាចទៅកន្លែងសាធារណៈនៅទីនោះដើម្បីអាចចូលរួមមើលដំណើរការសវនាការក៏បាន ឬមួយក៏លោកត្រលប់ទៅលំនៅដ្ឋាន ឬក៏ទៅទីណាដែលលោកមានបំណងចង់ទៅបានហើយ ។

ហើយឥឡូវនេះដល់ពេលម៉ោងត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពី

ពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តដំណើរការសវនាការស្តាប់សាក្សីបញ្ជាក់បង្ហាញអំពីអត្តចរិតជនជាប់ចោទជាបន្ត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:៤២នាទីដល់ម៉ោង ១៥:០២នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។ មន្ត្រីតុលាការ អញ្ជើញសាក្សី ជូ រិនចូលមកកាន់សាលសវនាការ ។

*(លោក ជូ រិន ចូលមកក្នុងបន្ទប់សវនាការ)*

**សួរដោយប្រធានអង្គជំនុំ៖**

សួស្តីលោក សាក្សី ។

**ស៖** តើលោកមានឈ្មោះអ្វី?

**ឆ៖** បាទ ខ្ញុំឈ្មោះ ជូ រិន ។

**ស៖** លោក ជូ រិន តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** (ឮមិនច្បាស់) ឆ្នាំហើយ ។

**ស៖** លោកឆ្លើយម្តងទៀត ហើយសូមណែនាំលោកថា លោកបង្អង់បន្តិច ក្រោយពេលស្តាប់សំណួរ ដោយលោកមើលនៅក្បាលមីក្រូខាងមុខហ្នឹងឲ្យសញ្ញាភ្លើងក្រហម ទើបលោកអាចផ្តើមនិយាយបាន ដើម្បីឲ្យសំឡេងរបស់លោកនុ៎ង អាចស្រូបចូលនិងប្រព័ន្ធ នៅក្នុងសាលសវនាការនេះ ហើយដើម្បីប្រតិចារឹកកត់ត្រាទុកនូវសម្តីរបស់លោកផង ហើយនិងមានការបកប្រែពីភាសាខ្មែរទៅភាសាអន្តរជាតិពីរទៀត គឺអង់គ្លេស និងភាសាបារាំង ដើម្បីឲ្យភាគដែលចូលរួម និងសាធារណជនដែលចូលរួមនឹងបានស្តាប់ និងបានយល់អំពីសក្ខីកម្មរបស់លោក ។ តើលោកយល់ដែរឬទេ?

**ឆ៖** បាទ, យល់ ។

**ស៖** តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** ខ្ញុំមានអាយុ៥០ឆ្នាំហើយ ។

**ស៖** តើសព្វថ្ងៃនេះ លោកមានទីលំនៅ នៅទីកន្លែងណា? ហើយលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** បាទ, ខ្ញុំនៅភូមិស្វភី សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ មុខរបរគ្រូបង្រៀន ។

**ស៖** លោក ជូ វិន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា លោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធ ឬក៏សហព័ទ្ធជាមួយនឹងភាគីនូវរឿងក្តីនេះទេ ហើយថាលោកបានស្បថរួចហើយ មុនពេលលោកអញ្ជើញចូលមកកាន់សាលសវនាការនេះ ។ តើពិតមែនដែរឬទេ?

**ឆ៖** បាទ, ពិតមែន ។

**ស៖** លោក ជូ វិន ក្នុងនាមលោកជាសាក្សី គឺលោកមានសិទ្ធិបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏សុំឲ្យលោកអំណះអំណាងមួយណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពទៅលើខ្លួនលោក។ ទន្ទឹមនឹងនេះ ក្នុងនាមលោកជាសាក្សី លោកមានករណីកិច្ចនិយាយតែការដែលពិត ដែលលោកបានដឹងបានឮ បានឃើញ ដោយផ្ទាល់ ។ លោក ជូ វិន តើលោកបានធ្លាប់បានស្គាល់ជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច នេះ នៅក្នុងអំឡុងពេលណាដែរ?

**ឆ៖** បាទ, លោកចៅក្រម ខ្ញុំបានស្គាល់លោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ ឈ្មោះនេះ ខ្ញុំស្គាល់ក្រោយទេ ។ ឈ្មោះពីដើមមិញ ឈ្មោះ ហង់ ពិន ដែលខ្ញុំស្គាល់ តាំងពីឆ្នាំ១៩៨៥ រហូតមកដល់ឆ្នាំ១៩៨៧ ។

**ស៖** កាលដែលស្គាល់ កាលនោះ តើស្គាល់ក្នុងកម្រិតណាដែរ ក្នុងនាមជាសហការីធ្វើកិច្ចការជាមួយគ្នា? ឬក៏គ្រាន់តែស្គាល់បែបផែននៃការជួបគ្នាដោយចៃដន្យទេ?

[១៥:០៨:០៥]

**ឆ៖** ស្គាល់-- ខ្ញុំស្គាល់ក្នុងនាមសហការី ក្នុងអាជីពជាគ្រូបង្រៀន ។

**ស៖** កាលនោះ លោកចាំទេ ថានៅក្នុងឆ្នាំដែលលោកបានជួបប្រាស្រ័យទាក់ទង និងស្គាល់ជាមួយនឹងជនជាប់ចោទ ដែលលោកអះអាងអំមិញថា កាលពីជួបហ្នឹង ឈ្មោះ ហង់ ពិន ហើយចំណែកឯឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹង លោកទើបតែស្គាល់ក្រោយមកទេ ។ ហើយសំណួរសួរថា តើនៅក្នុងការដែលជួបហ្នឹង ធ្វើគ្រូនឹងនៅទីកន្លែងណាដែរ កាលនោះ?

**ឆ៖** កាលណោះ គាត់ធ្វើគ្រូនៅភូមិផ្កាំ ។ ភូមិផ្កាំហ្នឹង ជាសាលាមួយដែលនៅក្នុងការគ្រប់គ្រងរបស់ការិយាល័យអប់រំស្រុកស្វាយចេក ។ ក្រោយមកទៀត ដោយមានសុខផ្ទាល់ខ្លួនរបស់គាត់ ក៏បានសុំមកនៅនឹងការិយាល័យដើម្បីគ្រប់គ្រងស្ថានភាពរបស់គាត់ឲ្យសុវត្ថិភាពជាប់ខ្លួន ក៏ខ្ញុំបានអនុញ្ញាតឲ្យគាត់មកនៅនឹងការិយាល័យអប់រំស្រុក ។

**ស៖** បើកសំឡេង ឲ្យគាត់បន្តចម្លើយរបស់គាត់ទៀត ។

**ឆ៖** នៅគាត់ជាសហការីគ្រូបង្រៀនម្នាក់នៅក្នុងសាលាផ្កាំ ។ សាលាផ្កាំនោះ គឺជាសាលាមួយដែលនៅក្រោយឱវាទរបស់ការិយាល័យអប់រំស្រុកស្វាយចេក នៅឆ្នាំ១៩៨៥ ។

**ស៖** សាលាផ្កាំហ្នឹង ជាកម្រិតបឋមសិក្សា? ឬក៏ជាអនុវិទ្យាល័យ? ឬក៏ជាវិទ្យាល័យ? ហើយកាលនោះគាត់បង្រៀនមុខវិជ្ជាអ្វីដែរ? ហើយនៅថ្នាក់ទីប៉ុន្មាន?

**ឆ៖** កាលនោះ គាត់បង្រៀននៅសាលាអនុវិទ្យាល័យផ្កាំ ។ ហើយគាត់បង្រៀនតែមុខវិជ្ជា រូប គីមី ។

**ស៖** គាត់បង្រៀនសិស្សថ្នាក់ទីប៉ុន្មានដែរ?

**ឆ៖** ចាំអត់បាន លោកចៅក្រម ។

**ស៖** កាលនុ៎ង អនុវិទ្យាល័យផ្កាំហ្នឹង ស្ថិតនៅក្នុងតំបន់ការគ្រប់គ្រងកាន់កាប់ ដោយរដ្ឋាភិបាល ឬក៏កាន់កាប់ ដោយកងកម្លាំងខ្មែរក្រហម? ពីព្រោះនៅក្នុង៨៥ហ្នឹង ដូចជាមិនទាន់សមាហរណកម្មទេ ។

**ឆ៖** ហើយទៅនៅឆ្នាំ១៩៨៥នុ៎ង គឺបាន តំបន់នោះ គឺជាតំបន់សមាហរណកម្ម ដែលមកពីនោះមកនៅឆ្នាំ១៩៨៤ មកដល់៨៥ហ្នឹង គាត់បានបង្រៀន ហើយនិងគាត់មានឈ្មោះនៅក្នុងក្រសួងអប់រំ ។

**ស៖** លោកនិយាយអំមិញថា រយៈពេលក្រោយមកទៀត បានគាត់មកនៅការិយាល័យអប់រំមូលហេតុបញ្ហាផ្ទាល់ខ្លួនរបស់គាត់ ។ ហេតុផលម៉េចទៅ បានជាមានបញ្ហាដូច្នេះ? ហើយតើមកការិយាល័យអប់រំនោះ តើគាត់មានតួនាទី ឬមុខងារធ្វើអ្វីនៅទីនោះ?

[១៥:១២:៣៩]

**ឆ៖** បាទ, លោកចៅក្រម! ក្រោយពីគាត់បានមកនៅការិយាល័យអប់រំស្រុក ដែលមានទីតាំងនៅទីប្រជុំស្រុកស្វាយចេកផ្ទាល់ គាត់ មូលហេតុរបស់គាត់គឺដើម្បីការពារសន្តិសុខផ្ទាល់ខ្លួន បន្ទាប់ពីក្រុមគ្រួសារគាត់ចោរប្លន់សម្លាប់ ។ ហើយខ្ញុំក៏បានអនុញ្ញាតឲ្យគាត់មកជាមួយដើម្បីជួយធ្វើការនិងមើលការងារនៅក្នុងការិយាល័យធម្មតា ដោយមិនបានចាត់តាំងថាឲ្យគាត់កាន់អាមុខការអីឲ្យបានច្បាស់លាស់

ទេ គ្រាន់តែជាជំនួយការរបស់ខ្ញុំផ្ទាល់។

**ស៖** លោក ជូ វិន ចូរលោកនិយាយរៀបរាប់ប្រាប់ដល់អង្គសវនាការ អំពីអត្តចរិតរបស់ជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលលោកស្គាល់ពីមុនថា ហង់ ពិន នោះ ។ ដែលលោកធ្លាប់បានដឹង បានកត់ស្គាល់ នៅក្នុងអំឡុងពេលដែលលោកបានធ្វើការជាមួយនឹងគ្នា និងប្រាស្រ័យទាក់ទងក្នុងនាមសហការីនោះ តើវាយ៉ាងដូចម្តេចដែរ? សូមអញ្ជើញ ។

**ឆ៖** នៅក្នុងឆ្នាំអំឡុង១៩៩៥ បន្ទាប់មកគាត់ទៅធ្វើការនឹងការិយាល័យអប់រំស្រុក ចរិតឫកពាគាត់គឺស្លូតបូត សុភាពរាបសា ម៉ឺងម៉ាត់នឹងការងារ ។ ធ្វើការបានល្អត្រឹមត្រូវ ទៅតាមការដាក់ចុះរបស់- - ខ្ញុំដាក់ឲ្យធ្វើ គាត់ធ្វើកើត ។

**ស៖** ក្រៅពីលក្ខណៈដែលលោកបានកត់សម្គាល់នេះ តើមានលក្ខណៈអ្វីផ្សេងពិសេស ផ្សេងទៀតទេ ដែលលោកបានធ្វើការកត់សម្គាល់អំពីឫកពា អំពីអាកប្បកិរិយាមារយាទ អំពីនិយាយរួមអត្ត-ចរិតរបស់គាត់នេះ តើមានអ្វី លោកមានកត់សម្គាល់អ្វីផ្សេងទៀតទេ?

**ឆ៖** បាទ,លោកចៅក្រម! នៅក្នុងអំឡុងពេលដែលគាត់បានរស់នៅនឹងកន្លែងនោះ គឺការរាប់អានចំណុចពិសេសរបស់គាត់ គឺមានការរាប់អានដោយសារតែគាត់មានប្រជាប្រិយខាងការងារអប់រំ ធ្វើការបានហ្មត់ចត់ល្អ រហូតដល់មុនដំបូងខ្ញុំអត់ដែលស្គាល់ឈ្មោះ ហង់ ពិន ទេ ។ គេហៅតែគ្រូតាៗ រហូតដល់គេប្រសិទ្ធិនាមថា គ្រូតាៗ រហូតមក ។ ខ្ញុំចេះតែឆ្ងល់ថា ទេ ឯណាគ្រូអត់ឃើញ មើលទៅឃើញតែឈ្មោះ ហង់ ពិន អ៊ីចឹងមក ។

[១៥:១៦:០៦]

**ស៖** នៅក្នុងអំឡុងពេលដែលគាត់ធ្វើការប្រាស្រ័យ អ៎! គាត់ធ្វើការជាមួយលោកជាសហការីហ្នឹង តើកាលណោះលោកធ្វើការងារអ្វីដែលលោកបាននិយាយថា បានដាក់ភារកិច្ចឲ្យគាត់ធ្វើការងារអីៗអ៊ីចឹង? តើលោកមានតួនាទីជាអីកាលពីអំឡុងឆ្នាំ១៩៩៥ -១៩៩៧ ដែលលោកបានជួបប្រាស្រ័យទាក់ទងជាមួយនឹងជនជាប់ចោទនោះ?

**ឆ៖** បាទ, លោកចៅក្រមនៅក្នុងអំឡុងឆ្នាំ៩៥ដល់៩៧ ហ្នឹងគាត់បានសូមខ្ញុំទៅធ្វើការជាមួយនៅកន្លែងនោះ គឺខ្ញុំមានតួនាទីជាអនុប្រធានទទួលបន្ទុកការងាររដ្ឋបាល ការងារបុគ្គលិក ហើយនិងគណនេយ្យផ្ទាល់ខ្លួនឯងផង ។ ដូច្នេះទន្ទឹមនឹងការងារនោះ ក៏ខ្ញុំបានដាក់ការងារមួយចំនួនឲ្យគាត់ធ្វើដូចជាការងារ ចែកចាយសៀវភៅ គាត់ធ្វើសៀវភៅ បញ្ជីសៀវភៅទៅការចង់បានរបស់ក្រសួងអប់រំ ទម្លាក់

ចុះទៅគាត់ ខ្ញុំដាក់ការងារឲ្យគាត់ធ្វើគឺគាត់ធ្វើបានតាមផែនការ ហើយទាន់ពេលទៀត ។

**ស៖** ហេតុផលយ៉ាងម៉េចទៅបានជាមានការសម្រេចចិត្តជ្រើសរើសគាត់ធ្វើជាគ្រូ ហើយរហូតដល់លោកបានអះអាងថា គាត់មានក្របខ័ណ្ឌត្រឹមត្រូវ ជាក្របខ័ណ្ឌក្រសួងអប់រំ ពីព្រោះរហូតដល់ឆ្នាំ ៩៤-៩៥ ហើយរបៀបរៀបរយនៃការដំណើរការប្រព្រឹត្តទៅក្នុងការជ្រើសរើសគ្រូហាក់ដូចជាមានការបណ្តុះបណ្តាលត្រឹមត្រូវ មានសាលាគរុកោសល្យចេញពីគរុកោសល្យនានា តាមបណ្តាលខេត្តនានាជាច្រើនគឺ មានទាំងខេត្ត មានទាំងភូមិភាគនៃការផ្តល់សេវាផ្នែកខាងគ្រូ បណ្តុះបណ្តាលគ្រូបង្រៀន ចែកចាយទៅដល់គ្រប់តំបន់នានានៅក្នុងដែនដីសមត្ថកិច្ច តើហេតុផលម៉េចបានជាមានការសម្រេចជ្រើសរើសគាត់ធ្វើការជាគ្រូបង្រៀននៅភូមិផ្គាំ នៅអនុវិទ្យាល័យផ្គាំ ក៏ដូចជាធ្វើជាបុគ្គលិកនៅអប់រំស្រុកកាលនោះ?

**ឆ៖** កាលនៅឆ្នាំ១៩៩៥--៩៤-៩៥ នុំងគឺនៅតំបន់នោះ គឺជាតំបន់ប្រទាញប្រទង់គ្នារវាងត្រីភាគី ហើយនិងរដ្ឋកម្ពុជា ដោយគ្រូមួយចំនួនធំនៅខាងស្រុកថ្មពួកហ្នឹង គឺជាតំបន់សមាហរណកម្ម ហើយនិងតំបន់ខាងស្វាយចេកនេះជាតំបន់រដ្ឋកម្ពុជា ។ ដូច្នេះ គ្រូកាលនោះវាច្របូកច្របល់គ្នាដោយៗគេរំសាយពីជំរំមកវានៅពាសណាពាសណីអ៊ីចឹងមក ។ ដូច្នេះ ស្ថានភាពនៃការអប់រំនៅកន្លែងនោះ គឺអត់មានយើងជ្រើសរើសទៅតាមរយៈថា អ្នកដែលចេះតិចបង្រៀនអ្នកមិនចេះ អ្នកដែលចេះច្រើនបង្រៀនអ្នកដែលចេះតិច ។ អ៊ីចឹងហើយនៅកន្លែងនោះជាតំបន់មួយដែលរហូតមកទាល់សព្វថ្ងៃ គឺនៅតែខ្វះគ្រូនៅឡើយ ខ្វះធនធានមនុស្សសម្រាប់បង្រៀននៅទីនោះបាទ ។ ដូច្នេះខាងនាយកសាលាហ្នឹង គេសម្រេចចិត្តជ្រើសរើស ហើយគាត់បានក្របខ័ណ្ឌមកទាល់ថ្ងៃនេះ គឺម្យ៉ាងគឺកាលនោះ គឺពីជំរំទៅទំនាក់ទំនងជាមួយក្រសួងផ្ទាល់ បានធ្លាក់ក្របខ័ណ្ឌមក យើងប្រើប្រាស់ធម្មតា អ៊ីចឹងបាទ ។

[១៥:២០:០៤]

**ស៖** លោកបានធ្វើការកត់សម្គាល់យ៉ាងម៉េចដែរទេ រវាងអត្តចរិតរបស់គាត់នៅក្នុងការទំនាក់ទំនងប្រាស្រ័យទាក់ទងនៅមជ្ឈមណ្ឌលសិស្ស មជ្ឈមណ្ឌលគ្រូដូចគ្នានៅក្នុងអំឡុងពេលដែលគាត់ធ្វើជាគ្រូបង្រៀននៅអនុវិទ្យាល័យផ្គាំ ហើយនិងអំឡុងពេលក្រោយមកទៀតនៅក្នុងអំឡុងពេលដែលគាត់ទទួលភារកិច្ចជាបុគ្គលិកនៅមន្ទីរអប់រំស្រុកស្វាយចេកនោះ?

**ឆ៖** តាមការកត់សម្គាល់របស់ខ្ញុំ ហើយនិងសន្និដ្ឋានចុងក្រោយឃើញថា អាកប្បកិរិយារបស់គាត់គឺមានរាប់អានពីអ្នកដទៃច្រើន ជាពិសេសអ្នករួមអាជីពជាគ្រូបង្រៀន គឺមានការគាំទ្រគាត់ច្រើន

រហូតដល់ហៅតែគ្រូតាៗ ។ នេះខ្ញុំក៏បញ្ជាក់ថា ហេតុដូចម្ដេចបានជាបុគ្គលិកនេះហៅគាត់តែគ្រូតា ខ្ញុំចេះតែសង្កេតឃើញគាត់ថា គាត់នឹងមានការអប់រំច្រើនមានការយោគយល់គេច្រើន មានអធ្យាស្រ័យ ទាំងចាស់ទាំងក្មេង គឺមានការទទួលស្គាល់គាត់ថា គាត់ជាអ្នកអប់រំមានស្នាដៃល្អ បង្រៀនពូកែ ហើយទាំងគ្រូទាំងសិស្សទាំងអស់គ្នាហ្នឹងគឺថា មានការស្រឡាញ់រាប់អានគាត់ជាធម្មតា ។

**ស៖** នៅក្នុងអំឡុងពេលដែលគាត់ធ្វើការជាមួយលោក ពីព្រោះលោកជាអនុប្រធានអប់រំស្រុក ហើយមានការគ្រប់ដណ្ដប់ទៅលើវិស័យទទួលខុសត្រូវនុ៎ងជាច្រើន ហើយសំណួរសួរថា តើលោកមានដែលកត់សម្គាល់ទៅលើអាកប្បកិរិយា ឬក៏សកម្មភាពរបស់គាត់ស្ដែងចេញយ៉ាងម៉េចខ្លះទេ នៅពេលដែលមានការនិយាយ ឬក៏ការពិភាក្សាដល់ទំនាស់គ្នារវាងខាងនយោបាយ ខាងរដ្ឋាភិបាលកម្ពុជា ហើយនិងខាងត្រីភាគី ព្រោះកាលនោះគឺមានការអនុវត្តនៅគោលនយោបាយតឹងតែងណាស់រវាងភាគីទាំងពីរនេះ នៅក្នុងការយកប្រៀបរវាងគ្នានឹងគ្នា តើលោកដែលកត់សម្គាល់ ឬក៏ការពិភាក្សាពីបញ្ហារបបខ្មែរក្រហមអីអ៊ីចឹងទៅ ហើយអាកប្បកិរិយារបស់គាត់សម្ដែង ស្ដែងឲ្យឃើញយ៉ាងម៉េចខ្លះដែរឬទេ?

[១៥:២២:៤៣]

**ឆ៖** នៅក្នុងអំឡុង ក្នុងរយៈពេលដែលគាត់បានទៅធ្វើការជាមួយគ្នាហ្នឹង គាត់សង្កេតឃើញថាឫកពាររបស់គាត់ធម្មតា ការនិយាយស្ដីអីក៏គាត់មិននិយាយពីរឿងរបបគោលនយោបាយផ្សេងៗ គឺគាត់អត់បាននិយាយប៉ះពាល់ផង ។ ហើយខ្ញុំក៏គិតតែពីរឿងការងារប៉ុណ្ណឹងឯង ។

**ស៖** គាត់ដែលបានចូលរប្រជុំជាសាធារណៈនៅក្នុងកិច្ចប្រជុំគ្រូបង្រៀន ឬក៏កិច្ចប្រជុំនៃមន្ត្រីរាជការបុគ្គលិករបស់ការិយាល័យអប់រំស្រុកដែរឬទេ? ឬក៏អង្គប្រជុំផ្សេងៗទៀតដែលការិយាល័យស្រុកចាត់តាំងឲ្យគាត់ទៅចូលរួមដែរឬទេ?

**ឆ៖** បាទ,លោកចៅក្រម! រយៈកាលកន្លងមកគាត់បានតែប្រជុំរួមនៅក្នុងការិយាល័យ ក្នុងចាត់ចែងការងាររៀបចំកោតុ អីហើយនិងចូលរួមប្រជុំសាមញ្ញអីប៉ុណ្ណឹងទេ ។ អារឿងថា ឲ្យចាត់ចែងអីចាត់តាំងទៅជាភ្នាក់ងារមួយ ឬក៏ជាតំណាងឲ្យការិយាល័យទៅចុះរួមប្រជុំកន្លែងណា គឺដូចដែលបានចាត់តាំងទៅផង ហើយនិងគាត់កាន់សោនៅការិយាល័យ ដើម្បីជួយមើលបោសសម្អាតអីធម្មតាអ៊ីចឹងមក ។ ហើយគាត់---

**ប្រធានអង្គជំនុំ៖**

បើកមេក្រូហ្វូនឲ្យគាត់និយាយបន្តទៀត ។

**ឆ៖** ហើយគាត់តែងតែ ដែលតាមខ្ញុំកត់សម្គាល់គឺថា គាត់គោរពម៉ោងពេលបានៗជាងគេនៅក្នុងចំណោមដែល-- អាហ្នឹងនិយាយពិតនិយាយត្រង់ ក្នុងចំណោមដែលអ្នកដែលសហការីជាមួយគ្នានៅកន្លែងនុំង ព្រោះសុទ្ធតែអ្នកផ្ទះឆ្ងាយៗដល់គាត់ជាចាស់ទុំម្នាក់នៅកន្លែងនោះក៏គាត់បានមកបើកទ្វារអីមកធម្មតាអ៊ីចឹងមក ។

**ស៖** នៅវិស័យគ្រូបង្រៀននៅក្នុងសង្គមយើងបច្ចុប្បន្ននេះ តែងតែទទួលនៅការបណ្ដុះបណ្ដាលបន្ថែម ។ សំណួរសួរថា អំឡុងពេលដែលគាត់ធ្វើគ្រូនៅអនុវិទ្យាល័យផ្កាំហ្នឹង តើខាងការិយាល័យអប់រំហ្នឹងដែលរៀបចំចាត់ចែងចាត់ឱ្យគាត់ទៅបំពេញវិជ្ជាបំពាក់បំប៉នបន្ថែមទេ អំពីគរុកោសល្យ ដូចជាសុក្រឹតការ ឬក៏វិក្រឹតការជាដើម ឬក៏មានការបំប៉នបន្ថែមប្រចាំឆ្នាំជាដើម ពីព្រោះនេះជាអនុវត្តទូទៅនៃគោលនយោបាយអប់រំដែលពង្រឹងពង្រីកនៅសមត្ថភាពខាងចំណេះដឹងដល់គ្រូបង្រៀន ដើម្បីជាប្រយោជន៍ក្នុងពង្រឹងពង្រីកគុណភាពអប់រំ ចំពោះការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ជាបន្តបន្ទាប់គឺឃើញថា ការអភិវឌ្ឍន៍របស់បៀបនេះគ្រប់ទីកន្លែងទាំងអស់ហើយជានិច្ចកាលតែម្ដង។ តើចំពោះគាត់ហ្នឹង គឺបានទទួលការចាត់ចែងឱ្យមានការអភិវឌ្ឍន៍ខ្លួនបែប ដែលយើងបានលើកឡើងអម្បាញ់មិញនេះដែរឬទេ?

[១៥:២៦:០៨]

**ឆ៖** រយៈកាលកន្លងមកគាត់ជាគ្រូបង្រៀនម្នាក់ដែលមានស្នាដៃល្អនៅក្នុងសាលា ហើយគាត់តែងតែឱ្យដំបូន្មាននៅក្នុងសាលាតែក្រោយការ-- ក្រោមការចាត់តាំងរបស់ការិយាល័យដើម្បីឱ្យគាត់ទៅបំពេញវិក្រឹតការអីកន្លែងផ្សេងៗដូចអត់ទាន់មានទេ ។ កាលនោះ វានៅតែច្របូកច្របល់ធ្វើទៅតាមរយៈការរៀនសូត្រពីគ្នាទៅវិញទៅមក ហើយការរៀបចំគ្រូក៏វាមិនទាន់មានលំនឹងបានស្រួលបួល កាលនោះមកធ្វើតាមខ្សែបណ្ដោយ ហើយនិងអង្គភាព ឱ្យអង្គភាពទុកឱ្យអង្គភាពធ្វើការប្រជុំអារឿងការងារបច្ចេក-ទេសផ្សេងៗ ដើម្បីឱ្យមានដំណើរការតាមកម្មវិធីឱ្យទាន់ពេលវេលាប៉ុណ្ណឹង ។

**ស៖** លោករកនឹកលើកវិញមើលថា តើនៅក្នុងការរៀបចំជ្រើសរើសគាត់ដើម្បីឱ្យចូលមកធ្វើជាគ្រូនៅអនុវិទ្យាល័យផ្កាំ ។ នៅក្នុងពាក្យសុំ តើមានការបំពេញបែបបទនៃពាក្យសុំដើម្បីរៀបចំក្របខ័ណ្ឌគ្រូបង្រៀនសម្រាប់បណ្ដុះបណ្ដាលកូនខ្មែរនៅអនុវិទ្យាល័យផ្កាំនៅទីនោះដែលមានការខ្វះខាតនោះ ថាតើមានតម្រូវឱ្យមានពាក្យសុំនោះមានរូបថតភ្ជាប់ជាមួយនឹងពាក្យសុំដែរឬទេ?

**ឆ៖** បាទ, លោកចៅក្រមនៅក្នុងការ-- ដើម្បីឲ្យគាត់ក្លាយខ្លួនជាគ្រូម្នាក់ចាំបាច់ត្រូវតែបំពេញនៅសំណុំទម្រង់បែបបទ មានរូបថតភ្ជាប់ជាមួយនឹងសលាកបត្រ ។

**ស៖** កាលនោះ គឺលោកបាននិយាយហើយ អំមិញថា ឈ្មោះគាត់ប្រើឈ្មោះ ហង់ ពិន ។ សំណួរសួរថា តើគាត់មានប្រើឈ្មោះហៅក្រៅផ្សេងទៀតដែរឬទេនៅក្នុងពាក្យសុំ ដើម្បីរៀបចំបំពេញបែបបទធ្វើជាគ្រូបង្រៀន ក្របខ័ណ្ឌគ្រូបង្រៀននោះ?

**ឆ៖** បាទ, លោកចៅក្រមនៅក្នុងដែលគាត់បានបំពេញសំណុំលិខិតហ្នឹង គាត់មានដាក់ឈ្មោះតែ ហង់ ពិន មួយទេ ។ ប៉ុន្តែគេហៅក្រៅ ហៅតែគ្រូតា១ អ៊ីចឹងតែម្តង ។ អានេះហៅក្រៅដោយគាត់មិនបានសរសេរពាក្យគ្រូតានៅក្នុងសលាកបត្រជាលាយលក្ខណ៍អក្សរទេ ហៅតែឈ្មោះ ហង់ ពិន១ រហូតមក ។

**ស៖** លោកចាំទម្រង់ទេ? ទម្រង់នៃការដាក់ពាក្យសុំធ្វើគ្រូបង្រៀន លោកចាំពីទម្រង់នៃពាក្យសុំដែរទេ ថាតើតម្រូវឲ្យមាននៅឯកសារអ្វីខ្លះ?

**ឆ៖** អត់ទោសលោកចៅក្រម មកទាល់ម៉ោងនេះ ពេលនេះក៏ខ្ញុំមិនទាន់បានចាំទេ មិនបានចាំទេ ប៉ុន្តែ បើតាមទម្លាប់របស់ការជ្រើសរើសគ្រូបង្រៀនវាតែងតែមានសំណុំវាដាក់ពាក្យស្នើសុំចូលគ្រូមធ្យមសិក្សទុតិយភូមិ បម្រើការនៅកន្លែងណាមានេះជីវប្រវត្តិ មានសលាកបត្រជាធម្មតាអ៊ីចឹងតែម្តង ហើយមានកិច្ចសន្យាត្រឹមត្រូវ បានក្រសួងគេទទួលយកធ្វើជាផ្លូវការដើម្បីទទួលស្គាល់តែម្តង ។ ប៉ុន្តែ នៅតំបន់នោះភាគច្រើន គឺគេបានទៅទាក់ទងនៅភ្នំពេញតែម្តង នៅក្រសួងអប់រំដើម្បីទម្លាក់មក ព្រោះខាង វាមានខ្សែខាងអប់រំមកពីជំរំមក ចួនកាលទម្លាក់ឈ្មោះទៅចំឲ្យយើងទទួលយកទៅគ្រប់គ្រងទៅប្រើប្រាស់ធម្មតា។

[១៥:៣០:២២]

**ស៖** លោកចាំទេ ថាតើលោកបានមើលនៅប្រវត្តិរូបរបស់គាត់ដែរទេ? ប្រវត្តិរូបជីវប្រវត្តិរបស់គាត់ដែលសរសេរនៅក្នុងពាក្យសុំ?

**ឆ៖** អត់ទោសលោកចៅក្រម ខ្ញុំបានទៅមើលសលាកបត្រ ហើយមានរូបថតជាប់នឹងសលាកបត្រហ្នឹងតែម្តង ។ គាត់បាននិយាយពីរឿងកាលដែលប្រពន្ធ គាត់ដាក់នៅពោះម៉ាយ ប្រពន្ធគាត់ស្លាប់ហើយមានកូនប៉ុន្មាននាក់ ហើយរៀននៅឯណា សម័យ ប៉ុល ពត ធ្វើអ្វី? សម័យណាធ្វើអី? គាត់ដឹង គាត់ដាក់ហ្នឹង ហើយសញ្ញាប័ត្ររបស់គាត់ កម្រិតវប្បធម៌របស់គាត់គឺមាននៅក្នុងសលាកបត្រហ្នឹង ។

**ស៖** លោកចាំទេនៅក្នុងជីវប្រវត្តិហ្នឹង តើនាមត្រកូលរបស់កូនគាត់ ដែលដាក់ក្នុងប្រវត្តិរូបហ្នឹង គាត់ដាក់ត្រកូលអ្វីដែរ? សូមលោកនិយាយតែគោលប៉ុណ្ណោះ មិនឲ្យនិយាយពាក់ព័ន្ធជាមួយនឹងឈ្មោះខ្លួនរបស់កូនរបស់គាត់ទេ?

**ឆ៖** ខ្ញុំដូចជាចាំអត់បានទេ ។

**ស៖** លោកកត់សម្គាល់ឃើញថា ក្រៅពីទំនាក់ទំនង គាត់ប្រាស្រ័យទាក់ទងនៅក្នុងសង្គម ជាគ្រូដូចគ្នា ឬក៏ជាបុគ្គលិកសិក្សានៅក្នុងអនុវិទ្យាល័យផ្គាំ និងនៅក្នុងអំឡុងពេលដែលគាត់ធ្វើការងារនៅក្នុងការិយាល័យអប់រំស្រុក ។ តើលោកបានកត់សម្គាល់ក្នុងការដែលគាត់ប្រាស្រ័យទាក់ទងជាមួយនឹងសង្គមសហគមន៍ផ្សេងទៀតដែលគាត់រស់នៅហ្នឹង តើគាត់មានទំនាក់ទំនងរបៀបម៉េចដែរ?

**ឆ៖** ខ្ញុំចាំអត់បានផង។ ប៉ុន្តែខ្ញុំកត់សម្គាល់ត្រង់ថា មានការរាប់អានពីប្រជាជនច្រើនរហូតដល់ល្បីឮដល់លោកការិយាល័យ ហើយនៅឆ្នាំសិក្សា១៩៩៥-៩៦ហ្នឹង គាត់បាន-- គេស្នើសុំគាត់ឲ្យទៅជួយបង្រៀនភាសាបារាំងនៅអនុវិទ្យាល័យស្វាយចេកមួយទៀត ។ នេះជាចំណុចពិសេសរបស់គាត់ ដែលទទួលស្គាល់ពីការអប់រំ ចំណេះដឹងរបស់គាត់ រហូតដល់សាលាហ្នឹងសុំឲ្យគាត់ជួយទៅបង្រៀនភាសាបារាំងនៅ ។ ហើយរូបខ្ញុំផ្ទាល់ដែលជាអនុប្រធានការិយាល័យទទួលបន្ទុកបុគ្គលិកហ្នឹង គឺបានចាត់តាំងឲ្យគាត់ទៅនៅកាន់អនុវិទ្យាល័យស្វាយចេក បង្រៀនភាសាបារាំង គឺនៅថ្ងៃទី២៨ ខែ១០ ឆ្នាំ១៩៩៦ ។

[១៥:៣៣:២៧]

**ស៖** ទិដ្ឋភាពមួយចំនួននៅពេលក្រោយសមាហរណកម្ម កម្លាំងទាំងអស់ស្ទើរគ្រប់អង្គភាពត្រូវបានច្របាច់បញ្ចូលគ្នារវាងភាគីកាលនោះ គឺរដ្ឋកម្ពុជា ហើយនិងភាគី ត្រីភាគី ប៉ុន្តែការសមាហរណកម្មបែបផែនណាក៏ដោយ គឺភាគច្រើនមនុស្សទាំងអស់នោះ គឺមានប្រភពច្បាស់លាស់ ថាមកពីភាគីណាមួយ ដែលមកធ្វើសមាហរណកម្មចូលនៅក្នុងអង្គភាពមន្ទីរនានារបស់ខាងរដ្ឋកម្ពុជា ដែលគ្រប់គ្រងដែនដីស្ទើរតែទាំងស្រុងនោះ ។ សំណួរសួរថាកាលនោះលោកដឹងទេថា ប្រភពរបស់ជនជាប់ចោទហ្នឹង គាត់មកពីប្រភពនៃភាគីណាមួយក្នុងចំណោមត្រីភាគី លោកមានព័ត៌មានហ្នឹងដែរឬទេ?

**ឆ៖** អត់ទោសលោកចៅក្រម នៅកន្លែងនេះខ្ញុំមិនបានចាប់អារម្មណ៍ដល់ គាត់មកពីភាគីណាទេ ពីព្រោះតំបន់សមាហរណកម្មកាលនោះ វាច្របូកច្របល់គ្នាណាស់ មកពីជំរំគ្រប់ ទាំងអស់ អ្នកខ្លះមកទៅរើសថ្មី អ្នកខ្លះស៊ីឈ្មោះគេ ជំនួសឈ្មោះគេ ចួនកាលក៏រើសថ្មី អ៊ីចឹងធ្វើម៉េចឲ្យកូនខ្មែរនៅកន្លែងនោះបានរៀន ។ ព្រោះរយៈកាលមក កន្លែងនោះជាកន្លែងប្រឈមមុខនឹងសង្គ្រាម បិទសាលាស្ទើរតែកូនក្មេង

មិនចេះអក្សរ ។ បន្តិចខ្មែរក្រហមចូល បន្តិចខាងយើងចូល បន្តិចប៉ារ៉ាចូល ។ អ៊ីចឹងទេ បានន័យថាយើងក្តាប់សភាពការណ៍នៅកន្លែងនោះអត់បាន រហូតដល់ការិយាល័យស្រុកខ្លះ មិនប៊ានទាំងចុះទៅផង។ មានតែនាយកសាលាទេ ដែលឡើងមកជួបការិយាល័យបាន ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ? សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សួស្តីលោកសាក្សី លោកបានបង្ហាញប្រាប់អង្គសវនាការថា លោកបានជួប ឌុច ហើយគាត់ហ្នឹង គឺជាជនរងគ្រោះនៃអំពើប្លន់មួយ ហើយដោយសារអំពើប្លន់ហ្នឹងឯង ប្រពន្ធរបស់គាត់បានស្លាប់ ។ តើលោកដែលមានឱកាសបាននិយាយអំពីព្រឹត្តិការណ៍នេះជាមួយគាត់ទេ ហើយតើគាត់មានបានប្រាប់លោកអ្វីខ្លះទេ អំពីព្រឹត្តិការណ៍នៃការប្លន់នោះ?

**ឆ៖** អត់ទោសលោកចៅក្រម សូមឆ្លើយនឹងសំណួរនេះ គឺថា ខ្ញុំអត់បានក្តាប់ឲ្យបានផង កន្លែងហ្នឹង ព្រោះកាលណាតំបន់ហ្នឹងជាកន្លែងអសន្តិសុខ សូម្បីតែខ្លួនខ្ញុំក៏មិនដែលបានចុះទៅឲ្យបានជាប់លាប់ ហើយស៊ើបអង្កេតពីរឿងបញ្ហាហ្នឹងដែរ មានតែគាត់ឡើងមកជួបរាយការណ៍ពីការដែលប្លន់ប៉ុណ្ណឹងទេ ។ រហូតដល់គាត់ ជាមូលហេតុនៃការដែលឲ្យគាត់មកនៅជាមួយខ្ញុំនៅការិយាល័យហ្នឹង គឺដោយសារការគេប្លន់ ហើយសម្លាប់ប្រពន្ធគាត់ គាត់គ្រាន់តែប្រាប់ប៉ុណ្ណឹងទេ ។ ហើយខ្ញុំសួរដេញដោលអាលិចអាកើតក៏ខ្ញុំមិនបដែលបានសួរនាំឲ្យបានច្បាស់លាស់ថា វាយ៉ាងម៉េច ។

[១៥:៣៧:២០]

**ស៖** ឈ្មោះ ហង់ ពិន គឺជាឈ្មោះមួយ តើឈ្មោះហ្នឹង វាមានប្រភពស្រដៀងគ្នាទៅនឹងឈ្មោះចិនឬ? ហើយថាតើគាត់ដែលនិយាយអំពីប្រភពគ្រួសារគាត់ ដែលគ្រួសារចិននោះដែរឬទេ? ដែលថាមានជីដូនជីតា ជាជនជាតិចិននោះ?

**ឆ៖** អត់ទោស ខ្ញុំអត់ដែលដឹងទេ អត់ដែលបានតាមដានដល់ថ្នាក់ហ្នឹងផង ។

**ស៖** នៅអំឡុងពេលនោះ តើជនជាប់ចោទហ្នឹងបានប្តូរសាសនាពីសាសនាព្រះពុទ្ធ មកសាសនាគ្រិស្តហើយឬនៅ? ហើយតើគាត់មានបានជជែកពិភាក្សាជាមួយលោកអំពីសាសនាដែរឬទេ?

**ឆ៖** នៅក្នុងអំឡុងពេលដែលគាត់បានទៅនៅការិយាល័យអប់រំស្រុកហ្នឹង គាត់បានប្តូរពីព្រះពុទ្ធសាសនា មិនដឹងជាគាត់ប្តូរពីអង្កាល់ណាទេ ប៉ុន្តែគាត់បានទៅចូលសាសនាយេស៊ូ ។ ឮគាត់និយាយអ៊ីចឹង ប៉ុន្តែខ្ញុំមិនបានចាប់អារម្មណ៍ថា វាយ៉ាងម៉េចៗ ដេញដោលហើយ ព្រោះគាត់វាមិនដែលបានទៅយកអារឿងសាសនានេះទៅផ្សព្វផ្សាយ អារឿងនៅក្នុងការិយាល័យអីឲ្យបានទូលំទូលាយទេ ។ គាត់ទៅចូល ចូលតែគាត់ កូនចៅគាត់អ៊ីចឹងម្តង ។ ខ្ញុំចាប់ត្រង់ឆ្ងល់ថា តើគាត់មានផ្សព្វផ្សាយអត់ អានេះខ្ញុំគិតថា មិនសូវជាមានចាប់អារម្មណ៍ទៅលើគាត់ កាន់សាសនាណា ក៏ខ្ញុំមិនដែលបានរវីរវល់ផង ។

**ស៖** ប្រសិនបើខ្ញុំយល់ដឹងត្រឹមត្រូវ អ្វីដែលលោកនិយាយប្រាប់ដល់អង្គជំនុំជម្រះនេះ គឺថាវាមានបញ្ហាច្រើនណាស់ពាក់ព័ន្ធនឹងជនជាប់ចោទ ដែលថាលោកបានដឹងនៅពេលក្រោយតែប៉ុណ្ណោះ ជាពិសេសឧទាហរណ៍ថា បញ្ហាមួយចំនួនធំៗ គឺលោកមិនដែលបានពិភាក្សាផ្ទាល់ជាមួយគាត់ ឬមួយក៏ត្រូវព័ត៌មានទាំងនោះត្រូវបានលាក់ពីគាត់ តើលោកអាចយល់ដឹងថា គាត់ហ្នឹងគឺជាប្រភេទមនុស្សម្នាក់ដែលព្យាយាមលាក់បាំងនៅព័ត៌មានមួយចំនួន ឬក៏លាក់កំបាំងនូវការពិតអស់ទាំងនោះ?

**ឆ៖** អត់ទោសលោកចៅក្រម នៅពេលយកគាត់មកនៅកន្លែងហ្នឹង គឺចាត់ទុកថា ជាការមួយគាំពារ ដើម្បីឲ្យគាត់មានសុវត្ថិភាពផ្ទាល់ខ្លួនប៉ុណ្ណឹងទេ ។ ហើយព្រោះបុគ្គលិកនៅកន្លែងហ្នឹង វាមានការគ្រប់គ្រាន់ហើយ ។ ដូច្នេះមិនចាំបាច់ត្រូវហៅគាត់មកប្រជុំទៅជាភ្នាក់ងារការិយាល័យអ៊ីចឹងទេ ដើម្បីទុកជម្រើសឲ្យគាត់ថែរក្សាខ្លួនគាត់ សុវត្ថិភាពខ្លួនគាត់ ហើយគ្រាន់តែជួយការពារគាត់តែប៉ុណ្ណឹងទេ មិនបានផ្តល់តួនាទីណាមួយឲ្យបានធំដុំដើម្បីឲ្យគាត់ដឹងទេ ព្រោះការចាត់តាំងការងារផ្សេងៗ គឺសម្តឹងទៅតាមនាយកដែលមានការធ្វើទៅតាមឋានន្តរក្រមប៉ុណ្ណឹងទេ ចាប់ពីថ្នាក់ស្រុកទៅក្រោម ។ ឲ្យគេនាយកហ្នឹង គេគ្រប់គ្រងគាត់វិញទេ ។ ដល់មនុស្សការិយាល័យអប់រំស្រុកដូចគ្នា គាត់ជាភ្នាក់ងារម្នាក់ដែលទទួលបន្ទុកការងារ ដែលខ្ញុំដាក់ឲ្យធ្វើប៉ុណ្ណឹងទេ ឲ្យថាចែកភារកិច្ចឲ្យកាត់ទទួលបន្ទុកនេះ ធ្វើនេះដូចមិនទាន់បានដាក់ឲ្យគាត់ទេ ដូច្នេះមិនចាំបាច់ឲ្យគាត់ដឹងទេ ។ គ្រាន់តែដាក់ការងារឲ្យគាត់ធ្វើទៅជាបុគ្គលិកម្នាក់ប៉ុណ្ណឹងទេ ។

[១៥:៤១:០៤]

**ស៖** ខ្ញុំយល់ដឹងអំពីចំណុចនេះ ។ អ៊ីចឹងដូច្នេះមានន័យថា គាត់គឺជាមនុស្សម្នាក់ដែលមានភាពជិតស្និទ្ធជាមួយនឹងលោក ហើយដែលលោកធ្វើការងារជាមួយជារៀងរាល់ ហើយលោកបានជួបគាត់ស្ទើរតែរៀងរាល់ថ្ងៃនោះ ។ តើយើងអាចនិយាយនៅថ្ងៃនេះថា គាត់គឺជាមនុស្សម្នាក់ដែលមានចំណុច

លាក់កំបាំងមួយចំនួន។ តើនៅពេលហ្នឹង លោកមានបានសម្គាល់មើលថា គាត់ជាមនុស្សម្នាក់ដែលលាក់កំបាំងនូវព័ត៍មានខ្លះដែរឬទេ ឬមួយលោកមានការភ្ញាក់ផ្អើលនៅពេលក្រោយនៅពេលដឹងថា តើ ហង់ ពិន នោះគឺជានរណាគេនោះ?

**ឆ៖** បាទ, លោកចៅក្រម! ខ្ញុំមានការភ្ញាក់ផ្អើលនៅពេលដែលគេចាប់ឃាត់ខ្លួនលោក ហង់ ពិន នៅពេលដែលគេចាប់បាន ដូចថា ឈ្មោះ ឌុច ឈ្មោះ កាំង ហ្គេកអ៊ាវ នោះទៅវិញទេ ។ កាលគេនៅជាមួយខ្ញុំ គឺជាបុគ្គលោកសាមញ្ញធម្មតា ព្រោះតំបន់នោះ ជាតំបន់អ្នកណាដែលមានជាងគេ ឬមួយក៏មានហៅថាជីវភាពគ្រាន់បើជាងគេ គឺមានចោរប្លន់ធម្មតា មានការគេចខ្លួន ដើម្បីរកសុវត្ថិភាពផ្ទាល់ខ្លួន មិនចាំបាច់តែ ហង់ ពិន ទេ អ្នកណាក៏ដូចគ្នា នៅតំបន់នោះ ។ អ៊ីចឹងទេ ខ្ញុំមិនបានជាចាប់អារម្មណ៍ពីបញ្ហានេះផង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី ខ្ញុំមិនមានសំណួរបន្ថែមទៀតទេ លោកប្រធាន ។

[១៥:៤២:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដល់សាក្សីរូបនេះ សូមអញ្ជើញ ។

**តាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក តាំង សេណារ៉ុង៖**

**ស៖** អរគុណលោកប្រធានអង្គជំនុំជម្រះ ហើយសូមស្វាគមន៍លោក ជូ វិន ។ អម្បាញ់មិញលោកបានជម្រាបជូនលោកចៅក្រមរួចមកហើយថា នៅពេលដែលលោកទទួលបានសមាសភាពដែលចូលមកបង្រៀននៅក្នុងស្រុករបស់លោក លោកបានទទួលសលាកបត្រមួយ នៅក្នុងនោះជនជាប់ចោទបានបំពេញសលាកបត្រ ដែលនិយាយពីប្រវត្តិរបស់គាត់នៅសម័យមុនៗ និងសម័យ ប៉ុល ពត ថាគាត់បានធ្វើអ្វីខ្លះ។ សំណួរសួរថា តើលោកមានបានពិនិត្យមើលសលាកបត្ររបស់គាត់ថា តើក្នុងសម័យ ប៉ុល ពត ហ្នឹងគាត់ធ្វើអ្វី ហើយមុនសម័យប៉ុល ពតហ្នឹង គាត់បានធ្វើអ្វីទេលោក?

**ឆ៖** ព្រះរាជអាជ្ញា! ខ្ញុំសូមឆ្លើយអាកន្លែងនេះថា ក្រោយពីឲ្យគាត់បំពេញនូវសលាបត្រតាមខ្ញុំចាំបាន ។ គាត់និយាយពីសម័យមុននឹងសម័យ ប៉ុល ពត គាត់ធ្វើជាគ្រូបង្រៀនម្នាក់ ក្នុងសម័យ ប៉ុល ពត

គាត់ជានិពន្ធសៀវភៅសម្រាប់បង្រៀនឲ្យកុមារ និងក្រោយមកគាត់ធ្វើគ្រូបង្រៀនប៉ុណ្ណឹងទេ ។

**ស៖** អរគុណលោក ។ នៅក្នុងនោះដែរ តើលោកមានបានសំណេះសំណាលជាមួយនឹងគាត់ថា តើគាត់ដែលមកធ្វើជាសមាសភាពគ្រូបង្រៀននៅក្នុងស្រុករបស់លោកហ្នឹង ចូលមកពីសមាសភាពនៃក្រុមណាមួយឡើងវិញហ្នឹង សូមលោកបញ្ជាក់ឡើងវិញបានទេ?

**ឆ៖** អត់ទោស លោកព្រះរាជអាជ្ញា! ខ្ញុំសូមឆ្លើយនៅកន្លែងនេះថា រយៈពេលនៃការនោះ ដើម្បីសុវត្ថិភាពខ្លួនគាត់ គាត់បានមកនៅឆ្នាំ៤៥ គាត់បានមកនៅក្នុងការិយាល័យអប់រំស្រុក ។ ក្នុងរយៈពេលមួយខ្លីទេ មិនមែនជាយូរប៉ុន្មានទេ ព្រោះគាត់ត្រូវការបង្រៀននៅអនុវិទ្យាល័យថែមទៀត ។

[១៥:៤៥:00]

ដូច្នេះ បវេនសកាលឆ្នាំ៤៥-៤៦ ហ្នឹងខ្ញុំបានបញ្ជូនគាត់ទៅនៅអនុវិទ្យាល័យស្វាយចេក ។ ដូច្នេះពេលវេលានៃការសំណេះសំណាល នេះវាគ្រាន់តែថា មិនបានទៅចាប់អារម្មណ៍ថា គាត់ហ្នឹង គេដេញដោលពីរឿងប្រវត្តិរូបគាត់ ឬក៏សមាសភាពគាត់មកពីណាហ្នឹង អត់បានចាប់អារម្មណ៍ទេ ព្រោះវាច្របូកច្របល់ដល់ទៅត្រីភាគី ។ ម្ល៉ោះហើយអាកន្លែងខ្លះ សូម្បីតែគ្រូនៅសព្វថ្ងៃដូចគ្នា គាត់មកពីនោះស៊ីឈ្មោះគេផង ឈ្មោះគ្រូម្នាក់ ឈ្មោះម្នាក់ គ្រូពីរនាក់ក៏មាន ។ អីចឹងទេ ខ្ញុំមិនសូវជាចាប់អារម្មណ៍ទេ ប៉ុន្តែដល់ក្រសួងទម្លាក់ទៅ បានខ្ញុំទទួលធ្វើការប្រាក់ខែជូនតែម្តង ។ ទទួលស្គាល់ថា គ្រូមធ្យមសិក្សាទុតិយភូមិ ឬក៏គ្រូមធ្យមសិក្សាបឋមភូមិ ប៉ុណ្ណឹងទេ ព្រោះវានៅកន្លែងនោះ វាជ្រក់ជ្រេញទៅហើយអារឿងការគណបក្សវាច្រើនពេកទៅខ្ញុំមិនបានជាស្គាល់គណបក្សណាផង ព្រោះនៅតែរដ្ឋកម្ពុជានៅឡើយ ។

**ស៖** អរគុណលោក ជូ វិន ។ ចាប់តាំងពីលោកបានស្គាល់គាត់ ហើយដែលធ្វើជាសហការីនៅក្នុងស្រុករបស់លោកនាពេលនោះ និងរហូតមកដល់ដែលលោកដឹងថា លោក ហាង់ ពិន នោះ គឺជាឈ្មោះ កាំង ហ្គេកអ៊ាវ ទេ ។ តើចាប់តាំងពីពេលដែលលោកស្គាល់នុ៎ង តើលោកអាចបង្ហាញពីចំណុចពិសេសៗរបស់ឈ្មោះ កាំង ហ្គេកអ៊ាវ ដែលមានឈ្មោះពីមុនថា ហាង់ ពិន ហ្នឹងប្រាប់ជូនអង្គជំនុំជម្រះបានទេថា គាត់ហ្នឹងជាមនុស្សប្រភេទដូចម្តេច? ដែលមុន ដែលក្នុងប្រវត្តិរូបរបស់គាត់ ហើយដែលគាត់បានចូលរួមធ្វើជាសហការីនៅក្នុងស្រុករបស់លោកនុ៎ង រហូតដល់ពេលដែលគេមកចាប់ខ្លួនបានហ្នឹង ។ លោកសូមបញ្ជាក់ជូនអង្គសវនាការឡើងវិញបានទេ? ចាប់ពីពេលនុ៎ងរហូតដល់ពេលដែលគាត់ដឹងថា គាត់ជាប្រធានមន្ទីរ ស-២១ ហ្នឹង ។

**ឆ៖** ចាប់តាំងពីគាត់បានរួចអាជីពជាគ្រូបង្រៀននៅជាមួយខ្ញុំ ក្រោមការគ្រប់គ្រងរបស់ខ្ញុំផ្ទាល់ នៅឆ្នាំ១៩៨៥ មកនៅក្នុងការិយាល័យហ្នឹង គាត់មិនបានសម្តែងអាកប្បកិរិយាណាមួយដែលធ្វើឱ្យយើងចាប់អារម្មណ៍ទេ ។ ប៉ុន្តែចំណុចពិសេសរបស់គាត់ គឺឃើញថា នៅក្នុងចំណោមគ្រូទាំងអស់គាត់ចេះជាងគេ ចេះត្រង់ថា គាត់បង្រៀនកើត មានបទពិសោធន៍ល្អ ។ រហូតដល់គេប្រសិទ្ធិនាមគាត់ថា គ្រូតាៗរហូតមក ។ ខ្ញុំក៏បានស្គាល់ច្បាស់គាត់នៅឆ្នាំ៨៥ ដែលគាត់មកសុំនៅតែម្តង សុំនៅ ហើយក៏ខ្ញុំស្រាវជ្រាវទៅតាមនុ៎ង ថាគ្រូនៅឯណា? នៅឯណាទៅ? បានគាត់ឆ្លើយថា គ្រូនៅបង្រៀននៅអនុវិទ្យាល័យផ្កាំ ។ ហើយខ្ញុំក៏ដើម្បីគាំពារគាត់ឱ្យរួចផុតពីអសន្តិសុខនោះ គាត់ក៏-- ខ្ញុំសុខចិត្ត ខ្ញុំបានអនុញ្ញាតឱ្យគាត់មកនៅជាមួយតែម្តង ។ ហើយបន្ទាប់មកពីនោះទៀត ខ្ញុំអត់បានតាមដានថា គាត់ហ្នឹងជាមនុស្សរបៀបម៉េច ប៉ុន្តែពិសេសរបស់គាត់ គឺបង្រៀនបានល្អជាងគេនៅក្នុងចំណោមមនុស្សចាស់ ហើយគេគោរពគាត់ថាជាគ្រូតាម្នាក់ ។ រហូតដល់សាលាវិទ្យាល័យ អនុវិទ្យាល័យស្វាយចេក គេដឹងថាគាត់ចេះភាសា ហើយបង្រៀនបាន ខ្វះគ្រូបង្រៀនបារាំង គេក៏មកស្នើហ្នឹងខ្ញុំ ខ្ញុំក៏បានអនុញ្ញាតឱ្យគាត់ផ្លាស់ចូលទៅក្នុងអង្គភាពអនុវិទ្យាល័យហ្នឹង នៅថ្ងៃទី២៨ ខែ១០ ១៩៨៦ ។

[១៥:៤៨:០០]

**លោក តាន់ សេណារ៉ុង៖**

អរគុណលោក ឌូ រិន ខ្ញុំអស់សំណួរ ដើម្បីនឹងសួរលោកទៀតហើយ ខ្ញុំបង្វិលសំណួរបន្តទៅជូនសហការីរបស់ខ្ញុំ ។ អរគុណលោកប្រធានអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្វាឯល៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោក ឌូ រិន ខ្ញុំចង់សួរនូវសំណួរផ្ទាល់ខ្លួនពីរបីសំណួរ ទាក់ទងទៅនឹងអំឡុងពេលដែលលោកបានស្គាល់ជនជាប់ចោទ ។ លោកបាននិយាយអំពីអង្គហេតុមួយចំនួនទាក់ទងទៅនឹងបញ្ហាសុវត្ថិភាពផ្ទាល់របស់ជនជាប់ចោទ ដែលថាគាត់ត្រូវបានអនុញ្ញាតឱ្យរស់នៅនៅក្នុងមន្ទីររបស់លោក គឺនៅមន្ទីរអប់រំស្រុកដែលលោកធ្លាប់ធ្វើការនោះ ។ តើនេះគឺជាចំណុចមួយ ឬក៏កាលៈទេសៈមួយដែលលោកនឹងត្រូវធ្វើសម្រាប់ឱ្យអ្នកណាគេគ្រប់គ្នា ដែលជនរងគ្រោះពីអំពើចោរប្លន់នោះឬ?

**ឆ៖** បាទ, លោកព្រះរាជអាជ្ញា! ខ្ញុំសូមឆ្លើយនឹងកន្លែងនេះថា នេះជាទង្វើសម្រាប់ទទួល-- ក្នុងនាមជាអ្នកដឹកនាំ ត្រូវតែទទួលខុសត្រូវចំពោះគ្រប់សមាសភាពនៃគ្រូបង្រៀន មិនចាំបាច់តែគាត់ម្នាក់ទេ គឺអ្នកណាក៏ខ្ញុំទទួលបានដូចគ្នា ឲ្យតែភៀសខ្លួនដើម្បីសុវត្ថិភាព ។ ព្រោះយើងដឹងហើយថា តំបន់នោះជាតំបន់អសន្តិសុខ ។ មានលួចផង ប្លន់ផង បាញ់កាប់សម្លាប់គ្នាស្ទើររាល់ថ្ងៃ ព្រោះអាកន្លែងប្រទាញប្រទង់មិនទាន់ច្បាស់លាស់ល្អទេ គោរពច្បាប់ក៏វាមិនបានត្រឹមត្រូវដែរកាលណោះ ។ គឺខ្ញុំចាំបាច់ត្រូវតែទទួលយកគ្រប់គ្រូបង្រៀនទាំងអស់ ឲ្យមានសភាពការណ៍ដូច្នេះ គឺថាត្រូវតែការពារគាត់ យកគាត់មកដាក់មួយកន្លែងដែលមានសុវត្ថិភាពប៉ុណ្ណឹងទេ ។

[១៥:៥០:៥២]

**ស៖** ដូច្នេះ ដើម្បីផ្តល់សុវត្ថិភាពដល់បុគ្គលណាម្នាក់ តើយើងគួរតែត្រូវដឹងអំពីហេតុផលនៃអសន្តិសុខនោះឬ? តើមានបានព្យាយាមស្វែងរកព័ត៌មានឲ្យបានជ្រាលជ្រៅពីគាត់ទេ ថាគាត់មានការបារម្ភអំពីអ្វី? តើគាត់-- មានន័យថា គាត់មានបារម្ភអំពីចោរប្លន់ ដែលអាចនឹងត្រឡប់មករកគាត់ទៀត? ឬមួយក៏គាត់នឹងមានការភ័យបារម្ភនឹងខ្មែរក្រហម ឬក៏រដ្ឋាភិបាល? សម្រាប់ខ្ញុំ ខ្ញុំពិបាកនឹងយល់ណាស់ថា ហេតុអ្វីបានជាលោកមិនបានសួរជនជាប់ចោទអំពីសំណួរអស់ទាំងនេះ? ឬមួយតើលោកមានបានចាំទេ ថាលោកមានបានសួរជនជាប់ចោទនូវសំណួរអស់ទាំងនេះ?

**ឆ៖** អត់ទាន់ទេ ខ្ញុំសូមឆ្លើយអាកន្លែងនេះថា តំបន់នោះជាតំបន់អសន្តិសុខ រហូតដល់មិនមែនមានតែម្នាក់គាត់ទេ មានឈ្មោះ ទុន ប៊ុនឈិន មានឈ្មោះជាច្រើនទៀត បីបួននាក់ទៀត ដែលរត់មកប្រមូលផ្តុំនៅកន្លែងស្រុកស្វាយចេក ។ ហើយជាពិសេសមេឃុំ មេភូមិ ដែលមាននៅរដ្ឋកម្ពុជា ក្រោយពីពួកនោះចូលធ្វើសមាហរណកម្មមក គឺថាគាត់បានរត់មកប្រមូលផ្តុំនៅកន្លែងស្រុកជាធម្មតា ព្រោះអានេះជាប្រពៃណីខាងកងទ័ព ។ សូម្បីតែគ្រូបង្រៀននៅកន្លែងនុំងក៏ប្រឈមកាន់អាវុធដើម្បីច្បាំងជាមួយភាគីម្ខាងដែរ នេះជាទម្លាប់មួយខាងនោះ គេថាអ្នកណាដែលធ្វើការនៅរដ្ឋកម្ពុជាគឺមកនៅកន្លែងស្រុក ។

**ស៖** តើនៅអំឡុងពេលនុំង ជនជាប់ចោទនុំងក៏មានកាន់អាវុធដែរមែនទេ?

**ឆ៖** នៅក្នុងពេលនុំងគាត់មិនបានកាន់អាវុធទេ។ គាត់មានឫកពាស្លូតបូត សឹងថាមិននិយាយជាមួយនឹងអ្នកណាផង គាត់ឲ្យដាក់ធ្វើអី ឲ្យមកនៅបោសសម្អាតនៅកន្លែងកិរិយាល័យ ក៏នៅធម្មតា គោរពម៉ោងពេលនៅចាំមើលយើងដែលទៅពីឆ្ងាយ ឬសហការីដែលធ្វើការជាមួយគ្នា អ្នកណាក៏ទៅឃើញដូចគ្នាអ៊ីចឹង ។ ក្រោយមកទៀត មកឆ្នាំដែលគាត់មកហ្នឹងវាផុតពីសង្គ្រាមទៅហើយ ប៉ុន្តែនៅតែសន្តិសុខ

និងអសន្តិសុខហ្នឹងវាមានគ្រប់ច្រកល្ហកទាំងអស់ ។

**ស៖** តើលោកប្រាកដថាឬ គឺមិនមានពាក្យចចាមអារ៉ាមនៅពេលនោះទេថា ខ្មែរក្រហម ឬក៏កម្មាភិបាលខ្មែរក្រហមនៅពេលនុំង ឬក៏ថាក្នុងនាមគាត់ជាប្រធានស-២១ ហើយថាតើពាក្យចចាមអារ៉ាមហ្នឹងមានពាក់ព័ន្ធអ្វីទៅនឹងឈ្មោះ ហង់ ពិន ដែរឬទេ? តើលោកមិនបានផ្តល់ចំណុចសំខាន់អ្វីទេឬទាក់ទងទៅនឹងពាក្យចចាមអារ៉ាម ដែលថាលោក ហង់ ពិន ហ្នឹង គឺជាប្រធានស-២១ នោះ?

[១៥:៥៤:១០]

**ឆ៖** បាទ,លោកព្រះរាជអាជ្ញា! នៅក្នុងអំឡុងពេលនោះ ខ្ញុំមិនបានចាប់អារម្មណ៍ពីរឿងបញ្ហាថា ខ្មែរក្រហម ឬក៏គុក-- មេគុក ឬមួយក៏ឈ្មោះ កាំង ហ្កេកអ៊ាវ ឬមួយក៏ឈ្មោះអីផ្សេងៗ ខ្ញុំអត់បានចាប់អារម្មណ៍ទេ ។ ឈ្មោះក្រោយហ្នឹង គឺថាទើបតែឮចាប់ខ្លួនបាន គឺឮឈ្មោះតែម្តង រហូតដល់ខ្ញុំភ្ញាក់ខ្លួនថា មិននឹកស្មានថា គាត់ហ្នឹងធ្វើធំដល់ម្លឹងផង ។ វាទៅជា ខ្ញុំថាមិនដឹងជាមនុស្សមួយដែលចាស់ម្នាក់ ដែលមានកម្លាំងអន់ខ្សោយ ហើយមិនបានឲ្យទៅបង្រៀននៅឯណាផង យកមកទុកនៅកន្លែងហ្នឹង ដើម្បីសុវត្ថិភាពប៉ុណ្ណឹងទេ ។

**ប្រធានអង្គជំនុំ៖**

លោកមានពេលប្រាំនាទីទៀត ក្នុងការសួរនេះ ។

**សួរដោយលោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្វាឯល៖**

លោកប្រធាន ខ្ញុំនឹងបញ្ចប់ក្នុងពេលឆាប់ៗនេះ ។

**ស៖** មានការរាយការណ៍មួយនៅក្នុងសៀវភៅរបស់លោក ដនឡុប គឺនៅទំព័រ២៥៤, ២៤៤ និង២៤៥ គាត់និយាយថា នៅក្នុងឆ្នាំ៩៤ មានគ្រូបង្រៀនជាច្រើនដែលជាសហសេវិករបស់ ហង់ ពិន បានធ្វើដំណើរមកភ្នំពេញ ហើយពួកគេម្នាក់បានទៅពិនិត្យមើល-- បានទៅទស្សនកិច្ចនៅទួលស្លែង ។ ហើយក៏បាននិយាយផងដែរនៅក្នុងសៀវភៅរបស់លោក ដនឡុប នោះ ថាសហសេវិកម្នាក់នុំង គឺបានស្គាល់ថា ហង់ ពិន ហ្នឹងគឺជា ឌុច គឺដោយរូបថតដែលគាត់បានឃើញនៅមន្ទីរស-២១ ។ ហើយគាត់បាននិយាយពីចំណុចហ្នឹង ពីព្រឹត្តិការណ៍ហ្នឹងប្រាប់ដល់សហសេវិករបស់គាត់ ។ ប៉ុន្តែ ក្រោយមកទៀត ពួកគាត់មិនបាននិយាយអំពីចំណុចនេះប្រាប់អ្នកដទៃទៀតទេ ដោយសារតែការភ័យខ្លាច ។ តើលោកមានបានដឹងអំពីរឿងនេះដែរឬទេ? ឬមួយក៏តើសហសេវិករបស់លោកបាននិយាយរឿងនេះប្រាប់លោកដែរឬទេ?

**ឆ៖** នៅក្នុងចំណុចនេះខ្ញុំអត់បានដឹងទេ ព្រោះនែ៎សហសេវិកខ្ញុំដែលបានមក គឺជាប្រធានរបស់ខ្ញុំផ្ទាល់តែម្តង ហើយគាត់តែងតែនិយាយលេងធម្មតា ក៏ខ្ញុំមិនដែលបានចាប់អារម្មណ៍ផង ។ មិនដែលបានចាប់អារម្មណ៍ថា ខ្មែរក្រហមហ្នឹងមានទោសប៉ុនណា អីប៉ុនណា ព្រោះ អៀង សារី ចូលមក ខៀវ សំផន ក៏ចូលមក។ ខ្ញុំថា អ្ហឺ! ធម្មតារដ្ឋកម្ពុជាតែងតែមានអធ្យាស្រ័យទោសគ្រប់តែកន្លែងឲ្យតែយើងសារភាពអ៊ីចឹង ។ បានជាខ្ញុំយកអាធម៌ហ្នឹងដាក់ខ្លួនមក ខ្ញុំមិនដែលបានសួរនាំលិចកើត គិតតែរឿងការបំពេញការងាររបស់ខ្ញុំប៉ុណ្ណឹងទេ ។

[១៥:៥៧:០៩]

**ស៖** លោក ជូ វិន នៅពេលចុងក្រោយដែលលោកបានដឹងថា ហង់ ពិន ឬក៏ ឌុច ហ្នឹង គឺជាប្រធានស-២១ នោះ តើលោកមានអារម្មណ៍នៅពេលក្រោយមកថា លោកហ្នឹងត្រូវបាន ហង់ ពិន ក្បត់លោកទេ? ដែលថាគាត់បានលាក់កំបាំងនូវប្រវត្តិឧក្រិដ្ឋរបស់គាត់នោះ ហើយដែលថា គាត់គួរអាចនឹងផ្តល់នូវគ្រោះថ្នាក់ ធ្វើឲ្យប៉ះពាល់ដល់ជីវិតរបស់គ្រូបង្រៀនអ្នកដទៃទៀត ដែលបង្រៀននៅក្នុងកន្លែងរបស់លោក ឬក៏អាចធ្វើប៉ះពាល់ដល់ជីវិតរបស់កូនសិស្សរបស់លោកនោះ ។ តើលោកខ្លួនឯងផ្ទាល់ហ្នឹងយល់ថាមិនគួរឲ្យជឿសោះថា គាត់ហ្នឹងសម្តែងតួបានល្អបំផុត ដែលធ្វើឲ្យមនុស្សគ្រប់រូបជឿទៅលើអាកប្បកិរិយារបស់គាត់នោះ?

**ឆ៖** បាទ, លោកព្រះរាជអាជ្ញា! មកទល់ថ្ងៃដែលគេចាប់ខ្លួនបាន ហើយទើបតែដឹងថាគាត់ឈ្មោះកាំង ហ្គេកអ៊ាវ ហៅ ឌុច ហ្នឹង គឺថា ខ្ញុំមានរំភើបក្នុងចិត្តថា គាត់ហ្នឹងដូចជាក្បត់រហូតដល់ពេលនេះ ខ្ញុំនិយាយថា បើប្រហែលជាគាត់ជួបមុខ ប្រហែលជាគាត់នឹង-- ព្រោះពេលនោះខ្ញុំអត់ដឹងទេ អត់ដឹងអីទាំងអស់ ។ មកទល់ពេលនេះ ប្រហែលជាគាត់ឃើញខ្ញុំ ហើយសើចនៅពេលទង្វើរបស់គាត់រយៈកាលកន្លងមកធ្វើឲ្យមានការភ័យខ្លាចទូទាំងប្រទេសផង ។ ហើយខ្ញុំក៏រំភើបចិត្តថា មិនគួរ-- ប៉ុន្តែអ្វីដែលគាត់នៅជាមួយខ្ញុំ គឺខ្ញុំមិនបានប្រើប្រាស់ឲ្យគាត់ឲ្យវាល្អក់កករយ៉ាងម៉េចៗទេ ។ ខ្ញុំអត់ដឹងទាល់តែសោះ ។ ទើបគេចែកចាប់បានហើយ ដឹងតែឃើញតាមទូរទស្សន៍ទៅ បានគិតថាឃើញថា អ៎! សម័យនោះបើសិនណាជាគាត់មានចិត្តក្បត់ ហើយសម្លាប់ខ្ញុំ ប្រហែលជាស្លាប់ដូចគ្នា ។ ប៉ុន្តែ ខ្ញុំមិនមានចិត្តដល់ប៉ុណ្ណោះទេ ព្រោះៗទង្វើរបស់គាត់ធ្វើល្អធម្មតា ដូចគេដូចឯងរហូតដល់ឲ្យគុណសម្បត្តិគាត់ថា គាត់បង្រៀនបានល្អអ៊ីចឹង ។

**លោក វ៉ាំងសង់ ដឺវ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរទៀតទេចំពោះសាក្សីនេះ ។

បាទ, សូមអរគុណលោកសាក្សី ។

[១៥:៥៩:៣៧]

**ប្រធានអង្គជំនុំ៖**

ជាបន្តអង្គជំនុំជម្រះផ្ដល់វេទិកាទៅមេធាវីការពារក្ដី ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះ ។ ប្រសិនបើមានសូមអញ្ជើញមេធាវីការពារក្ដី ។

**តាំងសំណួរដោយមេធាវីការពារក្ដី**

**សួរដោយ លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោក ជូ វិន ខ្ញុំសូមអនុញ្ញាតសួរលោកដូចតទៅ។ សួរថាតើលោក កាំង ហ្កេកអ៊ាវ ឬហៅថាលោក ហង់ ពិន នោះ មករួមរស់ជាមួយរដ្ឋាភិបាលបច្ចុប្បន្ននេះ មុនសមាហរណកម្ម ឬនៅពេលសមាហរណ៍កម្ម?

**ឆ៖** បាទ, លោកតាំងពីខ្ញុំស្គាល់មក គឺថាឃើញគាត់មកក្រោយសមាហរណកម្ម ព្រោះថាការមានសមាហរណកម្មទេ មានគ្រូមកពីជើងដើម្បីដាក់បញ្ចូលគ្នាបង្រៀនក្រោមការគ្រប់គ្រងរបស់ការិយា-ល័យមន្ទីរ ស្រុកដូចគ្នា ។ កាលនោះស្រុកពីរកាន់តែមួយ មានស្រុកស្វាយចេកមួយ ស្រុកថ្មពួកមួយនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យអប់រំស្រុកតែមួយ ។ ដូច្នេះ តំបន់មានពីរ ប៉ុន្តែក្រោយសមា-ហរណកម្មបានខ្ញុំសិទ្ធិគ្រប់គ្រងគ្រូទាំងអស់ ។

**ស៖** សូមអរគុណ។ អ៊ីចឹងក្រោយពីពេលសមាហរណ៍កម្ម បានសេចក្ដីថានៅពេលដែលគាត់បានមករួមរស់ គឺបានសេចក្ដីថា ពេលដែលគាត់ចេញពីខ្មែរក្រហមមកហ្នឹង តើគាត់មាននៅទាក់ទងជាមួយពួកខ្មែរក្រហមដទៃទៀតដែរឬទេ?

**ឆ៖** នៅពេល អំឡុងពេលដែលគាត់បានមកក្រោយសមាហរណ៍កម្មមកឃើញថា តាមខ្ញុំសង្កេតតាមដានទៅឃើញថា ដូចអត់ទាន់មានទាក់ទងអីទេ គាត់ខ្លាចខ្លួនមកពីនោះហើយគាត់មកនៅស្វាយចេកតែម្ដង គាត់មិនបានទៅណាទេ។ អានេះតាមទង្វើរនៃរយៈពេលដែលគាត់មកនៅជាមួយខ្ញុំរយៈពេលខ្លី ។ ព្រោះមកនៅនៅការិយាល័យឆ្នាំ៩៥ ទៅបង្រៀននៅ ៩៦ នៅអនុវិទ្យាល័យ ដោយកន្លែងនោះខ្វះគ្រូផង

តាមសំណូមពររបស់នាយកផង ក៏បានបញ្ជូនគាត់ទៅផុត ។ ពេលផុតពីនោះទៅទៀតខ្ញុំក្តាប់អត់បានទេ។

**ស៖** សូមអរគុណ ក្នុងមួយរយៈពេលដែលគាត់មករួមរស់ជាមួយលោក អ៊ីចឹងលោកបញ្ជាក់ច្បាស់ហើយថាមិនមានទាក់ទងជាមួយនឹងខ្មែរក្រហមទៀតទេ ។ អ៊ីចឹងខ្ញុំអាចសួរលោកទៀតថា តើជនជាប់ចោទបច្ចុប្បន្ននេះ ដែលមានរួមរស់ជាមួយលោក តើដែលមានបញ្ហាអ្វីធ្វើឲ្យល្អក់កករដល់សហគមន៍ដែរឬទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍ថា គាត់ដូចជាអត់មានបញ្ហាឲ្យដល់សហគមន៍ផង ហើយក្នុងជួរគ្រូបង្រៀនក៏គាត់មិនបានបង្កបញ្ហាអី គាត់នៅតែស្ងប់ស្ងៀម យូរៗទៅសុំខ្ញុំទៅ សុំច្បាប់ទៅព្រះវិហារនៅបាត់ដំបង នេះតាមគាត់ស្នើសុំច្បាប់ខាងយេស៊ូប៉ុណ្ណឹងទេ ។

**ស៖** សូមអរគុណ ។ អ៊ីចឹងតើជនជាប់ចោទនេះ អាចរស់នៅក្នុងសហគមន៍បានតទៅទៀតបានដែរឬទេ? សូមបញ្ជាក់មើលតាមការសន្និដ្ឋានរបស់លោក ។

[១៦:០៣:៤៣]

**ឆ៖** តាមការសន្និដ្ឋានរបស់ខ្ញុំតាមការរស់នៅរបស់គាត់នៅក្នុងសហគមន៍នៅភូមិផ្កាំ ឬមួយក៏នៅខាងស្វាយចេក?

**ស៖** នៅជាមួយលោក ។

**ឆ៖** នៅជាមួយខ្ញុំ គឺអាចបន្តបាន ព្រោះការគាំទ្ររបស់គេ គឺច្រើនៗ-- ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារក្តី ចាំរៀបចំសំណួរឡើងវិញ មិនគប្បីសួរនូវសំណួរណាបំណងឲ្យចម្លើយរបស់សាក្សីតបវិញជាសេចក្តីសន្និដ្ឋាននោះទេ ពីព្រោះសាក្សីពុំមានគុណភាពធ្វើសេចក្តីសន្និដ្ឋានដូចអ្នកជំនាញទេ ។ អ៊ីចឹង អ្នកទាំងពីរនេះចូលរួមនៅក្នុងដំណើរការនីតិវិធីខុសគ្នា ។

**លោក ការ សាវុត្ថ៖**

**ស៖** អ៊ីចឹងសូមលោកស្តាប់សំណួរម្តងទៀត ។ អ៊ីចឹងក្នុងមួយរយៈពេលដែលជនជាប់ចោទរស់នៅជាមួយលោក អ៊ីចឹងជនជាប់ចោទអាចរស់នៅជាមួយសហគមន៍បាន មែនឬទេ?

**ឆ៖** បាទ, លោកប្រធាន! គាត់អាចរស់នៅបាន ។

**ស៖** សូមអរគុណ ។ ពេលដែលមហាជន គេឲ្យរហស្សនាមគាត់ថា "ជាគ្រូតា" ដោយមហា--ដោយពេលនោះ គេយល់ថា គាត់បានបង្រៀនល្អជាងគេ ។ តើមានគុណសម្បត្តិអ្វីក្រៅពីនេះទៀតទេ

ដែលគេឲ្យរហស្សនាមថា គ្រូតា នោះ? សូមលោកបញ្ជាក់ ។

**ឆ៖** ខ្ញុំតែងតែសួរទៅលើបុគ្គលិក ម៉េចបានហៅគ្រូតា ព្រោះដល់កន្លែងហ្នឹង កន្លែងអ្នកណាដែលមានប្រជាប្រិយភាពខាងការបង្ហាត់បង្រៀន មានការរស់នៅជាសហគមន៍ចូលចុះ ហើយគេកោតសរសើរពីអ្នកដទៃផងនោះ គេនឹងឲ្យប្រសិទ្ធនាមទៅគាត់ហើយ ព្រោះតំបន់នោះ គេនិយមអ្នកណាដែលលេចធ្លោជាងគេ គេហៅគ្រូតា គេហៅ បងធំ អ៊ីចឹងតែម្តង ។

**ស៖** សូមអរគុណលោក ជូ វិន ដែលលោកបានឆ្លើយសំណួររបស់ខ្ញុំ ហើយសូម ខ្ញុំសូមអស់សំណួរ ហើយសុំលោកប្រធានមេត្តាអនុញ្ញាតឲ្យលោកមេធាវីការពារក្តីអន្តរជាតិមេត្តាសួរបន្ត ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ប៉ុន្តែជាបន្តអង្គជំនុំជម្រះយើងរំឭកដល់សាក្សីថា គួររំឭកឡើងវិញក្នុងការប្រើពាក្យសមាហរណកម្មនេះ ការដែលធ្វើមាតុភូមិនិវត្តន៍ដោយអនុវត្តតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសនោះរឿងមួយ ហើយរឿងមួយទៀតគឺសមាហរណកម្មកម្លាំងកងទ័ពខ្មែរក្រហមដែលមិនបានចូលរួមក្នុងការបោះ ឆ្នោតតាមការរៀបចំរបស់អង្គការសហប្រជាជាតិនោះរឿងមួយទៀត គឺនៅក្នុងខែ៦ ឆ្នាំ១៩៩៦ ហើយនិងដំណាក់កាលចុងក្រោយមួយទៀតនៃកម្លាំងដែលនៅសេសសល់ នេះជាការគិតអំពីកាលប្បវត្តិដើម្បីឆ្លើយតបទៅនឹងសំណួរផ្សេងៗឲ្យបានច្បាស់ បើពុំដូច្នេះទេ វាអាចភ័ន្តច្រឡំប្រវត្តិសាស្ត្រនាំឲ្យមានបញ្ហាស្មុគស្មាញដល់ការវិភាគរបស់អង្គជំនុំជម្រះដែរ ។

លោកយល់ទេ អាបញ្ហានេះ? ពីព្រោះសមាហរណកម្មនេះ គឺយើងប្រើវាមានអាចនិយាយជារួម ប៉ុន្តែមួយគឺ ការធ្វើមាតុភូមិនិវត្តន៍របស់-- កាលនោះគឺខាងត្រីភាគី គឺនៅក្នុងអំឡុងពេលនៃការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីសដើម្បីធ្វើសមាហរណកម្មមកបោះឆ្នោតឆ្នាំ៩៣ ហើយមួយទៀតគឺសមាហរណកម្មកម្លាំងកងទ័ពខ្មែរក្រហមលើកដំបូង គឺនៅថ្ងៃ នៅខែមិថុនា ឆ្នាំ១៩៩៦ ហើយកាលនោះគឺជាការចាប់ផ្តើមទ្រង់ទ្រាយធំ ហើយក្រោយមកទៀត គឺមានព្រឹត្តិការណ៍នៃកម្លាំងចុងក្រោយបង្អស់ ប្រហែលជានៅឆ្នាំ១៩៩៨ ។

អ៊ីចឹង ការណ៍ដែលយើងប្រើពាក្យពេចន៍នេះឲ្យមានការលក្ខណៈច្បាស់លាស់ដើម្បីងាយយល់អំពីហេតុការណ៍ដែលកើតមានឡើងចំពោះជនជាប់ចោទ ពីព្រោះបញ្ហានេះជារឿងអង្កេតដេញដោលមួយទាក់ទិនជាមួយនឹងអត្តចរិត ហើយក៏មានការពាក់ព័ន្ធចិត្តជិតទៅនឹងនិយោបាយរបស់ខ្មែរក្រហមផងដែរ

ដែលវាមានការពាក់ព័ន្ធទៅនឹងជនជាប់ចោទខ្លួនគាត់ផ្ទាល់ ។

ជាបន្តសូមអញ្ជើញ លោក ហ្វ្រង់ស្វ័រ រូ ដើម្បីមានឱកាសក្នុងការសួរសំណួរដល់សាក្សីរូបនេះ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

**ស៖** សូមអរគុណ លោកប្រធាន សូមគោរពលោកសាក្សី ។ ដូច្នេះលោកបាន ដូចដែលលោកបានរៀបរាប់ជូនអង្គសវនាការហើយ លោកមានការកោតសរសើរ ឌុច នៅពេលនោះ ទោះបីជាគាត់នៅពេលនោះ មិនមានដាក់ឈ្មោះ ឌុច នោះក៏ដោយ ហើយលោកក៏បានឆ្លើយផងដែរថា លោកមានការភ្ញាក់ផ្អើលណាស់នៅពេលដែលលោកបានដឹងថា លោក ហាង់ ពិន គឺជាអតីតប្រធានស-២១ ។ ខ្ញុំចង់សួរដូចតទៅ ថាតើលោកមានជួបប្រទះបញ្ហាណាមួយដែរឬទេ ក្នុងការមកផ្តល់ចម្លើយនៅក្នុងថ្ងៃនេះ? ថាតើលោកមានជួបបញ្ហាណាទេនៅពេលដែលលោកមកផ្តល់សក្ខីកម្មនៅទីនេះ? ហើយលោកមានការពិបាកក្នុងចិត្តទេ នៅពេលដែលមកផ្តល់សក្ខីកម្មនេះ? នៅពេលនេះលោកបានដឹងហើយថា លោកហ្នឹងគឺជាអតីតប្រធានស-២១ ថាតើលោកយល់យ៉ាងម៉េចដែរនៅក្នុងថ្ងៃនេះ? តើលោកគិតអំពីអត្តចរិត តើលោកយល់យ៉ាងម៉េចអំពីអត្តចរិតរបស់ជនជាប់ចោទនេះ?

[១៦:១០:៤៧]

**ឆ៖** បាទ,លោកប្រធាន! ក្រោយពីគាត់ ក្រោយពីដឹងថាគាត់ហ្នឹងជាមេគុកទួលស្លែង រហូតមកដល់ពេលនេះ ខ្ញុំបានមកធ្វើជាសាក្សីនេះ គឺខ្ញុំសូមឆ្លើយតែការពិត តាមត្រង់ តែដឹងថាគាត់ជាមេ២១ ក៏ខ្ញុំក៏មិនដឹងថាតើធ្វើយ៉ាងម៉េចដូចគ្នា ។ អានេះធ្វើទៅតាមកាតព្វកិច្ច ទៅតាមការចង្អុលបង្ហាញរបស់តុលាការ ខ្ញុំក៏ឆ្លើយតាមធម្មតា ។ តែតាមខ្ញុំដឹង តាមខ្ញុំបានឮ បានឃើញ ហើយនិងការអនុវត្តរបស់គាត់ផ្ទាល់ គឺឃើញថាអីចឹង មិនមានអីខុសប្លែកពីធម្មតាគួរឲ្យចាប់អារម្មណ៍ទេ ។

**ស៖** លោកក៏បានរៀបរាប់ជូនយើងខ្ញុំផងដែរថា លោកបានប្រាប់ថា គាត់ លោកសរសើរ និងកោតសរសើរគាត់ណាស់ តើលោកបាននិយាយអីចឹងដែរឬទេ? ហើយលោកចូលចិត្តគាត់ ហើយកោតសរសើរគាត់ ហើយលោកបានរៀបរាប់អំពីគុណសម្បត្តិរបស់គាត់នៅពេលនោះ នៅពេលដែលលោកបានជួបគាត់ហ្នឹង តើលោកមានបាននិយាយដូច្នោះដែរឬទេ?

**ឆ៖** អត់ទោសមេធាវី ខ្ញុំបាននិយាយដូច្នោះមែន ។ កាលសរសើរគាត់ទៅតាមការដែលគាត់ធ្វើបានធ្វើកើត ហើយដាក់ស្តែង។ នេះជាគុណសម្បត្តិរបស់គាត់ សូម្បីថាគាត់ធ្លាប់អីក៏ខ្ញុំវាអត់ដឹងដែរ ។ នេះខ្ញុំនិយាយតាមពិតតាមត្រង់ ។

**ស៖** នេះជាអ្វីដែលអង្គជំនុំជម្រះចង់ពីលោក គឺឲ្យលោកនិយាយតែការពិត ហើយលោកបានរៀបរាប់ពិស្តារនូវអ្វីដែលលោកបានស្គាល់ និងអ្វីដែលលោកបានយល់អំពីជនជាប់ចោទ ។ ហើយក្នុងនាមជាមេធាវីការពារក្តី ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក ដែលលោកបានធ្វើដំណើរមកផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់ជនជាប់ចោទ ។ យើងខ្ញុំពុំមានសំណួរសួរទៅកាន់លោកទៀតទេ ។

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ជូ វិន ដែលបានអញ្ជើញមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតាមការកោះហៅរបស់អង្គជំនុំជម្រះ ហើយអង្គជំនុំជម្រះក៏កត់សម្គាល់ឃើញថាមានការលំបាកនៅក្នុងការប្រឈម និងឆ្លើយនឹងសំណួរផ្សេងៗពីអង្គជំនុំជម្រះ និងពីភាគីដែលទៅចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីស្តាប់សក្ខីកម្មរបស់លោក ។ ប៉ុន្តែ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោកបានប្រឹងប្រែងអស់ពីលទ្ធភាពនៅក្នុងការអនុវត្តកាតព្វកិច្ចក្នុងនាមជាសាក្សី ហើយដំណើរក្នុងការស្តាប់លោកក្នុងនាមជាសាក្សី ហើយបានដល់ទីបញ្ចប់ហើយ ។ ដូច្នេះ លោកអាចត្រឡប់ទៅលំនៅដ្ឋានរបស់លោកវិញបាន ឬក៏លោកអាចទៅទីកន្លែងណាដែលលោកចង់ទៅបានហើយ ចាប់ពីពេលនេះទៅ ។

[១៦:១៤:៤៧]

ហើយមន្ត្រីតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីរៀបចំជូនដំណើរសាក្សីដែលបានផ្តល់សក្ខីកម្មរួចហើយឲ្យគាត់បានវិលត្រលប់ទៅលំនៅដ្ឋានរបស់គាត់វិញ ហើយដោយឡែកសាក្សីពីររូបទៀត ដែលមិនទាន់ធ្វើសក្ខីកម្ម គឺសូមជម្រាបគាត់ថា ដោយពេលវេលាថ្ងៃនេះគឺអស់ហើយ យើងលើកដំណើរការសវនាការក្នុងការស្តាប់សាក្សីពីរនោះទៅព្រឹកថ្ងៃស្អែក ។

ដូច្នេះ អង្គសវនាការប្រកាសផ្អាកដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការលើកបន្តទៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹកតទៅ ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនជាកំណត់ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:១៦នាទី]*